ភាគទី២៩

ជាបឋមនាងយល់ថារឿងករណីនាយKenគួរតែឲ្យរាមនរិន្ទដឹងឲ្យបានច្បាស់ ប៉ុន្តែខ្លួនត្រូវសារភាពការពិតពីដើមដល់ចប់ប្រាប់គេឬយ៉ាងណា? តើគេនឹងជឿនាងដែរទេ? ហើយចុះបើគេជឿ តើគេគិតយ៉ាងណាចំពោះប្រការដែលនាងបានធ្វើឲ្យព័ត៌មានមកកាន់ចាយ៉ាពូរ៉ារបស់គេត្រូវធ្លាយបែក?

នាងនិយាយប្រាប់ខ្លួនឯងតិចៗ៖

-កេតឌីម៉ា! ឯងជំពាក់គេច្រើនដល់ហើយ!

សន្សឹមៗ នារីលើកដៃដាក់លើប្រអប់សោក្នុងភាពស្ទាក់ស្ទើរថាគួរចេញទៅរកនាយរឿនដើម្បីលុបចោលការទិញសំបុត្រយន្តហោះទៅភ្នំពេញវិញ ឬក៏យ៉ាងណា?

នាងដាក់ដៃលើរនុកទ្វារ រួចទុចង៉ក់វិញជាមួយសំនួរមិនដាច់ស្រេចថាចុះបើមិនព្រមឆ្លៀតពេលនេះត្រឡប់ទៅភ្នំពេញ តើត្រូវបន្តផ្សងព្រេងជាមួយពួកគេដល់ពេលណាទៀត?

នាងនៅរេរាជុំវិញពាក្យ ថាចង់នៅ និងចង់ទៅ។ សម្ដីអង្គរក្សខ្ពស់ស្រាវលាន់មកសាជាថ្មីក្នុងអារម្មណ៍នាង "កោះហ្នឹងឆ្ងាយដាច់សង្វែង គ្មានចុងភៅ គ្មានអូតែលទេ! បាយពីរពេលក៏ប្រហែលជាពិបាករកផង! នាងដាច់ចិត្តដែរ?"

នាងក្រមុំដកដង្ហើមធំហើយគិតក្នុងចិត្ត៖

"ម៉េចក៏ឯងគិតពីគេកេតឌីម៉ា? មកពីឯងចង់សងគុណគេ ឬមួយឯងពិតជាចិត្តមិនដាច់ និងវង្វេងដៃរបស់គេ? ប៉ុន្តែទោះបីមិនបាននៅជាមួយគេទៀត ក៏គួរតែនិយាយប្រាប់គេអោយដឹងពីរឿងឧបាយកលពាណិជ្ជករដែកថែបដែរមែនទេ?"

នាងមួលសោទ្វារដោយមិនដឹងច្បាស់ទេថាខ្លួនកំពុងធ្វើអ្វី ដូចពាក្យ ថាគ្មានអ្វីរញ៉េរញ៉ៃជាងកំសួលចិត្តមនុស្សស្រីទេ។

ទ្វាររបើកតិចៗទៅតាមចិត្តស្ទាក់ស្ទើររបស់ម្ចាស់បន្ទប់ ប៉ុន្តែរូបរាងធំជង្រ្គោងរបស់បុរសម្នាក់ដែលឈរនៅខាងក្រៅទ្វារនោះ បានបញ្ចេញមកនូវស្នាមញញឹមអត់មានអ្វីស្ទាក់ស្ទើរឡើយ។ នាងភ្ញាក់ស្ទើរដាច់ផ្ងារនៅពេលឃើញគេមកឈរនៅក្រៅទ្វារតាំងពីពេលណាមកក៏មិនដឹង។

-លោកប្រុសរាម?

អ្នកប្រុសរបួសដៃគ្រងដោយអាវដំណោក បោះជំហានមួយៗចូលមកក្នុងបន្ទប់មិនរវល់នឹងភាពភ្ញាក់ផ្អើលរបស់ឌីម៉ា ធ្វើឲ្យនាងបែរក្រោយតាមសម្លឹងសកម្មភាពគេដោយងឿងឆ្ងល់។

មកដល់ក្នុងបន្ទប់ដែលក្រអូបប្រហើរដោយក្លិនខ្លួននារី រាមនរិន្ទប្រាសខ្លួនផ្កាប់មុខភឹងទៅលើពូក ធ្វើឲ្យស្រីស្អាតភ័យស្ទើររបូតមាត់ស្រែក ព្រោះគេហាក់ដូចមិនបានថ្នាក់ថ្នមរបួសដៃដែលនៅសល់បង់រុំនៅឡើយនោះសោះ។

នាងស្ទុះចូលទៅជិតគេ ប្រុងហារមាត់សួរថាម៉េចក៏គេប្រហែសម្ល៉េះ ប៉ុន្តែនាងទប់មាត់នៅស្ងៀមវិញ ព្រោះឃើញសម្ងំស្ងៀមគ្មានកម្រើកហាក់កំពុងត្រៀមគេងលក់មែនទែន។

-ជួយបន្ថយពន្លឺភ្លើងផងបានអត់?

នារីកាន់តែហួសចិត្ត ប៉ុន្តែនាងចាំបាច់ត្រូវតែធ្វើតាមសម្ដីគេ។ បរិយាកាសក្នុងបន្ទប់នារីរូបល្អ ប្ដូរមកជាស្រទន់ដោយពន្លឺភ្លើងពណ៌លឿងព្រាលៗជាមួយនឹងសំនួរតិចៗក្នុងចិត្ត៖

-គេគិតគេងនៅទីនេះមែនក៏អី? ម៉េចក៏ចូលចិត្តធ្វើអីចម្លែកៗម៉េះ? យប់មិញខឹងសម្បារ ថ្ងៃនេះចេញចរិតដូចកូនក្មេង!

ទោះជាបែរខ្នង ប៉ុន្តែគេប្រហែលជាដឹងថានាងនៅឈរទ្រឹងនៅឡើយ បានជានិយាយបន្ថែម៖

-ហើយចាំអង្គាល់បានចូលគេង?

តរុណីរវេ្ទកសម្លឹងទៅបរិវេណគ្រែដែលត្រូវបានរាងកាយគេគ្របដណ្ដប់ស៊ឹងថាគ្រប់កន្លែងទៅហើយ នាងចង់ទាញដណ្ដើមយកខ្នើយប្រចាំរបស់ខ្លួនមកវិញដែរ ប៉ុន្តែក៏ដឹងដែរថាវាគ្មានផ្លូវ ទើបត្រូវបង្ខំចិត្តដើរត្រឹកៗមកប្រះខ្លួនតិចៗលើគ្រែរបស់លំអង ហើយបែរខ្នងឲ្យគេទាំងមិនស្រណុកក្នុងចិត្ត។

អ្នកគ្រូបង្ហាញម៉ូតខំប្រឹងធ្មេចភ្នែកក្នុងពេលសម្រិបជើងគេលាន់មកក្បែរនាង តែពេលនេះទោះបីនាងប្រឹងគេចពីការពិតក៏នាងមិនអាចធ្វើមិនដឹងមិនឮចំពោះរាងកាយធ្ងន់កណ្ដុកដែលឱបនាងពីក្រោយជាប់ម៉ឺងនោះដែរ។

នាងមិនរើទៀតទេព្រោះដឹងថាគ្មានប្រយោជន៍។ ជួបបុរសនេះទើបតែប៉ុន្មានថ្ងៃ ក៏ប៉ុន្តែនាងហាក់ឆាប់ស្គាល់ចិត្តគេជាងនាយKenដែលនាងបានចំណាយបេះដូងជាច្រើនខែមកហើយនោះផង។

នាងនៅស្ងៀមបណ្ដោយឲ្យបុរសឱបរឹតពីក្រោយខ្នង រហូតដល់គេលោមកថើបកញ្ចឹងកសរលោងរបស់នាង ធ្វើឲ្យនាងរវេខ្លួនគេច។ រាមនរិន្ទនិយាយតិចៗក្បែរត្រចៀកៈ

-ស្នេកបែកគ្នាហើយ! កុំធ្វើដូចគ្មានបេះដូងសោះមើល៍?

ស្រីស្អាតគ្មានពាក្យអ្វីតប តែនាងរឹតតែមិនចង់ឲ្យខ្លួនឯងប្រឈមនឹងស្ថានភាពបែបនេះ នៅពេលទុក្ខកង្វល់ជាច្រើនជំពូកកំពុងតែញាំញីនៅឡើយ នាងក្រឡាស់ខ្លួនបែរមកទល់មុខនឹងបុរសដែលកំពុងលង់ក្នុងកាមារម្មណ៍។ នាងនិយាយមួយៗដោយសម្លឹងចំកែវភ្នែកគេៈ

-ខ្ញុំទៅកោះស្នោលឿងជាមួយលោក!

រាមនរិន្ទសម្លឹងផ្ទៃមុខសស្លេកដែលនៅកៀកបង្កើយ។ វាចម្លែកដែរដែលនាងលើកនេះសម្លឹងមុខអ្នកចំ ប៉ុន្តែមិនអ្វីទេព្រោះនាងកំពុងធ្វើក្នុងកាលៈទេសៈសមរម្យ គឺបេះដូងបុរសកូនអ្នកតំណាងរាស្ត្រពិតជាកំពុងត្រូវការពន្លឺភ្នែកនេះ។

គេនិយាយតិចៗតបទៅកាន់នាងៈ

-ហើយចុះ ដឹងហើយមែនអត់? ថាមានគេស្រលាញ់យើង នឹកយើងចង់ឆ្កួតទៅហើយកេតឌីម៉ា?

នារីដកក្រសែភ្នែកគេចពីពន្លឺភ្នែកអណ្ដែតអណ្ដូងរបស់គេ មកវាក់នឹងផែនទ្រូងស្រស់សង្ហាដែលនៅកៀកនឹងខ្លួនបង្កើយ។ នាងស្រាប់តែមានអារម្មណ៍ថាដង្ហើមខ្លួនទៅជាញាប់ ហើយដៃជើងចេញចំហាយក្ដៅអ៊ុនៗដូចកំពុងស្ថិតនៅក្នុងស្ថានភាពគ្រុនសន្និ។

នាងមិនដឹងទេថានេះជាសញ្ញានៃការចុះចាញ់ភាពបបោសអង្អែល និងការប៉ះពាល់រវាងភេទផ្ទុយដែលគ្រប់គ្នាហៅថាមនោសញ្ចេតនាតបស្នេង និងដែលរាមនរិន្ទតែងតែចង់បាន ព្រោះគេមិនដែលឃើញនាងមានអារម្មណ៍បែបនេះចំពោះខ្លួននៅរាល់ពេលនៅក្បែរគ្នាគ្រាមុនៗឡើយ។

នៅពេលដែលផែនថ្ពាល់ស្រីស្រស់ប្រែពណ៌ទៅជាក្រហមតាមធម្មជាតិនៃនារីភេទដែលលង់ក្នុងការថ្នាក់ថ្នមដោយដៃបុរស រាមនរិន្ទសង្កេតឃើញថា ព្រួញកាមទេពដែលនាយកំពុងបាញ់ទម្លុះបេះដូងស្រី ស្រស់ បានក្រឡានាងឲ្យទៅជាទេពធីតាមួយអង្គដែលស្អាតជាងពេលណាៗទាំងអស់។

គ្មានបុរសណាអាចទប់ចិត្តក្នុងស្ថានភាពនេះបានទេ។ សាជាថ្មី គេឱបរាងកាយទន់ល្វក់ក្នុងរង្វង់ដៃ។ ទោះបីនាងប្រឹងបម្រះតិចៗ តែបុរសដឹងហើយថា នារីកំពុងព្រមព្រៀងក្នុងការទទួលយកស្នេហារបស់អ្នក។

## វគ្គទី១៤

## គូស្នេហ៍លើទន្លេម៉េមប៊ីរ៉ាម៉ូ

ដំណើរពីក្រុងចាយ៉ាពូរ៉ាទៅកាន់កោះស្មៅលឿងមិនមែនជាចម្ងាយផ្លូវឆ្ងាយប៉ុន្មានទេប្រៀបជាមួយការហោះឆ្លងដែនតាំងពីប្រទេសកម្ពុជាមកដល់ឆ្នេរទេសចរបាលី ហើយហួសមកដល់ខេត្តប៉ាពួ ប៉ុន្តែប្រការដែលសំខាន់គឺដូចគ្នានឹងដំណើរទៅកាន់កោះជាច្រើនទៀតរបស់ខេត្តនេះដែរ ចរាចរណ៍ផ្លូវទឹកគឺជាជម្រើសតែមួយគត់។

តាំងពីព្រលឹមស្រាងៗនរៈត្រកូលអ្នកនយោបាយ និងក្រុមជំនិត ព្រមទាំងមានស្រីស្រស់ក្នុងបេះដូងអមដំណើរមកជាមួយផង បានចុះកប៉ាល់ហើយបណ្តែតខ្លួនទៅតាមខ្សែទឹករបស់ទន្លេម៉េមប៊ីរ៉ាម៉ូ Mamberamo Riverដែលជាទន្លេធំបំផុតនៅខេត្តប៉ាពួ ហើយតម្រង់ឆ្ពោះទៅទិសខាងជើង។

កំលោះជាប់ភារកិច្ចធំ ដែលស្រាប់តែជាសះពីរបួសដៃយ៉ាងឆាប់រហ័សដោយសារមានពេទ្យពិសេសព្យាបាលបេះដូងកាលពីយប់នោះ ចាប់ផ្តើមអង្គុយចុះជាមួយកុំព្យូទ័រដោយលែងរវល់ជាមួយបរិយាកាសជុំវិញខ្លួន ផ្ទុយគ្នាស្រលះពីតរុណីរូបល្អដែលបានឆ្លួតចិត្តចំពោះទិដ្ឋភាពដ៏ស្រស់ត្រកាលរបស់ដងទន្លេខៀវស្រងាត់។

ដោយសារឥណ្ឌូណេស៊ី ជាប្រទេសដែលមានគ្របដណ្តប់ដោយផ្ទៃសមុទ្រ តំបន់ទាំងឡាយនៃកោះនេះត្រូវបានខណ្ឌចែកដោយទឹក ធ្វើឲ្យស្ថានភាពរស់នៅរបស់ពលរដ្ឋពីតំបន់មួយទៅតំបន់មួយមានលក្ខណៈពិសេសដាច់ដោយឡែកពីគ្នា។ ចេញពីក្រុងធំ Jayapuraតែបន្តិច មាណវីយើងកាន់តែរំភើប និងស្លុងទៅក្នុងជីវភាពរស់នៅរបស់កសិករដែលដាំដំណាំប៉ប្រះទឹក ព្រមទាំងភូមិនេសាទតូចធំរបស់បព្វជិតសាសនាឥស្លាមក្នុងទិដ្ឋភាពប្រាសចាកទាំងស្រុងទៅនឹងភាពស៊ីវិល័យនាកោះទេសចរបាលី។

កំពុងរំភើបនឹងបរិយាកាសថ្មី ក្រសែភ្នែកនាងក្រឡេកទៅប៉ះនឹងនាយអង្គរក្សស្គមស្រាវដែលរវៀសរវៃ ដើរកាត់តាមកន្សៃកប៉ាល់ឆ្ពោះទៅបន្ទប់ខាងមុខ។ នាងដឹងហើយថាគេកំពុងតម្រង់ទៅរកចៅហ្វាយប្រុសសំណព្វរបស់គេ ដែលនាងទើបតែបានរៀបចំអាហារ និងភេសជ្ជៈដាក់ទៅឲ្យគេនៅទីនោះអម្បាញ់មិញដែរ។

ប៉ុន្តែទឹកមុខនាយអង្គរក្ស ហាក់បីដូចជាបង្ហាញថា គេកំពុងជួបរឿងអ្វីមួយមិនសប្បាយចិត្តច្បាស់ណាស់។ ប្រការនេះធ្វើឲ្យនាងក្រមុំដកចិត្តចេញពីភាពកម្សាន្តសប្បាយមកជាកើតពិភាល់។ រាល់ដង

ឲ្យតែនាយរឿនប្រើទឹកមុខបែបនេះ មិនដែលថាគ្មានបញ្ហានោះទេ ហើយដែលគួរឲ្យបារម្ភបំផុតនោះ គឺថាគ្រប់គ្នាកំពុងអណ្តែតឆ្ងាយពីដីគោកទៅហើយ។

ឌីម៉ាឈានដើរទៅតាមពីក្រោយនាយអង្គរក្សយ៉ាងរហ័សទៅតាមសន្ទុះចិត្តចង់ដឹង។ នាងមកដល់មុខបន្ទប់កញ្ចក់ ល្មមពេលនាយរឿនឈានចូលទៅខាងក្នុងផុតទៅហើយ ប៉ុន្តែសំឡេងបុរសនោះលាន់ជ្រែករបាំងកញ្ចក់មកស្រាលៗ៖

-ខ្ញុំសួរទៅចាយ៉ាពូរ៉ាហើយ គ្មានអ្នកណាបានឃើញថៅកែKen និងបក្សពួកចេញតាមប្រលានយន្តហោះទេ។ ចំណែកប្រភពនៅ Cita Resort និយាយថាពួកគេចាកចេញពីអូតែលតាំងពីព្រលប់ម្សិលម្ង៉ៃ! តើពួកហ្នឹងទៅណាទៅ? ហេតុអ្វីបានជាធ្វើជាទូរសព្ទមកប្រាប់អ្នកប្រុសថា លោករ៉ាទូស្លាប់?

រ៉ាទូបុរសរាងធាត់ក្រអាញដែលជាម្ចាស់វត្ថុបុរាណកាលពីព្រឹកម្សិលនោះ គឺឌីម៉ានៅចំណាំឈ្មោះច្បាស់ណាស់ ពិសេសដោយសារតែស្វែងរកបុរសនោះហើយ បានជារាមនរិន្ទសុខចិត្តវិលត្រឡប់ឡើងទៅសណ្ឋាគារទ្រុឌទ្រោមដោយបន្ទុះនោះវិញ ទាំងខ្លួនរបួសដែលឈាមសស្រាក់។ មិនដឹងថាកាលណោះគេបានជួបជននោះដែរឬយ៉ាងណាទេបានជាភ្លាមៗគេស្រាប់តែសម្រេចចិត្តថាបន្តដំណើរមកកាន់កោះស្មៅលឿង។

ពាក្យថាជននោះស្លាប់ដែលនាយរឿនបានបម្រើបអម្បាញ់មិញ នៅមិនមានទំហំគួរឲ្យភ្ញាក់ផ្អើលស្មើទៅនឹងពាក្យថៅកែKenដែលនាងទើបបានឮនោះទេ។ នារីផ្ទៀងស្តាប់ដោយយកចិត្តទុកដាក់ស្រាប់តែឮរាមនរិន្ទនិយាយមួយ៖

-ពួកហ្នឹងកំពុងនៅស្រុក Sarmiហើយរឿន!

-ថៅកែ Kenទៅដល់ហ្នឹងលឿនម៉េះ?

កេតឌីម៉ាចំហមាត់ឆ្ងល់នៅពេលឮបុរសមានអំណាចរំលឹកពីឈ្មោះប្រុសដែលបានធ្វើឲ្យនាងឈឺចាប់។ នាងនៅស្ងៀមត្រៀមចាំស្តាប់បន្តដោយសារគិតមិនលេចថាហេតុអ្វីចេញមកឆ្ងាយដល់ថ្នាក់នេះហើយគេនៅមានសាច់រឿងត្រូវពាក់ព័ន្ធគ្នាទៀត។ ភ្លាមនោះនាងបើកភ្នែកធំៗ ព្រោះថាល្ងង់យ៉ាងណា មកដល់ពេលនេះនាងមុខតែគិតយល់ហើយថា បុរសទាំងពីរដែលសុទ្ធសឹងតែមិនទាន់បានទទួលតន្ទប្បដិមាមកដល់ដៃ មានរឿងអីដែលថាការប្រឈមមុខគ្នារបស់ពួកគេអាចនឹងត្រូវបញ្ចប់នោះ? នាងរវេភ្នែករិះគិត។ បើតាមសម្តីនាយអង្គរក្ស ដែលបម្រើបអម្បាញ់មិញមានន័យថាសុភាព

បុរសក្លែងក្លាយដែលជាពាណិជ្ជករដែកថែប បានបាត់ខ្លួនពីក្រុងធំចាយ៉ាពូរ៉ា ហើយនៅសុខៗគេបែរជាទូរសព្ទមកប្រាប់ថា នាយរ៉ាទូម្ចាស់វត្ថុនោះស្លាប់ហើយ។ គេកំពុងលេងល្បិចអីទៀតហើយ?

គេចង់រារាំងរាមនរិន្ទមិនឲ្យតាមទៅរកនាយរ៉ាទូដល់កោះស្មៅលឿងទេដឹង?

នាងស្ទុះរឹងរុញទ្វារចូលទៅខាងក្នុងដោយតក់ក្រហល់ ធ្វើឲ្យនាយអង្គរក្ស និងរាមនរិន្ទបើកភ្នែកធំៗសម្លឹងមកដោយភ្ញាក់ផ្អើល។ ប៉ុន្តែបន្ទាប់មកអ្នកដែលត្រូវភ័យបះសក់ គឺរូបនាងដោយសារនាងបានប្រទះឃើញរាមនរិន្ទមិនមែននៅតែជាមួយកុំព្យូទ័រ ដូចដែលនាងលើកអាហារចូលមកឲ្យគេអម្បាញ់មិញទេ ប៉ុន្តែឧបករណ៍អេឡិចត្រូនិកជាច្រើនទៀតកំពុងស្ថិតនៅចំពោះមុខគេ។

គ្រាន់តែឃើញម្រាមដៃគេដែលកំពុងគាំងចលនានៅលើKeyboardក៏នាងអាចស្មានដឹងបានដែរថាគេកំពុងរវល់បំពេញការងារយ៉ាងមមាញឹក។ ហើយដែលនាងសម្រុកចូលទាំងទទឹងទិសមកនេះ គឺកំពុងធ្វើឲ្យគេ និងនាយរឿនទៅជាស្រឡាំងកាំង។

នាងដឹងថាមិនសមហើយ ប៉ុន្តែនាងចាំបាច់ត្រូវតែនិយាយ៖

-លោកប្រុសរាម! រឿន! អ្នកទាំងពីរកុំជឿគេ! ចៅកែ Kenនោះមានល្បិចច្រើនណាស់! បើគេប្រាប់ថាលោករ៉ាទូស្លាប់! ប្រាកដណាស់គឺគេកុហកទេ!

រឿនរេភ្នែកសម្លឹងប្រតិកម្មចៅហ្វាយ ក្នុងខណៈទឹកមុខរាមនរិន្ទទៅជាអស់សំណើច។ គេនិយាយតិចៗទៅកាន់ស្រីស្អាតដែលអើតមុខមកជាមួយនឹងសកម្មភាពប្រផាប់ប្រភីង។

-ចូលមកឌីម៉ា!

នារីងាកមើលប្រតិកម្មអង្គរក្សរឿន នាងឃើញគេធ្វើដូចធម្មតាទើបនាងឈានជើងចូលទៅតិចៗ។ ធីតាអង្គុយចុះនៅទល់មុខបុរសទាំងពីរ ល្មមពេលរាមនរិន្ទសួរស្រាលៗ៖

-អីក៏ភ័យម្ល៉េះ?

នារីបង្ហាញម៉ូតសម្រួលទឹកមុខនិយាយតិចៗតបដោយមិនហ៊ានសម្លឹងមុខអ្នកទាំងពីរ៖

-ព្រោះថាចៅកែKenមានល្បិចច្រើន! ខ្ញុំមិនចង់ឲ្យពួកលោកចូលអន្ទាក់គេ!

រាមនរិន្ទយល់ថាដោយសារកេតឌីម៉ាខឹងចិត្តដែលត្រូវលំអងបោកប្រាស់ ហើយចុងក្រោយក៏ដឹងថាលំអងជាសង្សារលួចលាក់ ជាមនុស្សក្រុមតែមួយជាមួយKen ទើបបានជានាងខឹងស្អប់ហើយសស្លើតសស្លក់ចូលមកដោយច្រាស់ច្រាលបែបនេះ។ តែគេមិនដឹងទេថា នាងមិនត្រឹមតែត្រូវលំអង

បោកប៉ុណ្ណោះទេ សាមីខ្លួននាងផ្ទាល់ក៏ត្រូវបានពាណិជ្ជករដែកថែបបោកយកបេះដូង និងប្រើប្រាស់នាងផងដែរ។

គេងាកទៅរកមនុស្សជំនិតហើយបង្គាប់៖

-រឿន! ឲ្យគ្នាយើងចេញដំណើរទាំងថ្ងៃទាំងយប់! ពួកនោះទៅដល់កោះស្មៅលឿងមុនយើងហើយ! គេច្បាស់ជាបង្ករឿងឲ្យឈឺក្បាល!

នាយរឿនក្រោកចាកចេញរឹង ដោយសារនាយក៏ទទួលស្គាល់ថាការងារនេះបន្ទាន់ណាស់។ បុរសត្រកូលខ្ពស់បិទកុំព្យូទ័រ ហើយងាកមកញញឹមដាក់នាង។ នារីដែលអង្គុយរិះគិតអស់បន្តិចហើយនោះ និយាយឡើងវិញតិចៗដោយអៀនខ្មាស៖

-សូមទោស!

រាមនរិន្ទញាក់ស្មាជាសញ្ញាងឿងឆ្ងល់។ កេតឌីម៉ាបន្តវាចា៖

-សូមទោសដែលរត់ចូលមកទទឹងទទែង រំខានពេលលោកធ្វើការ!

បុរសលង់ស្នេហ៍បង្ហាញភាពស្រស់ស្រាយលើផ្ទៃមុខ ទោះបីជានារីដឹងថាតាមពិតគេហត់នឿយនៅពីមុខកុំព្យូទ័រជាង៣ម៉ោងហើយក្ដី។ គេនិយាយដោយលូកដៃត្រកងចង្កេះនាងមកអង្គុយកាន់តែកៀក។ មាត់វាចាមួយៗ៖

-ចប់ហើយទេតើ! មានការងារអីទៀត?

ស្រស់ស្រីនៅតែមិនអស់ចិត្ត នាងស្រដីក្នុងពេលបុរសលើកទឹកក្រេបក្អឹកៗ៖

-តែនៅសុខៗស្រាប់តែគេទូរសព្ទមកប្រាប់ថាលោករ៉ាទូនោះស្លាប់ លោកប្រុសរាមកុំជឿគេឲ្យសោះ!

រាមនរិន្ទឆ្លើយវិញធ្វើហី៖

-អញ្ចឹងហើយបានជាចង់ដឹងថាគេឥឡូវកំពុងនៅឯណា!

ស្រីស្អាតទៅជាងឿងឆ្ងល់វិញ។ នាងសួរតប៖

-ចុះមិញនេះក្រែងលោកថាគេទៅដល់ស្រុកSarmiមែនទេ? លោកដឹងមកពីណា?

បុរសអភិជនញញឹមចង្អុលទៅកុំព្យូទ័រធ្វើហី ក្នុងពេលនាងរភ្នែកសម្លឹងឧបករណ៍ទាំងនោះដោយយកចិត្តទុកដាក់។ រំពេចនោះនាងស្រាប់តែគិតយល់ ហើយលើកដៃខ្ទប់មាត់ដោយភិតភ័យ។ រាម

នរិន្ទរក្សាអាកប្បកិរិយាធម្មតា គេគិតក្នុងចិត្តថាកេតឌីម៉ាក៏មិនមែនល្ងង់ពេកនោះដែរ។ ក្នុងពេលគេប្រមូលសម្ភារៈដាក់ទៅក្នុងវ៉ាលិស ហើយចាប់ដកទូរសព្ទដៃមួយចេញពីខ្សែដែលកំពុងភ្ជាប់ទៅនឹងកុំព្យូទ័រ។ សំឡេងនាងលាន់មកខ្សាវៗហាក់ភិតភ័យៈ

-លោកជា Hackerមែនទេ?

គេបើកទូរសព្ទមួយផ្សេងទៀត មាត់ឆ្លើយតបបណ្ដើរ ដៃលូករាវចុចទូរសព្ទបណ្ដើរៈ

-ភ្ញាក់ផ្អើលម៉េះ?

គេងៀងភ្នែកមករកផ្ទៃមុខសស្លាំងរបស់តរុណី រួចញញឹមតិចៗជាមួយវាចាបន្តៈ

-បើមិនធ្វើអញ្ចឹងម៉េចរកទីតាំងគេឃើញទៅ?

នារីនិយាយតបតិចៗវិញៈ

-តែលោក....មិន...មិន...ដូចជាHackerទេ!

ភាគទី៣០

បុរសអភិជនមិនស្ដីតែគេក្រោកឈរឡើងដោយស្ទួយនាងមកជាមួយគ្នាផង។ ធីតាសម្លឹងទៅអេក្រង់ទូរសព្ទដែលគេកំពុងតែបង្ហាញនាង។ សម្ដីគេលាន់មកមួយៗៈ

-កន្លែងនេះគឺSarmi! ហើយទៅដល់កន្លែងនេះ គឺកោះស្មៅលឿង។ ពួកហ្នឹងទៅដល់ Samiមានន័យថាគេចេញមុនយើងមួយជំហាន! គេប្រហែលក្រោកចេញទូកតាំងពីយប់ហើយ!

នឹកដល់សុភាពបុរសក្លែងក្លាយនោះ កេតឌីម៉ាហាក់ហេងហាងក្នុងចិត្ត។ នាងយល់ថាខ្លួនឯងបានធ្វើខុសធំមួយ គឺការដែលនាំដំណឹងពីរាមនរិន្ទឲ្យគេ រហូតដល់ពាណិជ្ជករដែកថែបដ៏កំហូចអាចមានតម្រុយមកដល់ចាយ៉ាពូរ៉ា ហើយពេលនេះឈានទៅកោះស្មៅលឿងមុនរាមនរិន្ទមួយជំហានទៀត ប្រសិនបើមិនអាចឃាត់គេក្នុងការដណ្ដើមតន្ទប្បដិមាពីរាមនរិន្ទបានទេ នាងមុខតែមិនស្ងប់ចិត្តសោះឡើយ។

ធីតាងើបមុខសួររាមនរិន្ទវិញភ្លាមៈ

-ចុះលោកគិតធ្វើម៉េចទៀត?

រាមនរិន្ទបិទទូរសព្ទ ហើយបណ្ដើរនាងចេញទៅក្រៅ។ នរៈក្រសោបធីតារូបល្អក្នុងរង្វង់ដៃដោយបំបែរមុខសម្លឹងទៅពន្លឺពណ៌មាសព្រិចៗលើដងទន្លេជាឥទ្ធិពលចុងក្រោយនៃព្រះអាទិត្យរៀបអស្ដង្គត។

-បងត្រូវតែយករបស់នោះ! ទោះយ៉ាងណាក៏ដោយ!

គេនិយាយស្រាលៗក្បែរត្រចៀកនាង ប៉ុន្តែវាអាចមានអត្ថន័យឲ្យនាងទទួលអារម្មណ៍ថាចម្លែក។ ហេតុអ្វីរង្វង់ដៃគេពេលនេះកក់ក្ដៅម្ល៉េះហើយពាក្យ "បង" ដែលគេទើបតែប្រើអម្បាញ់មិញពីរោះយ៉ាងនេះ?

"ឯងមិនសមថាទើបតែខូចចិត្តពីម្សិល ហើយមកងាកស្រលាញ់ប្រុសផ្សេងភ្លាមនៅថ្ងៃបន្ទាប់ទេដឹងឪម៉ា?" នាងសួរខ្លួនឯងក្នុងចិត្ត។ ម្រាមទាំង១០របស់បុរសរូបសង្ហាលូកមកក្រសោបលើម្រាមទាំង១០របស់នារីតូចតន់។ នាងនិយាយតិចៗដោយមិនងាកទៅសម្លឹងមុខគេទេ៖

-ហេតុអ្វីម្នាក់ៗចង់បានរបស់នោះម្ល៉េះ?

បបូរមាត់នាយដែលដាក់មកលើស្មានាងបង្ហើបតិចៗល្មមតែឮបានពីរនាក់៖

-វាជាអាថ៌កំបាំងរាប់ពាន់ឆ្នាំរបស់ខ្មែរយើង! បុព្វបុរសគ្រួសារបងមានជំនឿតៗមកថា វត្ថុនោះអាចនាំយើងទៅដល់កន្លែងមួយដែលអាចរកឃើញសម្បត្តិនានាមានតម្លៃជាកេតនភណ្ឌជាតិតាំងពីបុព្វកាលសម័យ! របស់ទាំងនោះបានបាត់ដំណឹងតាំងពីរជ្ជកាលសង្គ្រាម ប៉ុន្តែនៅតែមានពាក្យតំណាលមកថា វាត្រូវបានថែទាំ និងលាក់ទុកត្រឹមត្រូវពីអ្នកស្នេហាជាតិជាន់មុន ដែលសំខាន់គឺទីតាំងរបស់វាត្រូវបានបង្កប់នៅក្នុងវប្បធម៌សម្បត្តិមួយ ឈ្មោះថាឥន្ទប្បដិមា នរាធិបតិន្ទ! បើវត្ថុនេះធ្លាក់ដល់ដៃជាតិដទៃ ហើយត្រូវបានគេរកឃើញពីអាថ៌កំបាំងមហាសាលរបស់វា យើងគឺជាអ្នកខាតបង់!

នាងក្រមុំដៀងភ្នែកសញ្ជឹងគិត។ "កេតនភណ្ឌ" ដែលគេរំលឹកនោះជាអ្វីខ្លះបានជាពាណិជ្ជករសម្បូរល្បិចដូចនាយKenក៏សុខចិត្តប្រើកលសព្វយ៉ាងដើម្បីតែវត្ថុទាំងនោះ។

បង្អង់បន្តិចកូនប្រុសអ្នកតំណាងរាស្ត្របន្តបន្ថែម៖

-នៅមានមនុស្សជាច្រើនទៀតដែលបានដឹងពីវត្ថុមានឥន្ទប្បដិមា ប៉ុន្តែអាថ៌កំបាំងរបស់វត្ថុនោះត្រូវបានគេយល់ឃើញប្លែកៗពីគ្នា។ មនុស្សមួយចំនួនគិតថា ឥន្ទប្បដិមាជាផែនទីទៅរកកំណប់មហាសាលដែលបុព្វបុរសបានលាក់ទុកមុនពេលចលាចលដោយសឹកសង្គ្រាម។ អញ្ចឹងហើយ បានជា

គេនាំគ្នាចំណាយពេលវេលា និងកម្លាំងដើម្បីបានគ្រប់គ្រងឥន្ទប្បដិមា។ ប៉ុន្តែអ្វីៗគ្រាន់តែជាពាក្យចចាមអារ៉ាមតែប៉ុណ្ណោះ។ ការពិត គឺឥន្ទប្បដិមាមិនមានតម្លៃជាទ្រព្យសម្បត្តិទេ តែអត្ថន័យរបស់វាគឺលើសពីនេះ។

ទ្រាំមិនបានស្រីស្រស់ ពោលសួរវិញដោយងឿងឆ្ងល់៖

-ចុះហេតុអ្វីលោកជឿថារបស់ដែលលោកវ៉ាទូមាននោះជារបស់ពិត?

បុរសឱនមកសម្លឹងមុខស្រីស្អាត គេសួរវិញធ្វើព្រងើយ៖

-ចុះមានត្រង់ណាដែលគួរតែសង្ស័យថាមិនពិត?

នារីរិះគិតបន្តិចទើបឆ្លើយតបវិញ៖

ទោះមានទំនុកចិត្តខ្លួនឯងកម្រិតណា ក៏វត្ថុនោះលោកមិនទាន់ទាំងបានឃើញរូបរាងវាផងទេ? គេអាចថាប្រើល្បិចបន្លំក៏ថាបាន។ សូម្បីពិធីដេញថ្លៃកាលពីម្សិលចម្លែកផង សោះកក្រោះផង! លោកមិនយល់ថាម្នាក់មកពីកោះស្មៅលឿងហ្នឹងមានចរិតចម្លែកៗទេ?

រាមនរិន្ទចោលភ្នែកសម្លឹងទៅត្រើយខាងកើត។ ស្រមោលរាត្រីកាលចាប់ផ្តើមគ្របដណ្តប់បន្តិចៗម្តងៗសាជាថ្មី។ គេនិយាយបន្តដោយមានស្រីស្រស់ក្នុងរង្វង់ដៃ៖

-របស់នោះពិតក៏ដោយមិនពិតក៏ដោយ តែសម្តីម្នាក់នោះបញ្ជាក់ថា គេដឹងរឿងទាក់ទងជាមួយឥន្ទប្បដិមាច្រើនណាស់។ វត្ថុក្នុងក្រណាត់ក្រហមកាលពីម្សិលមិញអាចថាមិនមែនជារបស់ពិត ប៉ុន្តែម្នាក់នោះប្រាកដជាធ្លាប់ដឹងឮរឿងនេះ។ គេអាចជាខ្សែរយៈដ៏សំខាន់មួយនៅទីនេះ។ ពីមុនមកយើងដឹងតែត្រឹមថា ឥន្ទប្បដិមាបានរសាត់មកដល់ឥណ្ឌូណេស៊ី ហើយបាត់ដំណឹងសូន្យឈឹងនៅខេត្តប៉ាពួ។ ពេលនេះមានគេចេញមុខមកនិយាយថាគេមានរបស់ក្នុងដៃ បើយើងមិនចាប់អារម្មណ៍ក៏មិនកើតដែរ!

ទោះបីទទួលស្គាល់ថា សម្តីគេសមហេតុផល និងទទួលស្គាល់ថារាល់ការព្យាយាមអាចចាប់ផ្តើមពីចំណុចតូចបំផុតមួយ តែកេតឌីម៉ានៅតែព្យាយាមដេញសួរ៖

-តែព្រឹកម្សិលមិញ លោកវ៉ាទូនោះនិយាយថារបស់ដែលគាត់មាននោះ គឺមានប្រវត្តិមកពីប្រទេសឡាវទេ!

រាមនរិទ្ធហាក់មិនចម្លែកចិត្តអ្វីចំពោះចម្ងល់នេះសោះ។ គេបង្វែរនាងមកប្រឈមមុខនឹងខ្លួន រួចនិយាយតបសំនួរស្រីស្អាត៖

-តន្ទប្បដិមាមានប្រវត្តិចន្លោះរវាងឆ្នាំ៨១០-៨៤៥គ.ស គឺស្ថិតនៅក្នុងសម័យចេនឡា! ចំណែកឯកសារជាច្រើនអះអាងថាចេនឡាដីគោកមានព្រំប្រទល់ឆ្ងាយរហូតដល់ស្រុកលាវ ដូច្នេះប្រសិនបើរបស់ដែលលោកវ៉ាទូមាន ពិតជាមានប្រភពមកពីប្រទេសឡាវដូចគាត់ថាមែនហើយ គាប់ជួនមានឈ្មោះដូចគ្នាម្លឹងៗ អាចថារបស់មិនពិតដែរ?

អ្នកប្រុសសម្លឹងផ្ទៃមុខដ៏ស្រស់ស្អាតនៃតរុណីឱម៉ាមើលមកអ្នកវិញ។ ទោះបីយ៉ាងណា ក្រសែភ្នែកដែលមិនធ្លាប់មានពីមុនមកនេះ មិនបាច់និយាយក៏អ្នកអាចស្មានដឹងថា នាងកំពុងស្ញប់ស្ញែងអ្នក។

អ្នកញាក់ចិញ្ចើមសម្លឹងមុខនាង៖

-ឆ្ងល់អីទៀត?

ឱម៉ាកាន់តែបង្ហាញភាពសង្ស័យតាមរយៈកែវភ្នែក។ នាងនៅស្ងៀមមិនតបនឹងសំនួរនាយភ្លាមៗ ប៉ុន្តែបន្ទាប់មកនាងបន្ទន់សំឡេងពោលសួររាមនរិទ្ធមួយៗ៖

-ម៉េចក៏លោកនិយាយរឿងអស់នេះប្រាប់ខ្ញុំ?

នរៈសង្ហាសម្លឹងមុខនាងដោយញញឹម។ គេហាក់មានចេតនាបង្អួតភាពជាបុរសដែលប្រកបដោយភាពទាក់ទាញលើផ្ទៃមុខ។ ប៉ុន្តែគេនៅតែមិនឆ្លើយរហូតដល់នាងសួរមកបន្ត៖

អត់ខ្លាចខ្ញុំធ្វើឲ្យបែកការទេ?

នាងនិយាយបណ្ដើរ ឯចិត្តកំពុងក្ដុកក្ដួលបណ្ដើរ។ គេកាន់តែបើកចំហ នាងក៏កាន់តែស្ដាយក្រោយចំពោះកំហុសខ្លួនឯង។ នាងយល់ថា វាហាក់ដូចជាយឺតពេលណាស់ដែលទើបនឹងដឹងថា គេមិនមែនចង់បានខ្លួនប្រាណនាងប្ដូរនឹងលុយកាក់ គេមិនបានចាប់ជំរិតលំអង ហើយសំខាន់គឺគេមិនបានស្វែងរកតន្ទប្បដិមាដើម្បីទ្រព្យសម្បត្តិទេ។

នាងឈ្ងោកមុខមកវិញដោយទុក្ខព្រួយ។

មីងកុលាបតាំងពីមុនមក បាននិយាយប្រាប់នាងហើយថា រាមនរិទ្ធមិនមែនជាមនុស្សអាក្រក់ទេ ប៉ុន្តែដោយសារថាគាត់ធ្លាប់កុហកនាងច្រើនពេករហូតដល់ពេលនេះគាត់និយាយពិតម្ដង នាងលែងជឿតែម្ដង។

-មនុស្សនៅជាមួយគ្នា ត្រូវទុកចិត្តគ្នា! មែនអត់?

សំឡេងគេលាន់មកដំណាលនឹងការលូកដៃក្រសោបម្រាមតូចតន់ទាំង១០នៃនារីរូបល្អដែលនៅចំពោះមុខមកថើបថ្នមៗ... ធ្វើឲ្យឌីម៉ាទៅជាភ័ន្តភាំង... នាងបានត្រឹមនៅស្ងៀមងើបមុខសម្លឹងគេ... តែក៏មិនហ៊ានដកដៃចេញវិញដែរ ។...

រាមនរិន្ទដកដៃនាងចេញពីច្រមុះ... នារីប្រទះឃើញសេចក្តីអាណិតពិតៗឥតក្លែងក្លាយអណ្តែតចេញពីកែវភ្នែកទាំងគូ នៃបុរសអភិជនវ័យក្មេង... បបូរមាត់គេញញឹមមករកមាណវី... ប្រកបដោយស្នាមញញឹមគួរឲ្យកក់ក្តៅក្នុងចិត្ត... ផ្ទៃមុខស្រស់សង្ហារ និងមានអំណាចដែលនៅកៀកក្បែរខ្លួនបង្កើយ... បានធ្វើឲ្យឌីម៉ាមានអារម្មណ៍ថា... បើនៅសម្លឹងគេ... ទទួលយកទឹកមុខផ្អែមល្ហែមរបស់គេទៀត...នាងមុខតែបាក់ចិត្តលើគេមិនខាន... ។

នាងប្រុងងាកចេញគេចពីខ្សែភ្នែកគេ ក្នុងពេលដែលបេះដូងកំពុងលោតខុសចង្វាក់ តែត្រូវនរិន្ទទាញត្រឡប់មកវិញជាមួយប្រយោគស្រាលៗដោយសម្លឹងនាងមិនដាក់ភ្នែកផង ៖

-ឌីម៉ា!...

តរុណីនៅរង់ចាំស្តាប់សំដីគេ...តែមិនឮគេវាចាបន្តទៀតសោះ ទើបមុខសម្លឹងគេសាជាថ្មី... ម្តងណេះនាងត្រូវពន្លឺភ្នែករាមនរិន្ទ ទាក់ទាញចិត្តលែងងាកមុខចេញកើតហើយ... ព្រោះ...នាងដឹងថា... នាងចង់សម្លឹងគេ...ចង់មើលភ្នែកមួយគូនេះ... ចង់មើលឲ្យឆ្លុះដល់ចិត្តថាគេកំពុងគិតពីនាងយ៉ាងដូចម្តេច...ហើយមានអារម្មណ៍ថា...ចង់ស្តាប់សម្តីគេ... ចង់ឲ្យគេនិយាយពាក្យល្អៗមករកនាងដូច្នេះជារៀងរហូត... ។...

- ឈប់គិតអីអាក្រក់ៗ! ឈប់ធ្វើមុខស្លូត មុខស្រពោន! ឈប់ខ្វល់ពីអ្នកនេះអ្នកនោះច្រើនពេកដល់ថ្នាក់ស្មុគខ្លួនឯងទៀត! ឮអត់?

បេះដូងមាណវីត្រូវគេបញ្ជាឲ្យលោតញាប់ដោយអំណាចនៃអារម្មណ៍រំជើបរំជួល... ជាមួយនឹងពាក្យស្រាលៗ តែមានអត្ថន័យដូចអាជ្ញាសឹក។ ក្នុងមួយខណៈដែលនាងរកពាក្យអ្វីឆ្លើយតបទៅរាមនរិន្ទមិនបានមួយម៉ាត់សោះនោះ... នាងឮសូរស័ព្ទស្រាលៗរបស់គេពោលបន្ថែមក្បែរត្រចៀក៖

-ហើយកុំរៀនតាមរឿនហៅគ្នាអ្នកប្រុស លោកប្រុស! ស្តាប់ទៅសាំញ៉ាំ!

គេនៅស្ងៀមបន្តិច ទើបនិយាយស្រាលៗទៅរកនាង៖

- មនុស្សនៅជាមួយគ្នា... ត្រូវចេះប្រើពាក្យល្អៗសម្រាប់គ្នា ...!...

ពាក្យសម្ដីគេមានអត្ថន័យណាស់ បើសម្រាប់មនុស្សពីរនាក់ដែលភពប្រសព្វគ្នា ដោយមនោសញ្ចេតនាផុសពីបេះដូង តែសម្រាប់ឪម៉ាពាក្យមួយឃ្លានេះបានរត់ចេញពីចរន្តគំនិតនាងដោយប្រវត្តិ ថារស់នៅជាមួយគ្នាមែនតែដោយសារតែកលល្បិចរបស់អ្នកផ្សេងប៉ុណ្ណោះ។

នៅពេលបេះដូងលែងរឹងមាំ ដោយសារទទួលទុក្ខវេទនាព្រោះស្នេហាក្បត់ចិត្ត នារីយល់ថាបើកាន់តែនាងទទួលពាក្យល្អពីកូនប្រុសអ្នកនយោបាយច្រើនពេក នាងនឹងលង់ចិត្តហើយបើនាងជ្រុលចិត្តស្រឡាញ់គេនោះ ចុងក្រោយគឺនាងខ្លួនឯងដែលត្រូវពិបាក។

សូររើបម្រះប៉ះក្ដាកម្រាលកប៉ាល់លាន់មកទាញអារម្មណ៍ប្រុសស្រីទាំងទ្វេឲ្យដកចេញពីភាពអណ្ដែតអណ្ដូង។ រាមនរិន្ទបែរខ្នងសម្លឹងទៅរកប្រភពសំឡេងក្នុងពេលដែលក្រសែភ្នែកកេតឪម៉ាដែលឈរក្នុងបែរមុខទៅទីនោះស្រាប់ប្រទះឃើញរូបរាងមនុស្សម្នាក់កំពុងរមួលរនប ហាក់ឈឺចាប់ដោយសារអ្វីម៉្យាង។

បុរសដែលនាងស្គាល់ច្បាស់ថាជាអង្គរក្សឈ្មោះបរទេសកំពុងកាច់ដៃជើង និងទ្រេតខ្វាយៗទៅរកបង្កាន់ដៃកប៉ាល់ ហើយបបូរមាត់ស្លេកស្លាំងរបស់គេហៀរហូរកក្លាក់នូវពពុះពណ៌សស្រដៀងទៅនឹងទឹកមាត់។

ឪម៉ាលើកដៃខ្ទប់មាត់ដោយរន្ធត់ ព្រោះចំពោះកែវភ្នែកនាង នាយBirdហាក់កំពុងប្រកាច់ប្រកិន និងបាត់សតិដោយការឈឺចាប់អ្វីមួយ ហើយភ្នែកទាំងគូរបស់គេស្លីទៅលើដូចមនុស្សប្រុងដាច់ដង្ហើម។

ឥតស្ដីមួយម៉ាត់ រាមនរិន្ទបោះជំហានយ៉ាងរហ័សសំដៅទៅរកមនុស្សក្រោមបង្គាប់ដែលកំពុងប្រកាច់ទាំងឈរ ប៉ុន្តែនាយBirdមិនអាចរង់ចាំបានទេ ដៃនាយដែលខំតោងបង្កាន់ដៃដើម្បីជួយខ្លួនឯងជាចុងក្រោយបានកាច់ទៅក្រោយធ្វើឲ្យរបូតពីជំហរហើយរមួលខ្លួនក្រឡាស់ធ្លាក់ទៅក្នុងទឹកលាន់សូរប្រូង។

បេះដូងឪម៉ាស្ទើរឈប់លោត ចំណែករាមនរិន្ទស្រែកហៅកងជំនួយលាន់ខ្ទរះ

-រឿន! គង់!

នាយថៅហ្វាយឈ្មោកដោះខ្សែក្រវាត់ និងខោខូវប៊យចេញ រួចលោតប្រូងទៅតាមនាយBirdដែលកំពុងលិចស្រឹមទៅក្នុងទឹក។

អង្គរក្សរឿន និងនាយគង់ ព្រមទាំងមនុស្សម្នាផ្សេងៗរត់ស្រុះគ្នាមកដល់ តែពួកគេបានឃើញតែនារីរូបល្អដែលស្ទុះទៅតោងបង្កាន់ដៃសម្លឹងទៅក្នុងទឹកដោយទឹកមុខរន្ធត់។ គ្រាន់តែក្រឡេកឃើញខោ និងខ្សែក្រវាត់ចៅហ្វាយ នាយរឿនស្ទុះរឹងទៅស្រាយពោងពោះវៀនឡានដែលព្យួរចោលក្បែរបង្កាន់ដៃ បោះទៅក្នុងទឹក រួចលោតប្រូងទៅតាមពីក្រោយនាយចៅហ្វាយ។ នាយគង់ និងមនុស្សពីរបីនាក់ទៀតលោតទៅបន្តបន្ទាប់គ្នា។

ស្រីបង្ហាញម៉ូដហាក់ធូរទ្រូងជាងមុនព្រោះឃើញមនុស្សម្នាចុះទឹកច្រើន ប៉ុន្តែនៅក្រោមផ្ទៃមេឃដែលប្រែទៅជាពណ៌ប្រផេះស្រអាប់ដោយខ្វះពន្លឺព្រះអាទិត្យ នារីនៅតែរកមិនឃើញទីតាំងអ្នកប្រុសធំគ្រួសារអ្នកតំណាងរាស្ត្រដែលហាក់ទៅមុននេះឡើយ ធ្វើឲ្យនាងទៅជាថប់ដង្ហើមស្ទើរស្ទះ។

នាងស្រែកតាមពីក្រោយអង្គរក្សខ្ពស់ស្រាវដែលកំពុងហែលរេរកមើលចៅហ្វាយប្រុសដោយស្ទាត់ជំនាញ៖

រឿន! លោកប្រុសរាម លោតទៅមុននេះហើយ!

ដោយសារតែបុរសមាឌមាំដែលទើបសាសងស្នេហាជាមួយនាងអម្បាញ់មិញបានលិចបាត់ទៅក្នុងទឹកតាមពីក្រោយនាយBirdនោះ នារីស្រាប់តែចាប់អារម្មណ៍ថាគេអាចនឹងលង់ទឹកថែមម្នាក់ទៀតបន្តពីកូនចៅដែលប្រកាច់ពេញទំហឹង។ សំនួរមួយលេចភ្លែតក្នុងអារម្មណ៍ធីតាយើងដែលកំពុងបើកភ្នែកគ្រលួង "ម៉េចក៏គេលោតចុះទៅតាមកូនចៅហើយលិចបាត់ឈឹងក្នុងផ្ទៃទឹកយូរដល់ម្លឹង? ហើយចុះបើគេលែងអណ្តែតមកវិញ? ហើយចុះម៉េចក៏យើងមានអារម្មណ៍ភ័យពីគេខ្លាំងម្លេះ? ក្រែងយើងស្អប់គេណាស់ពីមុនមក?"

សម្រែកស្រែកហៅកងរំពងរបស់កងអង្គរក្សលាន់មករញ្ជួយពេញចិន្តានារីដែលកំពុងពិភាល់គិត៖

-អ្នកប្រុស! អ្នកប្រុស?

នៅក្នុងវិនាទីដែលរំលងទៅយឺតៗ នាងក្រមុំទទួលស្គាល់ថាបេះដូងដែលថប់ៗប្រែជាលោតកាន់តែញាប់ ហើយដៃជើងចាប់ផ្តើមញ័រពិបាកទប់ជំហរ។ នាងស្រាប់តែយល់ថាបុរសមានអំណាចគិតខ្លីណាស់ដែល លោតទឹកទៅទាំងអញ្ចឹង ព្រោះថានាយអាចនឹងត្រូវអង្គរក្សដែលប្រកាច់បាត់ស្មារតីនោះតោងរហូតដល់ស្លាប់ទាំងពីរនាក់ផងក៏មិនដឹង។

ប៉ុន្តែភ្លាមនោះដែរ រាមនរិន្ទអណ្តែតមកវិញដូចអភិនីហារ។ ដៃស្តាំគេដែលទើបតែរងរបួសកាលពីម្សិលបានសណ្តោងទាញសក់ក្បាលនាយBirdមកជាមួយផង។ កាយវិការមុជទឹកគេហាក់ស្ទាត់

ជំនាញ ជាងការគិតរបស់នាងឆ្ងាយ ដែលធ្វើឲ្យនាងកាត់យល់ថា កាលដែលគេបាត់ខ្លួនទៅក្នុងទឹកយូរយ៉ាងនេះប្រហែលដោយសារនាយ Birdលិចទៅជ្រៅពេក។

ក្រុមកងការពារដទៃហែលទៅក្បែរថៅហ្វាយប្រុសហើយជួយស្រង់នាយBirdមកលើវិញ ចំណែកកេតឱម៉ាត្រលប់ចូលទៅក្នុងកប៉ាល់ ហើយចេញមកវិញជាមួយនិងកន្សែងពោះគោក្នុងដៃ។

រាមនរិន្ទទទួលកន្សែងពីនាងក្នុងខណៈដែលមនុស្សឯទៀតកំពុងសស្រាក់សស្រាំក្នុងការជួយសម្រួលដង្ហើមនាយBirdសាជាថ្មីដោយសារនាយបង្កប់ខ្លួនលែងធ្វើទុក្ខដោយសារជម្ងឺប្រកាច់ តែបែរជាឈ្លក់ទឹកសន្លប់ឈឹង។

មិនយូរប៉ុន្មាន នាយBirdបម្រះ ហើយក្អួតទឹកចេញតាមមាត់មុនពេលដកដង្ហើមដូចប្រក្រតីវិញ ធ្វើឲ្យមនុស្សម្នារួមទាំងឱម៉ាផងធូរទ្រូងខ្សាក។

-យូរហើយមិនដែលដឹងថាឯងកើតឆ្កួតជ្រូកអាBird? (នាយគង់និយាយឮៗ)

រាមនរិន្ទបែរក្រោយត្រឡប់ចូលទៅក្នុងកប៉ាល់វិញ។ ចំណែកនាយរឿនដើរមកកាត់នារីបង្ហាញម៉ូតដែលនៅឈរទ្រឹងដោយភ័យមិនទាន់បាត់។ គេនិយាយមួយៗទៅរកនាង៖

-វាអស់អីហើយ! គួរចូលទៅមើលអ្នកប្រុសល្អជាង! ដៃគាត់មិនទាន់ជាផងឥឡូវត្រូវម៉ោទទឹកបាត់ហើយ!

ស្រីស្អាតងក់ក្បាលតិចៗដោយមិនចេញស្តី តែតាមពិតនាងដឹងថាដៃបុរសនោះមិនអីទេ ព្រោះគេដូចជាគ្មានបញ្ហាផងតាំងពីនៅជាមួយនាងយប់មិញនៅJayapura ម្ល៉េះ។

នាងសម្លឹងទៅរកនាយBirdបន្តិចរួចទើបចាកចេញទៅ។

ភាគទី៣១

មកដល់ខាងក្នុងកាត់តាមបន្ទប់ចម្អិនអាហារ នាងឃើញបុរសសង្ហាកំពុងកាន់ចាន និងដួសបាយខ្លួនឯងដោយរុំកន្សែងនៅចង្កេះនៅឡើយ។

-លោកត្រូវការអីប្រាប់ខ្ញុំបានហើយ!

នាងទទួលចានមកដួសរៀបចំអាហារពេលយប់ឲ្យគេព្រោះមើលទៅការជ្រមុជទឹក និងអត់ដង្ហើមយូរធ្វើឲ្យគេអស់កម្លាំងជាខ្លាំងបន្ថែមពីលើការអង្គុយពីមុខកុំព្យូទ័ររាប់ម៉ោងនោះ។

នាងនៅអង្គុយកំដរបុរសសង្ហាស្រស់ស្រូបផង ផ្តើមសំនួរទៅកាន់គេផង៖

-មិញនេះគ្រោះថ្នាក់ណាស់!

គេតបមកវិញដោយពមអាហារក្នុងមាត់៖

-ឥឡូវអស់អីហើយ!

រាមនរិន្ទកាន់តែធ្វើឲ្យធីតាយើងមានអារម្មណ៍ថានាងទើបតែស្គាល់គេថាជាមនុស្សបែបណាពិតប្រាកដក្នុងរយៈពេលដែលនៅជិតគ្នានេះ។ ហើយកាន់តែស្គាល់កាលណា ក៏កាន់តែដឹងថា គេជាមនុស្សល្អពិបាករក ព្រមទាំងផ្ទុយគ្នាស្រលះចំពោះអ្វីដែលនាងធ្លាប់គិតពីមុនមកផង។

នាងដៀងភ្នែកទៅរកដៃគេដែលរបួសដោយរងកំណាត់ឈើជំនួសនាងនៅឯសណ្ឋាគារWinter Jayapura ដៃនោះកំពុងបញ្ជាស្លាបព្រាបាយដូចគ្មានរឿងអ្វីកើតឡើង។ នារីរិះគិតម្នាក់ឯង៖

"រាមនរិន្ទ! លោកជាមនុស្សដែកឬអ្វី?"

សំឡេងគេលាន់មកកាត់ផ្តាច់អារម្មណ៍ត្រិះរិះរបស់នាង៖

-បើយូរណាស់ ម៉ោង១០ព្រឹកស្អែកយើងទៅដល់ ស្រុកSarmiហើយ!

កេតឌីម៉ាងក់ក្បាលតិចៗតែរក្សាភាពស្ងៀមស្ងាត់មិននិយាយតប...តែភ្លាមនោះនាងឮគេពោលបន្ថែម៖

-យើងប្រហែលជាអាចជួបលំអងនៅហ្នឹង!

ស្រីស្អាតដៀងភ្នែកដោយទុក្ខព្រួយស្របពេលនាងឮគេនិយាយបន្ត៖

-ព័ត៌មានអាកាសធាតុដូចមិនអំណោយផលឲ្យចេញទៅសមុទ្រដើម្បីបន្តទៅកោះស្មៅលឿងទេ! ពួកគេទៅដល់មុនយើង តែក៏ចាំបាច់ត្រូវតែសំចតសិនដដែល!

ឃើញនាងនៅតែស្ងប់ស្ងាត់ គេបង្អង់ពីការបរិភោគរួចងើបមុខសម្លឹងស្រស់ស្រី៖

-ចង់ជួបពួកម៉ាកអត់?

ឌីម៉ាតបដោយស្រពោន៖

-ជួបក៏អត់អីត្រូវនិយាយទៀតដែរ! ខ្ញុំអត់ចង់ជួបអ្នកដែលកុហកមានល្បិចមានកលលើខ្ញុំទេ!

រាមនរិន្ទសើចតិចៗ បន្តិចក្រោយមកទើបគេនិយាយមួយៗ៖

-គេក៏មិនអាក្រក់ពេកដែរ! តាមពិតគេនៅតែគិតពីឌីម៉ា ប៉ុន្តែប្រហែលមកពីមានគោលដៅផ្សេងបានជាបង្ខំចិត្តធ្វើអញ្ចឹង! បើលើកលែងបានគួរតែលើកលែង!

នារីមិនដឹងថាគេកំពុងព្យាយាមធ្វើចិត្តល្អឲ្យនាងស្ងប់ស្ងែង ឬមួយយ៉ាងណាទេ តែនាងត្រូវតែឆ្លើយតបវិញ៖

-ខ្ញុំជាមនុស្សធម្មតាដូចគេឯងមិនមែនជាព្រះពុទ្ធទេ! បើអ្នកណាធ្វើអាក្រក់ចំពោះខ្ញុំ ខ្ញុំត្រូវតែចងចាំហើយគ្មានរឿងអីត្រូវបំភ្លេចចោលងាយៗទេ!

នាងក្រោកប្រមូលចានក្បានរៀបចំលាងលែងរវល់នឹងគេ។ បុរសដែលកំពុងលង់ស្នេហ៍ឈានមួយៗមកឱបចង្កេះនាងពីក្រោយជាប់។

-មែនតើ! មានពីណាថាយើងហ្នឹងស្លូត?

ធីតាបង្អង់ដៃដែលកំពុងធ្វើការ។ នាងងាកតិចៗមករកបបូរមាត់បុរសដែលកំពុងញញឹមស្រស់ក្បែរថ្ពាល់។ ឌីម៉ាគិតបន្តិចទើបសួរ៖

-លោកប្រុសរាមធ្លាប់លើកទោសឲ្យអ្នកដែលនិយាយកុហក និងមានល្បិចកលអញ្ចឹងដែរអត់?

បុរសដង្ហើមយូរ គេពោលតបក្រោយពេលគិតបន្តិច៖

-អាស្រ័យទេ! បើគេដឹងខុស...មានអី!

តរុណីដៀងភ្នែកសញ្ជឹងគិតដោយព្រួយបារម្ភ។ សំនួរបន្ទាប់លេចមកស្ទាត់ៗក្នុងចិត្តនាង៖

"ចុះបើស្រីដែលលោកកំពុងឱប! ធ្លាប់ជាសង្សារអ្នកដែលមានឧបាយកលធ្វើបាបលោក ហើយនាងធ្លាប់មានល្បិចជាមួយលោកផង?"

## **វគ្គទី១៥**

### **ស្រុកសាមី(Sarmi)**

នៅឯស្រុកសាមីឯណោះវិញ តើលំអងពិតជាកំពុងមានសេចក្តីសុខជាមួយដៃគូស្នេហារបស់នាងដូចពន្លកត្រួយស្នេហ៍របស់រាមនរិន្ទ និងកេតឌីម៉ាដែរឬយ៉ាងណា?

ដោយសារចាំបាច់ត្រូវតែចូលចតដើម្បីចាក់ប្រេង និងស៊ើបព័ត៌មានបន្ថែមមុនធ្វើដំណើរបន្តឲ្យឆាប់ដល់កោះស្មៅលឿង បុរសពាណិជ្ជករKenកំពុងត្រូវអន្ទះសា ដោយសារព័ត៌មានអាកាសធាតុបានបង្អើលឲ្យនាយត្រូវរារែកចំពោះការរុលដំណើរទៅមុខបន្ទាប់ពីសំចតបានត្រឹមតែ៣ម៉ោង។

នៅក្នុងតៀមតែទឹកដោះដែលជាភេសជ្ជៈដ៏មានប្រជាប្រិយភាពរបស់ជនហិណ្ឌូជាច្រើន Kenអង្គុយបង្ហាញតប់ប្រមល់នៅពេលដែលលំអងកំពុងពន្យល់ពីរឿងអាកាសធាតុ។

-បងឆ្កួតហើយKen! ទោះយ៉ាងណាយើងមកដល់មុនពួកហ្នឹងឆ្ងាយហើយ មិនបាច់អីផ្សងជីវិតជាមួយព្យុះទេ! ចាំយូរមកហើយចេះចាំបាន? ចាំត្រឹមបី បួនថ្ងៃទៀត ឲ្យខ្យល់ស្ងប់សិន ចាំមិនបាន?

ទឹកមុខនាយឡុង និងនាយហ៊ូអង្គរក្សនាគខ្លារបស់ពាណិជ្ជករកាត់ចិនបង្ហាញសញ្ញាថាគាំទ្រសម្តីលំអង កាន់តែធ្វើឲ្យនាយKenកើតមួម៉ៅ គេដំឡើងសំឡេង៖

-កុំនាំគ្នាមើលងាយសត្រូវ! កុំឃើញពួកវានៅឆ្ងាយអាល័យនាំគ្នាដេកផ្លូវ លោតែវាតាមមកទាន់ខាតកម្លាំងទទេ! បើរបស់នោះធ្លាក់ដល់ដៃរាមនរិន្ទ កុំសង្ឃឹមដណ្ដើមមកបានវិញ! យប់នេះត្រៀមចាំមើលសិន តែត្រូវប្រុងជើងព្រួលឲ្យរហ័ស ឲ្យមេឃតែស្ងប់ ត្រូវចេញទៅសមុទ្រភ្លាម!

នាយឡុងងាកមើលកូនចៅប្រមាណ១០នាក់ដែលកំពុងស្ថិតនៅតុនានាជុំវិញនោះ។

ម្នាក់ៗមានទឹកមុខហេវហត់ដោយសារមិនទម្លាប់នឹងដំណើរតាមសមុទ្រ ហើយពេលនេះទៀតខ្លះកំពុងអង្គុយសម្លក់បាយគ្រឿងរបស់អ្នកកោះសាមី ដោយសារមិនចេះហូប។ ខ្លះនៅក្អួតចង្អោរ និងទាររកហាងម្ហូបចិន។

នាយហ៊ូងាកមកខ្សឹបដាក់លំអង៖

-ពួកនេះមិនធ្លាប់ដើរសមុទ្រ! ទន់អស់ហើយ! បើបណ្ដោយទៀត ឈឺអស់មិនខានទេ!

លំអងដកដង្ហើមធំ ងាកមកសួរវិញ៖

-ហ៊ូ! រកមើលហាងចិននៅម្តុំនេះទិញគ្រឿងហូបចុកខ្លះទុកលើកប៉ាល់ទៅ! បាយអស់នេះ គ្មានអ្នកណាចេះលេបទេ! ធំតែក្លិនហ្នឹងចង់រត់ទៅហើយ!

នាងងាកមករកប្រុសស្នេហ៍ដែលធ្វើមុខក្រញូវ៖

-ក្រែងមុននេះ បងKenទូរសព្ទទៅកុហករាមនរិន្ទថាលោកវ៉ាទូស្លាប់ហើយតើហ្អី? ពួកគេអាចថាមិនតាមមកទៀតទេមើលទៅ!

Kenលើកអកកែវទឹកដោះគោដោយអន្ទះសា ប៉ុន្តែគេត្រូវព្រួសមកវិញភ្លាមមួយរំពេចដោយសារមិនអាចទ្រាំទ្រនឹងក្លិនដ៏ឆ្អួលប្លែកនោះបាន។ គេក្រោករឹងដោយសៅហ្មងឆ្ពោះទៅរកមាត់ទឹក ហើយឈរសម្លឹងទៅឆ្ងាយ។ លំអងដែលក្រោកដើរទៅតាមដោយមានក្រដាសជូតមាត់ក្នុងដៃផងនិយាយបណ្ដើរ ហុចទៅឲ្យគេបណ្ដើរ៖

-ចុះបើដឹងថា គង់តែរាមនរិន្ទមិនជឿដដែល ចាំបាច់អីទូរសព្ទទៅកុហកគេនាំតែគេសង្ស័យយើងទៀត?

Kenតបដោយមុខក្រញូវ៖

-បងបាត់ដំណឹងពីខាងវាសូន្យ អញ្ចឹងហើយខលទៅក្រៅពីចង់កុហករឿងតាកន្ទាត់នោះស្លាប់ដើម្បីឃាត់ដំណើរវា និងឲ្យដឹងថាវានៅឯណាផង!

នាយពាណិជ្ជករប្រកបដោយមហិច្ឆតានិយាយរអ៊ូៗ៖

-អាBirdអើយអាBird ! បំបង់បាយ!

លំអងរភ្នែកសញ្ជឹងគិតរួចទើបនិយាយមួយៗ៖

-បើថានៅលើទន្លេម៉េមប៊ឺអត់មានអុបតិចហ្វូន ម៉េចក៏បងឯងទូរសព្ទរាមនរិន្ទចូល?

អង្គរក្សរឿនប្រហែលជាដកហូត ទូរសព្ទកូនចៅគេអស់ហើយតាំងពីឃើញបងKenមានមុខនៅកន្លែងដេញថ្លៃនោះ! អង្គរក្សសំគមនោះឆ្លាតផុតលេខហើយ!

ហាក់ទើបតែនឹកឃើញដល់រឿងអ្វីមួយ នាងបើកភ្នែកធំៗងាកមកសម្លឹងបុរសដែលនាងផ្ញើរបេះដូងរួចស្រុះកាន់៖

-បងKen!? កូនចៅបងឯងមានរឿងហើយដឹង?

នាយKenរលាស់ដៃចេញដោយមិនសប្បាយចិត្ត៖

-បងគ្មានពេលទៅខ្វល់ទេ! បើវាល្ងង់ដល់ថ្នាក់ឲ្យគេចាប់បាន អាហ្នឹងជាលទ្ធផលរបស់វា! ហើយបើទៅធ្វើរនុកក្នុង ហើយស្ងាត់ច្រៀបដូចចោរលួចសេះដដែល ចិញ្ចឹមវាឲ្យបំបង់បាយអី?

លំអងមានអារម្មណ៍អស់កម្លាំងចិត្ត។ នាងឈរឱបដៃទ្រេតខ្នងនឹងសសរឈើប្រឋមាត់ទឹក។ ហេតុអីក្នុងពេលពិបាកស្មុគស្មាញ Kenក្លាយជាមនុស្សកញ្ជ្រោល និងឆេវឆាវថ្នាក់នេះ? បដិមានោះអីក៏សំខាន់ដល់ថ្នាក់នេះ ?

ភ្លាមនោះនាងនឹកឃើញដល់កេតឌីម៉ា។ ផ្ទៃមុខស្លូតត្រង់ និងទន់ភ្លន់នាងលេចមកភ្លែតក្នុងអារម្មណ៍លំអង។ នាងដកដង្ហើមធំនៅពេលគិតដល់ចំណុចថា សូម្បីតែឌីម៉ាជាស្រីស្រស់ស្លូតបូត នៅតែពាណិជ្ជករដែកថែបមិនទន់ចិត្តអាណិតសូម្បីបន្តិច កុំថាឡើយដល់ទៅនាយBirdម្នាក់។

លំអងឱនសម្លឹងខ្សែទឹកដែលឆ្លុះជាមួយពន្លឺភ្លើងគោម។ នាងបើកភ្នែកធំៗនិមិត្តតែឃើញរូបបុរសវ័យក្មេងម្នាក់ប្រាកដកាយក្នុងនោះ។ នារីងើបមុខសម្លឹងមនុស្សពិតដែលកំពុងដើរមួយៗមករកនាង។ ទឹកមុខក្រអឺតក្រអោង និងងើយកសឹងដល់មេឃ គឺជាទម្លាប់របស់ជននោះទៅហើយ ទោះបីមកដល់កោះSamiហើយក៏គេនៅតែមិនបោះបង់ចោលអាកប្បកិរិយាខ្ពស់ហួសពពកនេះដែរ។

នាងបង្ហាញម៉ូតសសៀរចូលជិតប្រុសស្នេហ៍ដោយលាន់មាត់ប្រាប់គេតិចៗ៖

-បងKen! នុះ! កូនប្រុសឧកញ៉ាឆាយណាគុណ!

ដោយសារតែអាកប្បកិរិយារបស់រាមនរិន្ទចម្លែកខុសពីគេឯងបានជាកលល្បិចរបស់នាយKenនិងលំអងដែលប៉ងឲ្យឌីម៉ា ឬសិទ្ធិគុណអាចត្រូវរងគ្រោះដើម្បីឲ្យរាមនរិន្ទត្រូវជាប់ពិរុទ្ធមុនពិធីដេញថ្លៃមកដល់នោះត្រូវបរាជ័យ។

ប៉ុន្តែទោះបីខកចិត្តចំពោះបរាជ័យនៃគម្រោងការនោះ ក៏អ្នកទាំងពីរមិនដែលនឹកស្មានថា កាលដែលគេខំឆ្លងទន្លេមកទាំងយប់ងងឹត បែរជាមានបុរសពាណិជ្ជករវ័យក្មេងកូនកាត់ខ្មែរថៃនេះមកតាមទាន់នៅទីនេះដល់តែបាននោះទេ។

Kenងើបមុខសម្លឹងតាមសម្តីស្រីស្នេហ៍ គេរអ៊ូតិចៗ៖

-វាមកទីនេះធ្វើអីវា?

សំឡេងសិទ្ធិគុណលាន់មកមុនពេលលំអងឆ្លើយតបនឹងសម្តីប្រុសស្នេហ៍៖

-បងKen! ខានជួបគ្នាយូរហើយ?

សុភាពបុរសក្លែងក្លាយបង្ខំចិត្តងើបមុខញញឹមដាក់អភិជនវ័យក្មេងដែលល្បីខាងថៃចង់ស្រីឥតអៀនខ្មាស។ គេធ្វើជាសើចស្រស់ហើយលូកដៃទៅរលាក់តប៖

-សិទ្ធិគុណ! ខ្យល់អីបក់មកដល់កោះសាមី? ហើយចុះលោកពូឧកញ៉ា សុខទុក្ខម៉េចដែរ?

លំអងងាកមុខចេញ។ នាងដឹងថាទោះKenខំធ្វើពើតែសិទ្ធិគុណប្រហែលមិនល្ងង់ទេ ព្រោះមុននេះនៅចាយ៉ាពូរ៉ានាងបានទៅជួបគេ ហើយបាននិយាយចាក់ដោតគេពីរឿងរាមនរិន្ទបង្ខំឲ្យឌីម៉ារស់នៅជាមួយផង។ កាលណោះនាងមានចេតនាចង់ឲ្យសិទ្ធិគុណដែលលង់ស្នេហ៍អ្នកគ្រូបង្ហាញម៉ូតទៅបង្កជម្លោះជាមួយកូនប្រុសអ្នកតំណាងរាស្ត្រដូចដែលនាងធ្លាប់រៀបចំឲ្យគេទៅចែចង់កេតឌីម៉ានៅកណ្ដាលចំណោមឯកោះបាលីឲ្យរាមនរិន្ទមកប្រទះឃើញអញ្ចឹងដែរ។

នាងបែរខ្លួនចាកចេញទៅ ក្រោមកន្ទុយភ្នែកតាមសម្លឹងរបស់បុរសអភិជនវ័យក្មេងដ៏ក្រអឺតក្រទម។ សិទ្ធិគុណនិយាយតបទៅកាន់ពាណិជ្ជករដែកថែបៈ

-បងKenទៅកោះស្នោលឿងកើតដែរបើមេឃអញ្ចឹង?

នាយKenរក្សាស្នាមញញឹម ប៉ុន្តែក្នុងចិត្តកំពុងទោមនស្ស។ គេគិតស្ងាត់ៗម្នាក់ឯងៈ

"អាល្អិតនេះអត់មានមុខនៅពិធីដេញថ្លៃទេ ចុះវាមកដល់នេះដើម្បីអីដែរ? មិនសមថាវាស្រលាញ់កេតឌីម៉ាដល់ឆ្កួត ហើយតាមមកឆ្ងាយយ៉ាងនេះចោលការងារ មួយគំនរគគោករបស់ឪពុកវាកើតទេ? បើអញ្ចឹងមែន យើងគួរតែរកកម្លាំងវាបន្ថែមដើម្បីឆាប់សម្រេចកិច្ចការដែរទេ?"

ពាណិជ្ជករសម្បូរល្បិច និយាយតបដោយទឹកមុខប៉ប្រីមៈ

-បានប្អូនគុណជាគ្នាហើយ បងក៏លែងភ័យដែរ! តោះជជែកគ្នាបន្តិច!

នាយKenនាំពាណិជ្ជករវ័យក្មេងដែលលង់ស្នេហ៍នារីបង្ហាញម៉ូត និងដែលអាចចាត់ថាមានសត្រូវរួមតែមួយ ទៅរកកន្លែងគួរសមជាងគេមួយលើកោះសាមីដើម្បីជជែក។ បុរសកូនកាត់ចិនដ៏វៃឆ្លាតមិនមែនមិនដឹងទេថាដោយសារមិនធ្លាប់មានស្រីណាហ៊ានជំទាស់ចិត្ត ថៅកែក្មេងសិទ្ធិគុណដែលសូម្បីតែចង់ឲ្យកេតឌីម៉ានិយាយរកមួយម៉ាត់ក៏អត់មានសំណាងដែរនោះ នៅមិនអស់ចិត្តឡើយ។ គាប់ជួនកាលនៅJayapurគេត្រូវលំអងបញ្ឆោតថា ឌីម៉ាគ្មានសេរីភាពដោយសារត្រូវរងអំណាចរាមនរិន្ទយុវជនឈាមរាវកាន់តែមិនអស់ចិត្តទ្វេឡើងរហូតតាមមកដល់ទីនេះ។

សភាពការណ៍នេះបានជួយឲ្យនាយKenនឹកឃើញប្រើឱកាសស្វែងរកមធ្យោបាយក្នុងការលៃយ៉ាងណាឲ្យទទួលបានលទ្ធផលល្អដូចគ្នា គឺម្នាក់បានឥន្ទប្បដិមា ហើយម្នាក់ទៀតបានស្រីស្អាតមកនែបនិត្យ។

ដើម្បីផលប្រយោជន៍រៀងខ្លួន ទីបំផុតមនុស្សគ្មានចិត្តស្មោះទាំងទ្វេបានសម្រេចទទួលយកផែនការរួមក្នុងការបំផ្លាញទាំងបេសកកម្មឥន្ទប្បដិមានិងទាំងរឿងស្នេហារបស់កូនប្រុសត្រកូលអ្នកនយោបាយ។

រាត្រីដ៏មាននំនុកចិត្តនៅកោះសាមីបានកន្លងផុតទៅយ៉ាងឆាប់រហ័ស ផ្លាស់វេនឲ្យថ្ងៃថ្មីមួយទៀតឈានចូលមកវិញ នាំយកមកជាមួយនូវកប៉ាល់លឿនមួយគ្រឿងដែលជាជំនិះរបស់បុត្រាតំណាងរាស្ត្រខ្មែរ។

មនុស្សម្នានៅកំពង់ផែ Sarmiបានចោលភ្នែកដោយក្តីស្ញើចសរសើរលើរូបសម្ផស្សប្រុសស្រីមួយគូដែលសក្តិសមតែជាគូព្រេងក្នុងប្រលោមលោកមនោសញ្ចេតនា។

រាមនរិន្ទ និងឌីម៉ាបណ្តើរគ្នាដោយមានកងការពារតាមពីក្រោយឆ្ពោះទៅរកទីសម្រាក គឺតៀមតែទឹកដោះដែលកាលពីម្សិលបានទទួលអភិជនខ្មែរពីរនាក់រួចទៅហើយ។

ក្នុងខណៈដែលកែវតែទឹកដោះគោក្តៅៗទើបលើកមកដល់ មនុស្សមួយក្រុមមានគ្នីគ្នាមិនក្រោម១០នាក់បានបង្ហាញខ្លួនដេញបង្អើលជនានុជនដែលតាមសម្លឹងអ្នកទាំងពីរ។ ឯកសណ្ឋានពណ៌ខៀវចាស់បូករួម និងអាវុធវែងនៅនឹងដៃរបស់ពួកគេ អាចធ្វើឲ្យរាមនរិន្ទស្មានដឹងថា នោះអាចជាក្រុមសន្តិសុខមូលដ្ឋានដែលកំពុងការពារដំណើរអ្នកណាម្នាក់។

បុរសមានអំណាចមិនខ្វីរវល់ច្រើនដោយឱនមកក្រេបទឹកដែលកេតឌីម៉ាកំពុងមានអារម្មណ៍ថាមានក្លិនដូចជាទឹកសាប៊ូ។ នាងសម្លឹងគេ ឃើញគេក្រេបក្អឹកៗហាក់មិនមានខ្វល់ខ្វាយអ្វីចំពោះក្លិនឬរសជាតិឡើយ។ គេងើបមុខសម្លឹងនាង ហើយឃើញនាងធ្វើមុខជូរដោយមិនចេះផឹក។ នរៈសើចស្រស់រួចពោលទៅរកកល្យាណី៖

-នៅម្តុំនេះមានផ្សារមួយ! តាមមើលអាចថាមានរបស់ខ្លះដែលអាចហូបបាន!  បាត់ហត់ពេលណាប្រាប់បង បងជូនអូនទៅមើល!

នាងសួរវិញភ្លាម៖

-ម៉េចក៏លោកដឹងថាទីនេះជិតផ្សារ?

រាមនរិន្ទមិនតបតែគេបូញមាត់ទៅរករទេះទំនិញមួយចំនួនដែលអូសកាត់ទៅមកដោយសត្វចៀមនិងខ្លះដោយម៉ូតូធំៗ។

ស្រីស្រស់ញញឹមស្ងួត ឯសន្ទឹកដេញអ្នកដំណើរក៏លាន់មកលើសមុនដែរ។ ប្រុសស្រីទាំងពីរងាក ក្រោយសម្លឹងទៅហ្វូងសន្តិសុខដែលកំពុងដើរតម្រង់មករកពួកខ្លួនច្បាស់ណាស់។ រាមនរិន្ទរក្សា ស្នាមញញឹមលើផ្ទៃមុខ ប៉ុន្តែឌីម៉ាចាប់ផ្តើមបារម្ភ។

ភាគទី៣២

បុរសម្នាក់រាងទាបក្រអាញសម្បុរខ្មៅទុកពុកចង្កាក្រាស់ខ្មឹកបានបង្ហាញខ្លួនភ្លាមៗកណ្តាលចំណោម កងសន្តិសុខហើយវែកក្រុមដើរតម្រង់មក។

ម្តងនេះមិនបាច់ឆ្ងល់ទេគឺជននោះកំពុងដើរតម្រង់មករកអ្នកទាំងទ្វេរមែនធ្វើឲ្យនាយរឿន និងអង្គរក្ស នានាដែលនៅតុក្បែរនោះក្រោកភ្លែតមកចោមរោមនាយចៅហ្វាយ។

ដោយឃើញជននោះប្រឹងជំនះទឹកមុខសោះកក្រោះ ហើយខំញញឹមមកតាំងពីចម្ងាយ នរិន្ទលើកដៃ ឲ្យសញ្ញាឲ្យកងការពារត្រឡប់ទៅកាន់កន្លែងដូចដើមវិញ។

ដូចការគិតទុក បុរសខ្មៅក្រអាញញញឹមញញែមហើយឱនកាយគោរពកម្លោះយើងតាមរបៀបក្រុម អ្នករស់នៅដាច់ស្រយាល។ ឥរិយាបថរបស់គេទន់ភ្លន់ ប៉ុន្តែទឹកមុខទាហានដែលមកជាមួយមាន ភាពនឹងធឹង និងសោះអង្អើយ។

បុរសខ្មែរក្រោកទទួលបុរសដែលមានលក្ខណៈដូចមនុស្សមកពីកុលសម្ព័ន្ធណាមួយ។ខ្សែកភ្លុកដំរី ដែលលៀនចេញពីក្នុងអាវដ៏វែងតាមបែបសាសនាហិណ្ឌូ និងស្នាមសាក់ក្រវ៉េមក្រវាមលើបាតដៃ ស្តាំរបស់គេជាសក្ខីភាពស្រាប់។ គេតឌីម៉ាក៏យោងកាយក្រោកឈរដែរ។

ភាសាអង់គ្លេសរបស់ជននោះលាន់មករដាក់រដុបតែល្មមអាចយល់ការបាន៖

-ចៅកែរាម! សូមស្វាគមន៍ដំណើរដ៏វែងឆ្ងាយមកដល់ស្រុកសាមី!

រាមនរិន្ទញញឹមស្មើ ក្រោមពន្លឺភ្នែកតាមសម្លឹងរបស់ស្រីស្នេហ៍ គេនិយាយតប៖

-សូមអរគុណ! លោកគឺ....?

បុរសពុកចង្កាបញ្ចេញសំណើចក្អាកក្អាយឮៗទៅតាមរូបរាងធាត់ទ្រលុករបស់គាត់។ បន្ទាប់មកទើប គាត់តបនឹងសំនួរនាយ៖

-ខ្ញុំឈ្មោះអូណ៉ារ ជាមេកងសន្តិសុខនៅភូមិភូវិខាន់!

រាមនរិន្ទចងចិញ្ចើមតែបបូរមាត់កាន់តែញញឹម គេនិយាយបន្តរតាមតិចៗ៖

-ភូរិខាន់?

ជនសម្បុរខ្មៅឆ្លើយតបដោយទឹកមុខញញឹមដូចគ្នា៖

-ភូរិខាន់មានចម្ងាយជាង៨គីឡូម៉ែត្រពីកំពង់ផែSamiនេះ! ភូមិយើងក៏ជាភូមិមួយល្បីឈ្មោះ និងមានប្រជាជនរស់នៅច្រើនជាងគេក្នុងចំណោមភូមិទាំង១៤នៅលើកោះនេះដែរ។

អភិជនខ្មែរលើកដៃឲ្យសញ្ញាអញ្ជើញបុរសនោះអង្គុយ ដូច្នេះកេតឌីម៉ាបានញញឹមគួរសមទៅរកបុរសនោះដែរ មុនពេលនាងឱនកាយចាកចេញទុកឲ្យពួកប្រុសៗបន្តការជជែករបស់ពួកគេ ប៉ុន្តែនាងមិនបានដឹងទេថាស្នាមញញឹមចុងក្រោយរបស់នាងបានខាបយកព្រលឹងរបស់បុរសពុកចង្កា។

ជនឈ្មោះអូណ័រនៅបន្តជជែកជាមួយរាមនរិន្ទ ឯកេតឌីម៉ានៅខាងណេះកំពុង គយគន់ទិដ្ឋភាពដ៏មមាញឹក និងគួរឲ្យរីករាយរបស់កំពង់ផែសាមី។ នារីមូស្លីមជាច្រើនដែលមានទទូរកន្សែងបិទបាំងសក់របស់ពួកគេផង បានមើលមកនាងថាជានារីចម្លែក និងមានឥរិយាបថផ្ទុយស្រលះពីការទូន្មានក្នុងសាសនារបស់ពួកគេ។

ជំនិះខ្លះត្រូវបានរ៉ាប់រងដោយសេះ និងចៀម ចំណែកឯឡាន និងកង់គឺមិនទាន់ប្រទះមួយសោះ ឬឯម៉ូតូមានតែប្រភេទធំៗប៉ុណ្ណោះ។ ចំណែកគ្រឿងស្នូនមាន ចូ ផើង ឆ្នាំងដី និងចានក្បានពីដីឥដ្ឋ ឃើញមានចរាចរណ៍កាត់ចុះឡើងមិនមានអាក់ខាន។ នាងបង្ហាញម៉ូដសួរខ្លួនឯងតិចៗ៖

"សម័យកាលនេះទៅហើយ នៅមានតំបន់មួយដែលរក្សាការរស់នៅដូចការរៀបរាប់ក្នុងរឿងអក្សរសិល្ប៍កាលពីបុរាណដែរហ្ន៎"?

សំឡេងនាយBird លាន់មកក្បែរត្រចៀកពញ្ញាក់នាងមកវិញ៖

-អ្នកនាងឌីម៉ា! ត្រូវទៅផ្សារមែនទេ?

ឃើញនារីបង្ហាញទឹកមុខងឿងឆ្ងល់ គេនិយាយបន្ថែម៖

-លោកប្រុសរាមប្រាប់ថាប្រហែលជាមានការត្រូវជជែកជាមួយមេកងសន្តិសុខនោះយូរ! ដូច្នេះហើយប្រើឲ្យខ្ញុំជូននាងទៅផ្សាររកទិញសម្ភារៈម្ហូបអាហារមុន!

ធីតាយើងដៀងភ្នែកទៅរកបុរសដែលកំពុងព្យាយាមកាន់កាប់បេះដូងនាង។ នាងឃើញគេកំពុងបង្ហាញភាពជក់ចិត្តនឹងការសន្ទនាជាមួយបុរសហិណ្ឌូដែលទើបស្គាល់គ្នាដូចដែលនាយBird

និយាយប្រាប់មែន ចំណែកនៅក្បែរនោះអង្គរក្សវឿន និងកូនចៅដទៃក៏កំពុងតាមដានសកម្មភាពក្រុមសន្តិសុខដោយយកចិត្តទុកដាក់ដែរ។

នាងងក់ក្បាលទៅកាន់នាយBird៖

-តោះយើង!

ផ្សារកំពង់ផែសាមីជាផ្សារតូចមួយដែលមានផ្ដុំដោយរទេះលក់ទំនិញដែលដឹកដោយសត្វចៀម និងម៉ូតូធំ។ ក្រៅពីនោះគេឃើញមានតែកសិករដែលមានទំនិញបន្តិចបន្តួចដាក់ក្នុងល្អីឬក៏កន្ត្រកធ្វើអំពីផ្តៅ។ ចំណែកគេហដ្ឋានពលរដ្ឋក្បែរៗនោះក៏ច្រើនជាប្រភេទផ្ទះឈើដែលដាក់លក់ក្រណាត់ព្រំថោកៗ និងគ្រឿងកាឡៃបន្តិចប៉ុណ្ណោះ។ បន្ទាប់ពីរកបានម្ហូបក្រៀម ផ្លែឈើនិងសម្ភារៈប្រើប្រាស់ខ្លះហើយនាយBirdដែលមុននេះធ្វើពុតជាចេញឆ្ងាយពីនាងដើម្បីស្វែងរកទូរសព្ទសាធារណៈនោះត្រឡប់មកវិញដោយទឹកមុខហត់នឿយ។ នារីសម្លឹងទៅឃើញបុរសអង្គរក្សដែលមានកាន់ដបភេសជ្ជៈខ្លះក្នុងដៃហើយនិយាយទៅកាន់គេ៖

-Bird! ទឹកមុខអត់ស្រួលសោះ! បើជំងឺធ្វើទុក្ខទៀតឆាប់ប្រាប់ណ៎ា!

បុរសបង្កប់ខ្លួនដៀងភ្នែកសម្លឹងមកនារីរូបល្អ គេដឹងថានាងល្ងង់ណាស់ នាងប្រាកដជាស្មានថាកាលដែលគេគេចទៅអម្បាញ់មិញ ព្រោះតែទិញទឹកក្រូចប៉ុន្មានដបនេះមែន។ ដូច្នេះគេក៏និយាយទៅកាន់នាងតិចៗ៖

-អ្នកនាងឌីម៉ា! នាងមានទូរសព្ទទេ? ខ្ញុំមានការចង់និយាយទៅផ្ទះបន្តិច! ខ្ញុំសុំប្រើបន្តិចបានទេ?

ឌីម៉ាគ្រវីក្បាល។ នាងតបដោយទឹកមុខស្លូត៖

-ខ្ញុំក៏អត់មានដែរ! អង្គរក្សវឿនគេដកទុកតាំងពីមុនឡើងទូកចេញពីក្រុងចាយ៉ាពូរ៉ាទៅទៀត!

នាយBirdបង្ហាញអាកប្បកិរិយាហួសចិត្ត៖

-សូម្បីនាងក៏គេមិនទុកចិត្តដែរ? ស្មានតែដកទុកតែរបស់ពួកខ្ញុំ?

ឌីម៉ាញញឹមស្ងួតមិនឆ្លើយ ប៉ុន្តែនៅតាមផ្លូវដើរត្រឡប់ទៅហាងតែវិញ នាងត្រិះរិះសរសើរគំនិតអង្គរក្សវឿនដែលតែងតែម៉ត់ចត់ និងយកចិត្តទុកដាក់លើគ្រប់ស្ថានការណ៍។ ដោយសារភាពស្លូតត្រង់នាងមិនបានយកករណីសួររកខ្សែទូរសព្ទរបស់នាងBirdមកគិតទេ។

ពេលមកដល់ហាងតែទឹកដោះគោបានបន្តិច នារីឃើញមានរថយន្ត១២កៅអី២គ្រឿងពណ៌ស្លឹកឈើបើកមកដល់ទីនោះដែរ។ នោះជាឡានតែ២គត់ដែលនាងបានឃើញបន្ទាប់ពីបានចាកចេញពីក្រុងចាយ៉ាពូរ៉ា។

ពេលនោះហើយ ដែលនាងឮរាមនរិន្ទប្រាប់ថា ត្រូវបន្តដំណើរទៅភូមិភូវីខាន់របស់បុរសពុកចង្កា។

ធីតារូបល្អរួមដំណើរជាមួយរាមនរិន្ទ និងអង្គរក្សទាំងអស់ ចំណែកបុរសមេកងសន្តិសុខ និងក្រុមទាហានរបស់នៅលើរថទីមួយដែលនាំដំណើរ។

ជំនិះទាំងពីរបានបោះពួយចាកចោលកំពង់ផែសាមីតាមផ្លូវដីទទឹងប្រហែល៥ម ដែលអមបណ្តោយមាត់ផ្លូវដោយចម្ការថ្នាំជក់ប៉ប្រះមាត់ទន្លេ។ បានប្រមាណ២គីឡូម៉ែត្ររថយន្តបត់ចូលតាមផ្លូវលំមួយក្បែរជើងភ្នំហើយបោលជ្រែកកាត់ព្រៃក្រាស់ឃ្មឹកដែលអមសងខាងផ្លូវឆ្ពោះទៅទិសខាងលិច។

ដកភ្នែកចេញពីការតាមដានទេសភាពអមផ្លូវជាចៃដន្យ កេតឌីម៉ាក្រឡេកឃើញអង្គរក្សខ្ពស់ស្រាវដែលនៅអង្គុយអែបម្ខាងទៀតជាប់រាមនរិន្ទដែរនោះ កំពុងពិនិត្យដងផ្លូវនិមួយៗដោយយកចិត្តទុកដាក់។ កូនសៀវភៅ និងប៊ិចនៅលើដៃគេម្តងម្កាលសរសេរកត់ត្រាអ្វីម្យ៉ាងដែលនាងយល់ថាប្រហែលជាគេកំពុងព្យាយាមចំណាំទិស និងផ្លូវធ្វើដំណើរ។

នាងយល់ថា គេឆ្លាត និងម៉ត់ចត់ណាស់។

## វគ្គទី១៦

### ភូមិភូវីខាន់(Puvikan)

ភូមិភូវីខាន់ចោមព័ទ្ធដោយព្រៃឈើនិងផ្នែកខាងកើតនៃភ្នំHimalayas។ ពលរដ្ឋរស់នៅមានសរុបជាង៤ម៉ឺននាក់ ក្នុងចំណោមនោះឥស្លាមសាសនិកមានចំនួនច្រើនជាងគេ។ ទោះជាបែបនោះក្តីភូមិភូវីខាន់មិនបានប្រកាសខ្លួនជាភូមិឥស្លាមទេ ដោយសារគេមានពលរដ្ឋជាអ្នកហិណ្ឌូក្នុងភាគរយច្រើនគួរសមកំពុងរស់នៅ។

ភ្ញៀវកម្ពុជាទាំងនោះ ត្រូវបានគេទទួលនៅផ្ទះសំណាក់មួយដែលជាទីទទួលបដិសណ្ឋារកិច្ចសមរម្យជាងគេបង្អស់នៅភូមិភូវីខាន់។ ផ្ទះសំណាក់នោះមាន៣ជាន់សង់ពីថ្មប្រក់ក្បឿង ប៉ុន្តែបំពាក់ដោយសង្ហារិមឈើ និងចោមព័ទ្ធដោយសួនដំណាំហូបផ្លែដែលប្ដូរកដោយផលានុផលគួរជាទីគាប់ភ្នែក។

ជាន់ទី៣គឺជាជាន់លើបង្អស់ ក៏ជាជាន់ដែលជនពុកចង្កានិយាយថាទុកសម្រាប់ឲ្យក្រុមភ្ញៀវខ្មែរទាំងនេះប្រើប្រាស់តាមចិត្ត ដូច្នេះហើយនៅពេលដែលរាមនរិន្ទត្រូវបានអញ្ជើញឲ្យចេញទៅជួបពិភាក្សាការងារនៅឯទីតាំងធំរបស់កុលសម្ព័ន្ធ គេបានទុកឲ្យកេតឌីម៉ា និងអ្នកការពារបីនាក់ទៀតនៅទីនេះជាមួយនាង ដោយមាននាយBirdជាអ្នកមើលខុសត្រូវ ឯអង្គរក្សវឿនមិនដែលឃ្លាតពីថៅហ្វាយធំរបស់គេសូម្បីតែមួយពេលឡើយ។

រសៀលឈានចូលមកដល់ ពួកគេនៅតែមិនទាន់វិលមកវិញឡើយ។ នារីបង្ហាញម៉ូតបានចុះដើរចច្រប់ម្នាក់ឯងក្នុងចម្ការហូបផ្លែដែលលាតសន្ធឹងច្រើនហិកតារ។ ផ្លែចេក និងត្របែកសម្បូរជាងគេបង្អស់នៅក្នុងចម្ការភូវីខាន់។ បរិយាកាសទាំងឡាយមានសភាពខុសគ្នាទាំងស្រុង និងកំពង់ផែសាមីក៏រឹតតែប្លែកគ្នាឆ្ងាយ និងទិដ្ឋភាពអព្ភ និងព្រិលនៅក្រុងធំចាយ៉ាពូរ៉ា។

អាកាសធាតុមានលក្ខណៈត្រូពិកច្រើនដែលហាក់ស្រដៀងផងគ្នាទៅនឹងស្ថានភាពនៅប្រទេសកំណើតខ្លួន ជួនជាមួយចម្ការលាតសន្ធឹងធំធេង ធ្វើឲ្យនារីលង់ទៅក្នុងមនោសញ្ចេតនាថ្មី។ ក្លិនផ្លែត្របែកទុំក្រអូបឆ្អួលនាសា លាយជាមួយសព្ទសត្វបក្សីបក្សាខ្សៀវខ្សារកងរំពងហាក់បបោសអង្អែលនារីឲ្យចាកឆ្ងាយពីទុក្ខព្រួយដោយសារស្នេហាក្បត់ និងភាពទើសទាល់ចំពោះស្នេហាថ្មីដែលនៅមិនទាន់លេចរូបរាងច្បាស់។

នាងឈោងបេះផ្លែត្របែកក្រហមរន្ទាលជាសញ្ញាថាវានឹងជ្រុះហើយបើគ្មានអ្នកណាចង់បេះទេនោះ។ ម្រាមមិនទាន់លូកដល់ផងនាងឮសំណើចមនុស្សប្រុសម្នាក់លាន់មកក្រអៅ។ ធីតាភ្ញាក់ក្រញ៉ាងដោយសារមុននេះនាងគិតថានៅទីនេះប្រហែលជាគ្មានអ្នកណាក្រៅពីនាងទេ។ ឌីម៉ាងាកក្រោយរឹងសម្លឹងទៅរកប្រភពនៃសំណើច ស្របពេលអភិជនក្មេងដែលនាងស្គាល់ច្បាស់បោះជំហានមួយៗសំដៅមក។ នារីនៅស្ងៀមទ្រឹងដោយទឹកមុខស្មើ ប៉ុន្តែក្នុងចិត្តនាងកំពុងភ្ញាក់ផ្អើល។

"ម៉េចក៏សិទ្ធិគុណមកដល់ទីនេះដែរ?"

សូម្បីតែសិទ្ធិគុណមានវត្តមានមកកាន់ចាយ៉ាពូរ៉ាតាំងពីពេលណាមកក៏នាងមិនដែលបានដឹងផង កុំថាឡើងដល់គេឡើងទូកមកស្រុកSarmiហើយបង្ហាញមុខនៅភូមិភូវីខាន់ទៀត ព្រោះថាចាប់តាំងពីពេលដែលគេឲ្យអ្នកស្រីកុលាបមកបញ្ចុះបញ្ចូលនាងនៅកោះបាលី ហើយចុងក្រោយគេត្រូវដកខ្លួនដើរគេចចេញពីផ្លូវរបស់រាមនរិន្ទនោះ គឺនាងលែងបានឃើញគេរហូត។

អភិជនវ័យក្មេងដ៏ល្បីឈ្មោះខាងច្រឡោងខាម និងមានព័ត៌មានអាស្រូវមិនដាច់ជាមួយស្រីស្អាតៗនោះ ឈ្ងោកមកសម្លឹងធីតារូបល្អជិតសែនជិតដូចដែលគេធ្លាប់ធ្វើរួចមកហើយនៅពេលគេបានឃើញនាងជាដំបូងនៅកោះបាលី។

សម្ដីគេលាន់មកជាមួយកែវភ្នែកទើសទាល់របស់កេតឌីម៉ា៖

-ចូលចិត្តកន្លែងនេះអត់?

ដូចកាលពីមុនដែរ គឺនារីងាកមុខគេចចេញពីបុរសគឃ្លើន។ សិទ្ធិគុណដែលសូម្បីតែវ័យក៏មិនប្រាកដថាច្រើនជាងនាងនោះ បែរជាបង្ហាញឫកពាចែចង់ស្រី និងគ្មានសូម្បីតែសម្ដែងជាសុភាពបុរសមួយពេលសោះនេះ ពិតជាមិនខុសអ្វីនឹងពាក្យល្បីដែលនាងធ្លាប់បានឮកន្លងមកឡើយ។ តរុណីឈានជើងចេញ ប៉ុន្តែនាងទៅមិនរួចជាមួយជំហានវែងៗរបស់នាយងប់ស្នេហ៍ឡើយ។

-បើនាងចូលចិត្ត ខ្ញុំនឹងទិញចម្ការនេះទាំងមូលទុកសម្រាប់យើងមកកម្សាន្តតែពីរនាក់!

គេនិយាយផង ពាំងផ្លូវនាងផង។ ពេលនាងឈានទៅមុខមិនបាន គេកាន់តែបានចិត្តហើយឈ្ងោកមកសម្លឹងផែនថ្ពាល់ដែលប្រែទៅជាក្រហមព្រឿងៗដោយសារកំហឹងក្នុងចិត្តស្រីស្រស់។

ប្រសិនបើគេគិតថាគេអាចប្រើវិធីនេះដើម្បីឲ្យនាងហារមាត់និយាយតបនោះ គេមុខតែគិតខុសហើយ។ ល្បែងស្នេហ៍ផ្អែមល្ហែមប្រើអំណាចផង ប្រើសម្ដីលួងផងរបស់រាមនរិន្ទនៅតែមិនទាន់ប្រាកដថាអាចឈ្នះបេះដូងកេតឌីម៉ាបាន កុំថាឡើយឫកពាបែបឈាមរាវ និងខ្វះការយល់ដឹងពីចិត្តសាស្ត្រនារីភេទរបៀបនេះ។ យុវជនមកពីគ្រួសារស្ដុកស្ដម្ភហាក់ទើសចិត្តចំពោះអាកប្បកិរិយារឹងទទឹងរបស់នាងបង្ហាញម៉ូតគេនិយាយដោយមានះ៖

-ស្អីគេអស្ចារ្យម៉េះ? ធ្វើស្រីបងរាម បានលុយប៉ុន្មានទៅ? មិនមែនប្រពន្ធគេឯណាកុំធ្វើឫកពាធំដុំពេក! គេលូកទៅចាប់ដៃនាងដើម្បីឃាត់ដំណើរ ប៉ុន្តែនារីដែលបានត្រៀមរួចហើយនោះងាកមកប្រានគេអស់ទំហឹងក្នុងពេលតំណាលគ្នា។ ដោយសារតែនឹកស្មានមិនដល់ពីប្រតិកម្មនាងសិទ្ធិគុណប្រែជាបាត់ជំហរដួលភីងអុកគូទទៅក្រោយ ទុកឱកាសឲ្យស្រីស្អាតលើកជាយសំពត់រត់កាត់ចម្ការឆ្ពោះមកផ្ទះសំណាក់វិញយ៉ាងរហ័សដូចមានអសុរកាយដេញមកពីក្រោយទុកឲ្យនាយអភិជនក្មេងក្រោកបោសដីដោយហ្មងសៅ។

គេតាមសម្លឹងនាងពីក្រោយដែលស្ថិតនៅឆ្ងាយៗទៅៗ។ ស្រីដែលកាន់តែលំបាក យុវជនកាន់តែនឹកស្រលាញ់ ពិសេសនាងគឺមនុស្សដែលនៅក្បែររាមនរិន្ទ សិទ្ធិគុណកាន់តែកើតចំណង់ចង់បានមកនែបនិត្យ ដើម្បីឲ្យដឹងថាតើនាងមានអ្វីពិសេសលើសស្រីនានាទៅ។

"គ្រាន់បើបន្តិចទៀតសិនទៅ!" គេរអ៊ូតិចៗដោយក្រសែភ្នែកពិសពុល។

នៅឯណេះនារីរត់រហូតដល់កាំជណ្ដើរឡើងទៅលើទីសំណាក់។ កំពុងភ័យសស្លឹត នាងងើបមុខទៅឃើញរាមនរិន្ទឈរឱបដៃសម្លឹងមកដោយញញឹមចិញ្ចាច។ អង្គរក្សខ្ពស់ស្រាវដែលនៅក្បែរនាយឃើញនាងរត់មកដល់កាលណាគេ ក៏បែរខ្លួនដើរឡើងទៅលើមុនចោលចៅហ្វាយនាយហាក់ដូចជាមានចេតនាឲ្យពួកគេបានសម្ដែងមនោសញ្ចេតនារកគ្នា។

បុរសស្វាគមន៍មករកស្រីស្នេហ៍នូវប្រយោគជាមួយសព្ទសំឡេងស្រាលៗ៖

-មានមន្តស្នេហ៍ដល់ហើយហ្ន៎?

កេតឱម៉ាទើបតែភ្ញាក់ខ្លួនដឹងថាតាមពិតគេត្រឡប់វិញតាំងពីពេលណាក៏មិនដឹង រហូតដល់បានទាន់ឃើញព្រឹត្តិការណ៍ចែចង់របស់បុរសក្មេងនោះនៅចម្ការត្របែកអស់ហើយ តែគេមិនត្រឹមមិនជួយរារាំងសិទ្ធិគុណបែរជាមកឈរចាំសើចចំអកនៅទីនេះទៀត។ កំពុងហត់ផង មកឃើញទឹកមុខញញឹមបែបគឃ្លើនរបស់គេទៀត នាងទៅជាមួហ្មង។

សម្ដីសិទ្ធិគុណដែលដៀលត្មះបញ្ឈឺនាងថាមានឋានៈត្រឹមតែជាស្រីរកប្រាក់របស់រាមនរិន្ទនោះលេចឡើងមកក្នុងសោតាសាជាថ្មី ដោយសារពិបាកភ្លេចបំផុត ហើយប្រការនេះបានដុតចិត្តនាងឲ្យកើតជាទោសៈ។ ស្រីស្អាតដើរជៀសឡើងសំដៅទៅជាន់ខាងលើមិនខ្វីឆ្លើយតប និងមិនខ្វីខ្វល់សម្លឹងមុខគេ។ តែដោយដឹងចិត្តកញ្ញាច្បាស់ រាមនរិន្ទស្រវាលូកចាប់កដៃជាប់ ហើយបែរខ្លួនកៀកចង្កេះនាងបណ្ដើរឡើងទៅលើ។

អារម្មណ៍ខឹងសម្បាររបស់ស្រីស្នេហ៍ធ្វើឲ្យអ្នកប្រុសសម្រួលទឹកមុខលែងហ៊ានលេងសើចតែបែរជានិយាយតិចៗទៅរកស្រីស្រស់៖

-ខឹងអ្នកណាខឹងតែម្នាក់ហ្នឹងទៅ កុំឲ្យរាលដាលដល់អ្នកផ្សេងដែលគេមិនដឹងរឿងមើល៍!

ដល់ក្នុងបន្ទប់ទទួលភ្ញៀវនាងបែរទៅរកកែវចាក់ទឹកឲ្យគេ។ បុរសសង្ហាទទួលកែវទឹកមកក្រេបស្របពេលនាងយកអាវក្រៅរបស់គេទៅពាក់ទុកលើទំពក់ដោយមិនចេញស្ដី។ ដៀងភ្នែកទៅរកផ្ទៃមុខក្រហមព្រឿងៗរបស់នាង រាមនរិន្ទកាន់តែចង់លលេង។ កាលពីពេលដែលគេត្រឡប់មកពីជួប

ជជែកជាមួយក្រុមកុលសម្ព័ន្ធ គេមានចេតនាទៅរកនាងដែរ ប៉ុន្តែគាប់ជួនក្រឡេកឃើញសិទ្ធិគុណនៅទីនោះ គេបានបង្អង់ដំណើររង់ចាំមើល។ ទោះបីកាលពីនៅចាយ៉ាពូរ៉ាបន្ទាប់ពីចាញ់កលនាងលំអងមក គេបានប្រចៃប្រចណ្ឌឌីម៉ា និងសិទ្ធិគុណខ្លាំងមែន ប៉ុន្តែក្រោយមក គេបានដឹងច្បាស់អស់ហើយថា នាងមិនបានទុកអភិជនក្មេងនៅក្នុងចិត្តទេ។ ពេលនេះទៀតគេបង្អង់ព្រោះគ្រាន់តែចង់ពិភាក្សាជាមួយអង្គរក្សសំណព្វថាហេតុអ្វីសុខៗសិទ្ធិគុណដែលមិនមានចំណាប់អារម្មណ៍ចំពោះតន្ត្រីប្បដិមាសោះបែរជាលេចមុខនៅភូមិភូរីខាន់? ការបង្ហាញមុខដោយចៃដន្យរបស់ក្រុមកុលសម្ព័ន្ធ និងអញ្ជើញក្រុមខ្លួនមកសំចតនៅទីនេះទៀត តើមានទាក់ទងអ្វីនឹងអភិជនច្រឡោងខាមនោះដែរឬក៏អត់?

ក្នុងនាទីដែលគេកំពុងគិតជាមួយអង្គរក្សរឿន កេតឌីម៉ាស្រាប់តែរត់មកដល់ពេលនេះសកម្មភាពនាងដែលដូចជាគ្មានមេត្តាអ្វីសូម្បីតែបន្តិចចំពោះបុរសក្មេងនៅក្នុងចម្ការត្របែកនៅតែស្ថិតនៅក្នុងអារម្មណ៍កូនប្រុសអ្នកតំណាងរាស្ត្រ។ គេដើរមួយៗទៅរកនាងហើយឱបនាងពីក្រោយទោះបីនាងធ្វើមុខក្រញូវព្រោះខឹងនឹងពាក្យ "ស្រី" ដែលសិទ្ធិគុណទើបតែនិយាយមុននេះ។ នរិន្ទនិយាយតិចៗក្បែរសរសៃសក់ដែលក្រអូបប្រហើរដិតដោយក្លិនត្របែកទុំ៖

-អាណិតសិទ្ធិគុណបន្តិចអីអត់? គេខំតាមមកដល់ទីនេះ ឆ្ងាយមិនស្ទើរទេ! និយាយរកគេមួយម៉ាត់ក៏អត់?

តរុណីមិនឆ្លើយ ប៉ុន្តែនាងនឹកក្នុងចិត្ត៖

"បើលោកនៅតែនិយាយច្រើនទៀត សូម្បីលោកក៏ខ្ញុំមិននិយាយរកដែរ!"

ភាគទី៣៣

នាងប្រឡេះដៃកូនប្រុសអ្នកតំណាងរាស្ត្រចេញ រួចដើរទៅរៀបចំអាហារធ្វើមិនដឹង។ បុរសដឹងថានាងនៅមិនសប្បាយចិត្តពីរឿងសិទ្ធិគុណ គេក៏បណ្ដោយឲ្យនាងនៅស្ងាត់ស្ងៀម ហើយចូលទៅងូតទឹក។ ចេញមកវិញឃើញអាហារត្រូវបានរៀបចំហើយជាស្រេចនៅលើកូនតុតែមិនឃើញវត្តមាននារីរូបល្អទៀតទេ។

គេដើរចេញទៅរកមើលនាង ក៏ឃើញនាងកំពុងត្រូវបានចោមរោមដោយក្រុមអង្គរក្សរបស់ខ្លួនដែលកំពុងត្រូវការអាហារពេលល្ងាច។ រាមនរិន្ទតាមមើលសកម្មភាពនាងពីចម្ងាយ ទឹកមុខនាងញញឹ

មញ្ញៀមដួសបាយចែកឲ្យក្រុមកងការពារខុសគ្នាឆ្ងាយនឹងភាពងង៉ក់ដែលនាងបង្ហាញចំពោះខ្លួនកាលពីក្នុងបន្ទប់។

អ្នកចាប់អារម្មណ៍ថាជាយូរមកហើយអ្នកមិនដែលឃើញនាងញញឹមស្រស់ដូចពេលនេះទេ។ កេតឌីម៉ាដូចជាកំពុងកក់ក្ដៅណាស់ នៅពេលដែលម្ហូបម្ហានាងត្រូវបានក្រុមកងការពារពេញចិត្ត និងកោតសរសើរ ម្ល៉ោះហើយនាងបានញញឹមចេញពីបេះដូងខុសប្លែកពីស្នាមញញឹមដោយញញើតញញើម និងទើសទាល់គ្រប់គ្រាដែលនាងនៅក្បែរអ្នក។

កំពុងភ្លឹកភ្លាំងទៅលើស្នាមញញឹមរបស់ស្រស់ស្រី នាងស្រាប់តែងាកមកវិញ។ ក្នុងវិនាទីនោះរាមនរិន្ទមិនដឹងធ្វើម៉េចគេក៏កាន់តែសម្លឹងនាងភ្លឹកភ្លាំង។ ពេលនាងសម្លឹងចំគេ នាងរុះរោយទៅវិញនូវស្នាមញញឹម ដោយសារនាងនៅក្នាញ់ផងខ្មាសផងចំពោះសម្ដីសិទ្ធិគុណដែលថានាងជាស្រីរបស់គេ មិនមែនជាប្រពន្ធគេទេ។ តាមពិតរាមនរិន្ទបានឈរពីចម្ងាយតាមសម្លឹងនាងនៅឯចម្ការត្របែក មិនមែនមានន័យថាគេបានឮសម្ដីដែលសិទ្ធិគុណនិយាយទេ ប៉ុន្តែនាងបែរជាគិតថា គេឃើញបុរសក្មេងប្រមាថនាង ហើយគេនៅតែធ្វើហីទៀត។

ឃើញនាងលែងញញឹម កំលោះទៅជាទីទើរ គេដឹងថាការយល់ជម្រៅចិត្តស្រីៗមិនមែនងាយស្រួលទេ។ នរិន្ទលើកដៃធ្វើសញ្ញាដួសបាយបញ្ចូលមាត់ទៅកាន់នាង ហាក់ចង់ប្រាប់ថាគេចង់ឲ្យនាងមកបាយជាមួយ ប៉ុន្តែទោះបីយល់ន័យនោះហើយក្ដី ក៏ស្រីស្អាតធ្វើជាមិនឃើញហើយបែរខ្នងដួសបាយដាក់ចានហូបជុំជាមួយក្រុមអង្គរក្សធ្វើឲ្យនាយរឿនតាមសម្លឹងដោយហួសចិត្ត។

បុរសកូនប្រុសអ្នកនយោបាយដែលមិនដែលចេះយកចិត្តស្រីៗទៅជាមិងមាំង ព្រោះមិនដឹងថាតើហេតុអ្វីបានជានាងនៅងរង៉ក់យូរដល់ម្លឹង។ មិនចង់ឲ្យខ្មាសកូនចៅ និងគ្មានបទពិសោធន៍ខាងលួងស្រីៗផង គេក៏បែរក្រោយដើរតយង៉យទៅក្នុងបន្ទប់វិញតែម្នាក់ឯង។ នៅស្ដុកអាហារដែលមានទឹកមួយកែវរៀបទុករួចជាស្រេច អ្នកសម្លឹងកែវទឹកហើយសើចខឹកៗ និមិត្តនឹកឃើញដល់រាត្រីនៅAmandariដែលស្រីស្រស់ត្រូវចំណេះជិះកងងរហូតដល់ដេកលក់ស្លូកស្ដឹង។

"យើងស្រលាញ់ស្រីម្នាក់នេះអីម្លឹងៗ! គ្រាន់តែគេងរង៉ក់ខឹងបន្តិច យើងកើតជានៅមិនសុខមិនសាប់ធ្វើការអីលែងកើតទាំងអស់!"? គេគិតបណ្ដើរ ដៃរេរាំលើកុំព្យូទ័រសំណព្វបណ្ដើរ។

ខ្យល់បក់ត្រសៀកៗ  ហើយអាកាសធាតុក្ដៅស្អុះស្អាប់ពីពេលថ្ងៃ ប្ដូរមកជាត្រជាក់ ជាសញ្ញាថារាត្រីកាលបានបង្ហាញរូបរាងជាបណ្ដើរៗហើយ ។

ទ្វារបន្ទប់នៅតែមិនរបើកតាមការទន្ទឹងរង់ចាំរបស់ម្ចាស់ប្រុសសោះ។ គេចាប់ផ្ដើមខឹងមួម៉ៅ។

"កេតឌីម៉ា! នាងមិនសមថាយកលេសខឹងបន្តិចបន្តួចហ្នឹង ដើម្បីបែកកន្លែងគេងទេមែនទេ?"

គេក្រោកដើរយឺតឆ្ពោះទៅបន្ទប់អង្គុយលេងដែលមានរានហាលមួយលាតសន្ធឹងៗ...តាមរយៈវាំងននដែលប៉ើងរវិចៗតាមកម្លាំង ខ្យល់គេមើលឃើញនារីវាងរាវកំពុងឈរម្នាក់ឯងស្រូបខ្យល់អាកាសបរិសុទ្ធ។

ដូចរាល់ដង គេលូកដៃក្រសោបចង្កេះនាង៖

-នឹកអ្នកនៅចម្ការត្របែកហ្នឹងហ្អី?

ឌីម៉ាហួសចិត្ត...ទោះគេនិយាយលេងក្ដី និយាយមែនក្ដី នាងនៅតែមិនចង់ឲ្យរាមនរិន្ទរលើករឿងសិទ្ធិគុណពោលពាក្យលែបខាយ និងប្រមាថនាងនៅទីនោះទៀតទាល់តែសោះ។ ស្រស់ស្រីបញ្ចេញភាពមួហ្មងតាមពន្លឺភ្នែក។ នាងរក្សាការស្ងាត់ស្ងៀម បុរសនិយាយបន្ត៖

-ម្នាក់ហ្នឹងគួរសម! តាមអូនអត់បាន តែអាចធ្វើឲ្យស្រីស្អាតរបស់បង ខឹងដោយទាំងបងម្នាក់ទៀត!

រង្វង់ដៃគេឱបនាងតឹងជាងមុន តាមទំហំចិត្តស្រលាញ់ដែលកាន់តែធំឡើងៗ។ គេកាន់តែស្រលាញ់នាងនៅពេលដឹងថានាងគ្មានអ្នកផ្សេង ហើយពេលដែលនាងនៅស្ងៀម គេកាន់តែចង់ឲ្យនាងនិយាយ។ នរិន្ទជ្រមុជច្រមុះថើបថៃលើកញ្ចឹងកសរលោងរហូតដល់នារីរើបម្រះមិនបានសុខចិត្តផ្លាស់ទឹកមុខខឹងក្រញូវទៅជាសើចបែបមិនសុខចិត្ត។ នាងងាកក្រោយសម្លក់គេ ប៉ុន្តែមាត់ញញឹមបែបគ្មានក្នាញ់។ អ្នកប្រុសបានចិត្តណាស់ នាយឱនទៅខ្សឹបតិចៗដាក់នាង៖

-ឈប់ខឹងឬនៅ?

ស្រីស្រស់បង្ហាញទឹកមុខហួសចិត្ត នាងនិយាយតប៖

-អ្នកណាខឹង?

នាងលូកដៃបម្រុងបេះដៃគេចេញ តែរាមនរិន្ទដែលស្គាល់កាយវិការនាងស្ទើរគ្រប់សព្វបែបយ៉ាងហើយនោះ ម៉េចនឹងបណ្ដោយឲ្យនាងទៅណាឆ្ងាយបានមួយជំហានទៀតយប់ថ្មើរណេះទៅហើយ។គេនិយាយដោយឱបនាងជាប់ខ្លាចរបូតបាត់៖

-បើអត់ទេ! តោះទៅគេង យប់ហើយ!

នារីក្តាប់មាត់ នាងឆ្លើយតាមចរិតងរង៉ក់៖

-ខ្ញុំគេងនៅទីនេះហើយតើ !

រាមនរិន្ទក្រឡេកទៅតាមចង្អុលដៃស្រីស្អាត គេឃើញសាឡុងឈើវែងដែលសម្រាប់គេងមើលទូរទស្សន៍ ត្រូវបានរៀបចំក្រាលភួយ និងមានខ្នើយធំមួយទុកហើយជាស្រេច។ គេទើបតែដឹងថានាងមានបំណងគេចមកគេងនៅទីនេះពិតមែន។ កូនប្រុសអ្នកតំណាងរាស្ត្ររវៃភ្នែកមកសម្លឹងនាងដោយខ្សែភ្នែកគ្រឹតខ្នាញ់។ ភាពជាកូនប្រុសដែលត្រូវបានទំនើងតាំងពីតូចមក បានគ្របដណ្តប់មកវិញសាជាថ្មី។ គេងក់ក្បាលផ្ញក់ៗ រួចនិយាយរកនាងដោយទឹកមុខផ្ងាញ់ផ្ងាល៖

-បានតើ! ចង់គេងនៅហ្នឹង! មានអី!

គេលែងដៃពីនាង។ ក្រោមពន្លឺភ្នែកសង្ស័យរបស់នារី រាមនរិន្ទនាំកាយស្រស់សង្ហាទម្លាក់ទៅលើសាឡុងនោះ។ កេតឌីម៉ាសម្លក់គេស្មែរស្របពេលអ្នកប្រុសញាក់ចិញ្ចើមផ្ងាញ់៖

-ចាំអីទៀត? ក្រែងចង់គេងនៅទីនេះហ្អី?

គេដឹងហើយថានាងមិនអាចគេងនៅក្បែរគេក្នុងទីកន្លែងចំហកណ្តាលវាលបែបនេះបានទេ បានជាគេនិយាយឲ្យនាងទ័លច្រក។ ស្រីស្អាតធ្វើមុខក្រញូវ ប៉ុន្តែនាងប្តូរទៅជាសើចខឹកៗដោយសារបុរសចាប់ផ្តើមត្រូវចោមរោមដោយហ្វូងមូសហើយនាយស្ទុះក្រោកការពារខ្លួន។ តាំងពីតូចដល់ធំរបស់អ្នកប្រុសត្រកូលអ្នកនយោបាយមិនដែលស្គាល់ជីវភាពលំបាកវេទនាហាលភ្លៀងហាលខ្យល់ ម្ល៉ោះហើយកាយវិការដេញមូសរបស់គេល្អមើលគួរសមរហូតដល់ស្រីស្រស់ទៅជាអស់សំណើចសើចខឹកៗ។

គេក្រោកឈរសម្លឹងមកនាងហើយញញឹមស្រស់។ តាមពិតគេកំពុងឈ្លក់វង្វេងនឹងសំណើចរបស់ធីតាអ្នកបង្ហាញម៉ូត។ ជាលើកដំបូងដែលនាងញញឹមអស់ពីចិត្ត ញញឹមមែនទែន ហើយមិនមែនញញឹមដើម្បីតែលួងចិត្តនាយ។

រាមនរិន្ទឈានចូលទៅរកនាង បបូរមាត់គេនិយាយស្រាលៗ៖

-ល្អសើចណាស់ទៅ?

នារីបិទមាត់មកវិញ តែនាងទប់មិនបាននៅតែបន្តសើច ហើយលើកដៃខ្ទប់មាត់សើចតែម្តង។ នាងបែរក្រោយដើរចូលទៅក្នុងបន្ទប់ដោយមានបុរសលង់ស្នេហ៍ដើរទៅតាមពីក្រោយទាំងបេះដូងហោះ

ហើរ។ នារីរកបានប្រអប់ប្រេងម៉ុងតុលរួចក៏បែរមករកនរៈដែលឈរទ្រឹងសម្លឹងនាងដោយឥទ្ធិពលភ្លើងស្នេហ៍។ នាងខំទប់លែងសើច តែភាពរីករាយនៅតែលេចឡើងលើបបូរមាត់ស្រស់ប្រិមប្រិយ។តរុណីរុញច្រានខ្នងគេឲ្យផ្កាប់មុខទៅលើគ្រែ ហើយនាងលាបប្រេងថ្នមៗទៅកាន់ផែនសាច់បុរសអភិជនដែលពពួកមូសមិនធ្លាប់បានជាចំណីពីពេលមុនមក។

-គេងទៅ! ក្រែងលោកថាយប់ជ្រៅហើយហ្អី?

បុរសដែលបានចិត្តដោយសារបានស្រីស្អាតក្នុងកណ្ដាប់ដៃ ក៏បន្លឺមកវិញ៖

-និយាយរឿងឲ្យស្ដាប់ទៅអញ្ចឹង!

ឌីម៉ាចងចិញ្ចើម នាងនិយាយតិចៗ៖

-ស្ដាប់រឿង? មើលតែកូនក្មេង?

រាមនរិន្ទតមកវិញភ្លាម៖

-ចុះមនុស្សធំគេធ្វើអីវិញអញ្ចឹង?

កេតឌីម៉ាដឹងថាចូលស៊ងសម្ដីគេនាងប្រញាប់ក្រឡាស់សម្ដីវិញភ្លាម៖

-និយាយរឿងក៏បាន! តែនិយាយរឿងអីទៅ?

-រឿងអីក៏បាន និយាយមួយរឿងហើយមួយរឿងទៀតទៅ!

-ខ្ញុំមិនមែននាងឆេហរ៉ាសាត ទេ!

(Sheherazade បុត្រីច្បងរបស់មហាឧបរាជនៃរឿងនិទានមួយពាន់មួយយប់ដែលនាងបាននិទានរឿងថ្វាយព្រះចៅឆារីយ៉ា ដែលការនិទានរបស់នាងបានបង្កើតជាកម្រងរឿងរាប់រយនៃភាគនិទាន ១០០១យប់ដ៏ល្បីរបស់អារ៉ាប់។)

ដឹងហើយថានាងចង់និយាយថានាងមិនមែនចេះរឿងនិទានច្រើនដូចស្ត្រីដ៏ពូកែ Sheherazade តែបុរសនៅតែចង់ផ្ទាញ់ផ្ទាលនាង។ គេនិយាយទៀត៖

-អញ្ចឹងនិយាយរឿងនាង Sheherazadeហ្នឹងតែម្ដងទៅ!

តាមពិតគេគ្រាន់តែចង់ស្ដាប់សម្ដីនាង ចំណែកកេតឌីម៉ាក៏យល់ថា នាងស្រាប់តែចង់នៅជិតគេ និងប្រលែងលេងរបៀបនេះ។

ទោះបីនាងធ្លាប់ លះបង់បេះដូងឲ្យពាណិជ្ជកររដែកថៃបឈ្មោះKenប៉ុន្តែភាពស្និទ្ធស្នាលទាំងឡាយនៅតែមិនអាចប្រៀបស្មើនឹងរយៈពេលនៅជាមួយរាមនរិន្ទដ៏ខ្លីនេះទេ។ បុរសឈ្មោះKenប៉ិនប្រសប់ខាងយកចិត្តស្រីៗតាមរយៈសម្តីផ្អែមល្ហែម និងជូនវត្ថុអំណោយភ្ញាក់ផ្អើល ប៉ុន្តែចុងក្រោយគេគ្មានសូម្បីតែចិត្តស្មោះបន្តិច។

ចំណែកបុរសម្នាក់នេះវិញ សម្តីផ្អែមក៏មិនងាយនិយាយ ធ្វើការសឹង២៥ម៉ោងក្នុងមួយថ្ងៃ ហើយនៅជាមួយគេ តែងតែជួបរឿងថ្មីចម្លែកៗ តក់ក្រហល់ស្ទើរតាមមិនទាន់ ចុះហេតុអ្វីនាងបែរជាមានអារម្មណ៍ថាអន់ចិត្តជាខ្លាំងជាមួយសម្តីដែលសិទ្ធិគុណបានឌឺដងនៅចម្ការថានាងមិនមែនជាភរិយារបស់គេ?

"ឯងប្រហែលស្រលាញ់គេមែនហើយកេតឌីម៉ា"។

នារីគិតបណ្តើរផ្តោតភ្នែកសម្លឹងរាងកាយមាំទាំសមស្មើនឹងទឹកចិត្តដ៏ទូលាយរបស់ម្ចាស់វាដែលកំពុងទ្រោបថ្ពាល់មុខរង់ចាំស្តាប់រឿងនិទានចេញពីបបូរមាត់ស្រីស្រស់។ ឥតមានគេបញ្ជានាង ស្រាប់តែមានអារម្មណ៍ចង់ថ្នាក់ថ្នមគេដោយលើកដៃទាំងពីរច្រូបាច់ធ្វើសរសៃឲ្យគេទាំងមិនដឹងខ្លួន។ បបូរមាត់ទន់ល្មើយចាប់និយាយមួយៗក្នុងពេលតំណាលគ្នា៖

-រឿងផ្លែប៉ោមបីណា! នេះជារឿងមួយដែលស្ថិតក្នុងចំណោមរឿងនិទានរបស់ Sheherazadeដែរ!

នរៈសំងំស្ងៀមក្រោមការថ្នាក់ថ្នមរបស់ធីតាកំពូលស្នេហ៍។ ទោះបីជាបុរសរឹងប៉ឹងបែបណា ទីបំផុតគេនៅតែចុះចាញ់ក្រោមម្រាមដៃទន់ល្មើយរបស់ស្រីស្អាត គេទើបតែដឹងថា អញ្ចឹងហើយបានជាព្រះចៅឆារីយ៉ាស្តាប់រឿង១០០១រាត្រីចប់កាលណា បំភ្លេចបាននូវអតីតកាលដ៏ឈឺចាប់ហើយងាកមកស្រលាញ់នាងSheherazade។

សំឡេងនាងSheherazadeទី២ កេតឌីម៉ាបន្លឺមួយៗបណ្តោតតាមវាយោរាត្រី៖

-កាលពីព្រេងនាយមានបុរសអ្នកជំនួញម្នាក់រស់នៅក្រុងបាដាត។ គាត់មានភរិយាវ័យក្មេងប្រកបដោយរូបឆោមស្រស់ និងកូនប្រុសតូចៗពីរនាក់។ ថ្ងៃមួយនាងភរិយាធ្លាក់ខ្លួនឈឺធ្ងន់អង្វរប្តី ចង់បានផ្លែប៉ោមបរិភោគ តែនោះមិនមែនជារដូវប៉ោមមានផ្លែទេ។ បុរសនោះដើររកទិញគ្រប់ច្រកល្ហកនៅតែរកមិនជួប។ គាត់ក៏ត្រឡប់មកផ្ទះវិញអង្គុយសញ្ជប់សញ្ជឹងសម្លឹងភរិយាដែលរាងកាយស្គមស្គាំង បាយលែងនឹក ទឹកលែងស្រេក។ ទីបំផុតគាត់សម្រេចចិត្តទៅកាន់ទីក្រុងមួយផ្សេងទៀតតាមដែលគេប្រាប់ថានៅទីនោះមានសួនពិសេសមួយសម្រាប់តែព្រះរាជា។ បុរសនោះប្រើពេលអស់បី

ថ្ងៃទើបទៅដល់ ហើយគាត់ប្រើគ្រប់វិធីក្នុងការអង្វរលួងលោមអ្នកថែសួនទំម្រាំអាចទិញបានប៉ោមបីផ្លែថ្លៃ៣ដំឡឹងមាស។ បន្ទាប់មកគាត់ត្រូវប្រើពេល៣ថ្ងៃទៀត ដើម្បីត្រឡប់មកផ្ទះវិញ។ ទំរាំគាត់មកដល់ភរិយាគាត់សន្លប់ស្តូកស្ដឹងលែងកម្រើកទៅហើយ។ គាត់យំសស្រាក់និយាយជាមួយស្ត្រីមានជំងឺនោះថា "អូនឆាប់ក្រោកឡើង ព្រោះបងរកបានផ្លែប៉ោមហើយ" តែស្ត្រីនោះនៅតែមិនកម្រើក។ នាងនៅសល់តែដង្ហើមផ្ដឹកៗ។ ដោយពិបាកចិត្តខ្លាំងពេក ស្អែកឡើងបុរសនោះក៏ចាកចេញពីផ្ទះទៅសំកុកនៅហាងទំនិញគាត់។ រហូតដល់ថ្ងៃជិតលិច គាត់ឃើញទាសករស្បែកខ្មៅម្នាក់ កាន់ផ្លែប៉ោមមួយផ្លែដើរកាត់មុខហាង។ គាត់មានមន្ទិលក្នុងចិត្តក៏ឃាត់ដំណើរទាសករហើយសួរថាតើរដូវនេះទៅហើយ គេទៅរកផ្លែប៉ោមពីណាមកបាន។ ទាសករសម្បុរខ្មៅមិនបង្អង់ឆ្លើយតបវិញភ្លាមៗថា ផ្លែប៉ោមនេះជារបស់សហាយខ្ញុំ នាងមាយាឲ្យប្ដីនាងទៅរកទិញដល់ទៅព្រះរាជវាំងបានតែបីផ្លែ ខ្ញុំជួបនាងព្រឹកនេះក៏យកមួយផ្លែមកទៅ។

កេតឌីម៉ានៅស្ងៀមបន្តិចទើបពោលសួរបុរសដែលនៅស្ងៀមសំងំស្ដាប់៖

-ចុះលោកគិតថាអ្នកជំនួញនោះគិតយ៉ាងណាដែរ?

រាមនរិន្ទមិនឆ្លើយគេបែរជាពេលបង្ខំនាង៖

-និយាយតទៅទៀតទៅ!

ស្រស់ស្រីដឹងថារឿងនិទាននេះកំពុងទាក់ចិត្តគេបាន ម្ល៉ោះហើយនាងនិយាយបន្ថែម៖

-បុរសនោះឮហើយទ្រាំមិនបានក៏ស្រូតរូតបិទហាងត្រឡប់មកផ្ទះវិញ។ ដោយសារតែពាក្យពេចន៍ផ្អែមល្ហែមតម្លួញតម្អែររបស់គាត់ប៉ុន្មានថ្ងៃមកនេះ នារីជាភរិយាបានធូរស្បើយផ្នែកផ្លូវចិត្ត និងចាប់ផ្ដើមបើកភ្នែកដឹងខ្លួនវិញ។ ប្ដីនោះមកដល់បន្ទប់មិនគិតខ្វល់នឹងសុខភាពភរិយាបែរជាងាកមើលរកផ្លែប៉ោមទាំងបី ហើយក៏ឃើញនៅសល់តែពីរទេ។ គាត់សួរនាងភ្លាមថា តើផ្លែប៉ោមមួយទៀតទៅណាហើយ។ នារីនោះឆ្លើយខ្សាវៗថានាងមិនដឹងទេ។ បុរសដែលជឿងប់ពាក្យទាសករក៏ហូតដាវកាប់នាងជាច្រើនកំណាត់ដោយភ្លើងប្រច័ណ្ឌ ហើយក៏ច្រកសពនោះចូលទៅក្នុងហិបយកទៅបណ្ដែតតាមទឹក។ លុះចប់ការងារនោះគាត់វិលមកផ្ទះវិញ តាមផ្លូវព្រៃប្រទះឃើញកូនប្រុសច្បងកំពុងពួនយំម្នាក់ឯង គាត់សួរថាម៉េចមិនទៅផ្ទះតែកូននោះប្រាប់ថាខ្លាចម្ដាយវាយ ដោយសារវាបានលួចយកប៉ោមមួយផ្លែទៅកាន់លេង ហើយត្រូវទាសករស្បែកខ្មៅម្នាក់ដណ្ដើមយកទៅបាត់។ បុរសនោះឮហើយមានវិប្បដិសារីជាខ្លាំង ចុងក្រោយនៅពេលព្រះរាជាប្រទះឃើញហិបនោះគាត់ក៏ចូលទៅសារភាពកំហុស។ នេះហើយរឿងផ្លែប៉ោមបី។

រាមនរិន្ទឃើញនាងនៅស្ងៀមលែងនិយាយ គេប្រែខ្លួនបែរមកគេងផ្ងារ។ អ្នកឃើញធីតាប្រកប ដោយទឹកមុខទន់ភ្លន់សម្លឹងមកខ្លួនវិញ។ អ្នកញញឹមសួរនាងតិចៗ៖

-បុរសនោះល្ងង់ណាស់មែនទេ?

នារីញញឹមតិចៗតែនាងនៅស្ងៀមមិនតប។ បុរសចាប់ដៃនាងថ្នមៗហើយនិយាយបន្ថែម៖

-ហ្នឹងហើយ ដែលគេថាចេះតែស្រលាញ់ តែមិនយល់ចិត្ត! មនុស្សស្រលាញ់គ្នាតែមិនចេះទុកចិត្ត គ្នា!

ស្រីស្រស់នៅតែមិនចេញស្តី រហូតដល់បុរសទាញនាងឲ្យប្រេះមកក្បែរហើយលូកត្រកងឱបប្រាណ នាងពីក្រោយជាប់លង្វែកទ្រូង នាងក៏អត់រើបម្រះចេញដែរ ព្រោះចិត្តនាងកំពុងវិលវល់ជុំវិញពាក្យ ពេចន៍ចុងក្រោយរបស់គេ។

នាងប្រាប់ខ្លួនឯងតិចៗ៖

"រាមនរិន្ទ! ខ្ញុំធ្លាប់ទុកចិត្តគេហើយ! ខ្ញុំធ្លាប់ស្រលាញ់គេ ហើយស្រលាញ់ជាទីបំផុត! ខ្ញុំមានចិត្តត្រង់ ចំពោះស្នេហា ខ្ញុំអាចធ្វើអ្វីបានទាំងអស់សម្រាប់មនុស្សដែលខ្ញុំស្រលាញ់ ដូចគ្នានឹងបុរសអ្នកជំនួញ ដ៏កម្សត់នោះដែរ! គេជិះសេះ៦យប់៦ថ្ងៃគ្រាន់តែដើម្បីរកផ្លែប៉ោមបីផ្លែមកឲ្យភរិយា ចំណែកខ្ញុំ សូម្បីកិត្តិយសមនុស្សស្រីក៏ខ្ញុំលះបង់បានដើម្បីគេ ខ្ញុំធ្វើរឿងដែលមិនដែលគិតថាខ្លួនឯងហ៊ានធ្វើ! ខ្ញុំ បោកប្រាស់លោក ហើយក្លាយជាមនុស្សមានកលមានល្បិចដើម្បីតែផ្គាប់ចិត្តគេ។ ទីបំផុត គេមិន ដែលស្រលាញ់ខ្ញុំផង តើលោកយកការទុកចិត្តមកនិយាយធ្វើអី បើលោកមិនដែលឆ្លងកាត់ការឈឺ ចាប់ដូចដែលខ្ញុំធ្លាប់ឆ្លងផងនោះ!"

នាងស្រក់ទឹកភ្នែកសស្រាក់ឲ្យតែនឹកដល់នាយKen ពាណិជ្ជករដែកថែប។ នាងនឹកថានារីក្នុងរឿង និទាន ទោះស្លាប់ក្រោមដៃបុរសដែលស្រលាញ់នាង ក៏នៅគ្រាន់បើជាងខ្លួនដែលត្រូវរស់នៅទាំង ឈឺចាប់ហើយដឹងថាគេកំពុងក្បត់ខ្លួនទាំងភ្នែកស្រស់។ នាងព្យាយាមទប់ក្តីសង្វេគដែរ ប៉ុន្តែនាង ទប់មិនកើតសោះ។ នៅពេលដែលគេលូកដៃមកក្រសោបម្រាមទាំង១០របស់នាងសាជាថ្មី នាង កាន់តែនឹកឃើញដល់សម្តីសិទ្ធិគុណនៅជាន់ខាងក្រោមកាលពីល្ងាច។

"រាមនរិន្ទ! នៅទីបំផុត ខ្ញុំក៏នៅតែជាស្រីរបស់លោក! លោកជាអ្នកមានប្រាក់ ជាអ្នកមានការងារធំដុំ ជាប់ខ្លួន រឿងស្នេហាចំពោះលោកគ្រាន់តែជារឿងកំប៉ិកកំប៉ុកដូចតែនាយKenអញ្ចឹងដែរ! ចុះលោក មកធ្វើល្អចំពោះខ្ញុំធ្វើអី?"

មិនឃើញសំឡេងនាងលាន់ថាម៉េចទៀតសោះបុរសអភិជនសួរមកបន្ត៖

-ចេះរឿងអីទៀតឌីម៉ា?

កេតឌីម៉ាមិនឆ្លើយ ព្រោះខ្លាចគេឮសូរសំឡេងរអាក់រអួលរបស់នាង ដោយនាងគ្រវីក្បាលជំនួសវិញ។

ទោះបីរាមនរិន្ទ ជាបុរសតែម្នាក់គត់ដែលបានរួមរស់ជិតស្និទ្ធនឹងនាង ប៉ុន្តែតើមានន័យអ្វីទៅគេជាអភិជនគេមានរឿងអីដែលមើលមកនាងថាជាសំខាន់នោះ? បើនាងយកពាក្យផ្អែមល្ហែមរបស់គេក្នុងយប់នេះមកទុកជាការពិតនោះនាងនឹងខ្មាសខ្លួនទៅថ្ងៃក្រោយជាមិនខាន ។

ភាគទី៣៤

ឌីម៉ាដកអារម្មណ៍ចេញពីការត្រិះរិះ នាងងាកមុខចេញជាមួយនឹងពាក្យអស់សង្ឃឹមមួយឃ្លាដែលកំពុងចាក់ឆ្កឹះក្នុងចិត្ត "បើរាមនរិន្ទមិនមែនជាអ្នកមាន បើគេមិនមែនជាកូនប្រុសតំណាងរាស្រ្ត តើល្អយ៉ាងណាទៅ? នាងនឹងអាចយកខ្លួនទៅផ្ទឹមនឹងគេខ្លះ តែជាតិនេះគ្មានទេក្តីសង្ឃឹមនោះ។"

ទឹកភ្នែករមៀលធ្លាក់មកយ៉ាងរហ័ស... ឌីម៉ាខំងាកមុខចេញហើយទប់សំឡេងខ្សឹកខ្សួល... ដើម្បីកុំឲ្យរាមនរិន្ទមើលឃើញ... ក្នុងពេលដែលនាងទទួលអារម្មណ៍ថា ដៃគេកំពុងតែក្តោបម្រាមទាំង ១០ របស់ខ្លួនណែនជាងមុន ...។...

សំឡេងរាមនរិន្ទ បង្ហាញចេញនូវអារម្មណ៍មិនរីករាយ ៖

- យំទៀតហើយ?.

ឌីម៉ាស្រវាដកដៃចេញពីប្រអប់ដៃគេ ដើម្បីជូតទឹកភ្នែក ស្របពេលបបូរមាត់កំលោះត្រកូលហង្សក្រោកក្រេះដើរទៅរកបង្អួចទាំងមិនខ្ចីងាកមកសម្លឹងនាង។

ពីក្រោយខ្នងធំមាំនោះ នាងដឹងថាគេចាប់ផ្តើមមិនសប្បាយចិត្តទៀតហើយ។ ធីតាក្រោកឃីតៗ ហើយខំទប់ភាពសោកសៅរបស់ខ្លួនដើរទៅឈរមួយជំហានពីក្រោយអ្នកប្រុស។ នាងឮគេនិយាយតិចៗតែក្នុងន័យទោមនស្សមកកាន់នារីដែលភ្នែកទាំងគូរកំពុងព្រិលរកាំដោយទឹកភ្នែក។

-រស់នៅជាមួយ រាមនរិន្ទ វេទនាណាស់ទៅកេតឌីម៉ា?

ឌីម៉ាដែលតាំងចិត្តថាមិននិយាយជាមួយគេច្រើនទេ មិនយកសំដីផ្អែមល្ហែមរបស់គេមកទុកក្នុងចិត្តទេ ពេលនោះនាងហាក់លែងចង់គ្រប់គ្រងអារម្មណ៍ខ្លួនឯងទៀត។ នៅចន្លោះរវាងអតីតកាលដ៏ឈឺ

ចាប់ និងភាពកក់ក្ដៅថ្មីមួយដែលគ្មានស្រីណាដែលថាអាចមិនរំភើបចិត្តនេះ នាងកំពុងពិបាកក្នុងការគេចវេះ ហើយដែលសំខាន់ជាងគេក្នុងពេលនេះ គឺនាងរឹតតែមិនដាច់ចិត្តឲ្យគេខូចចិត្តទេ។ នាងគ្រវីក្បាលយឺតៗជាហេតុឲ្យដោយទឹកភ្នែកបន្តហូរសាជាថ្មី...។

អ្នកប្រុសបែរក្រោយដោយបញ្ចេញភាពអាក់អន់តាមពន្លឺភ្នែក ការអំណត់បែបណាវមែងមានទីកំណត់របស់វា។ ទោះបីបុរសនេះមានចិត្តទូលាយ ក៏កេតឌីម៉ាទីបំផុតនៅតែសាំញ៉ាំរហូតដល់គេគិតថា នាងជាអ្នកណាមកពីណាក៏មិនដឹង ដែលមិនយល់ថាហេតុអ្វីគេមកលង់ស្នេហ៍នាងទាំងងងឹតងងល់ និងចំណាយពេលខ្ជីខ្ជាជាមួយនាងដល់ថ្នាក់នេះ។ ប៉ុន្តែនៅពេលដែលងាកមកប្រទះឃើញវង្វង់មុខពងក្រពើកំពុងឈ្ងោកយំសស្រាក់ពីក្រោយខ្នងខ្លួនហេតុអីចិត្តប្រែជាទន់វិញភ្លាមៗដោយគ្មានលក្ខខណ្ឌ។ អ្នកប្រុសឈរសម្លឹងមុខនាងដោយមិនចេញស្តី ជាមួយសំនួរលេចឆ្លោក្នុងចិត្ត៖

"រាមនរិន្ទអើយរាមនរិន្ទ! គ្រាន់តែឃើញទឹកភ្នែកនាង ឯងចាប់ផ្តើមឆ្កួតបាត់ទៅហើយ! តទៅឯងរស់នៅគ្មានគេម្តេចបានទៅ?"

អ្នកដៀងភ្នែកសម្លឹងទៅដៃទាំងពីរដែលញ័រទទ្រើកហើយក្តាប់លើសំពត់ផ្កាទាំងសងខាង...កេតឌីម៉ានៅតែជាស្រីស្លូតត្រង់ម្នាក់ដូចដែលព្រលប់មួយនៅកោះបាលីដែលនាងឃើញក្រុមនាយBirdវាយដំអ្នកស្រីកុលាប។

អ្នកឃើញប្រអប់ថ្នាំម៉ុងតុលនៅក្តាប់ជាប់ក្នុងម្រាមទាំង៥នៃដៃឆ្វេងរបស់នាងនៅឡើយ។ អ្នកនឹកសង្វេគក្នុងចិត្តថា មនុស្សស្រីដែលទន់ភ្លន់ មានអត្តចរិតល្អ ជួយយកអាសាអ្នកផង មិនចេះប្រើមាយា មិនចេះលាក់ពុត ហេតុអ្វីចុងបញ្ចប់មានភព្វវាសនាត្រឹមតែជានារីបម្រើអារម្មណ៍បុរសដោយគ្មានភ្លេងការបែបនេះ។

នាងមិនងើបមុខមកប្រឈមនឹងអ្នកទេ តែទឹកភ្នែកដែលស្រក់មកលើកម្រាលឥដ្ឋធ្វើឲ្យបុរសអភិជននឹកដល់រាត្រីឃោរឃៅនៅ jayapuraដែលអ្នកដាច់ចិត្តទន្ទ្រានរាងកាយនាង ដោយប្រើកម្លាំង និងអំណាចក្នុងសភាពនាងគ្មានពេលសូម្បីតែបកស្រាយ និងការពារខ្លួន។

ប្រុសស្អាតឈានចូលទៅរកស្រីស្រស់.. គេពោលសួរទាំងទឹកមុខស្លូត..៖

- ស្អប់បងណាស់... មែនទេ ?

វាចាគេទៅជាស្រពោន និងហាក់ដូចជាមនុស្សដែលមានវិប្បដិសារីហួសហេតុ លើទង្វើអ្វីមួយរបស់ខ្លួន ធ្វើឲ្យកេតឌីម៉ាមិនអាចទទួលយកបានឡើយ។

- អត់ទេ!... (ឪម៉ាភ្លាត់មាត់ដោយរអាក់រអួលព្រោះលែងបញ្ឆាខ្លួនឯងបានទៀតហើយ)

នាងឈប់ស្ងៀមដោយពាក្យពីរម៉ាត់យ៉ាងខ្លី... តែក៏ល្មមគ្រប់គ្រាន់ឲ្យរាមនរិន្ទដឹងថា... នាងរស់នៅក្បែរគេមិនមែនគ្មានសេចក្ដីសុខទេ... ហើយនាងក៏មិនប្រាកដថា "ស្អប់ខ្ពើម" គេនោះដែរ ។

បុរសញញឹមទាំងជះភាពស្រពោនតាមពន្លឺភ្នែក។ សាជាថ្មី គេឱបនាងហើយនិយាយបន្ត៖

-សន្យាណា! ឈប់ធ្វើចរិតឆ្កួតៗ ឈប់យំ ឈប់គេច ឈប់រញ៉េរញ៉ៃទៀតបានអត់?

តើមានន័យថាម៉េច ?.

ឪម៉ាដណ្ដឹងសួរខ្លួនឯងស្ងាត់ៗក្នុងចិត្ត... គ្មានចម្លើយច្បាស់លាស់ប្រាប់នាងទេ ថារាមនរិន្ទចង់បានអ្វីពីសំនួរចុងក្រោយនេះ... តែអ្វីដែលនាងដឹងច្បាស់ក្នុងយប់នេះ គឺថា... នាងចាប់ផ្ដើមរំភើបចិត្តចំពោះមុខប្រុសម្នាក់នេះ... ហើយធ្វើចិត្តរឹងចំពោះគេតទៅទៀតលែងកើតហើយ... នាងទទួលស្គាល់ថា... ចង់ឮសំដីគេណាស់... ចង់ឲ្យគេពោលពាក្យល្អៗមកកាន់នាងបែបនេះរហូតទៅ... ហើយក៏ចង់រស់នៅក្នុងរង្វង់ដៃគេបែបនេះគ្រប់ពេលវេលា ។

**វគ្គទី១៧**

**អន្ទាក់គ្រោះថ្នាក់នៅ ភូរីខាន់**

នៅជាន់ទី២នៃទីសំណាក់ដដែលអភិជនក្មេងសិទ្ធិគុណកំពុងអង្គុយគងអន្ទាក់ខ្លាស្ដាប់សេចក្ដីរាយការណ៍របស់ជនពុកចង្កាដែលមុននេះបានស្វាគមន៍រាមនរិន្ទនៅឯកំពង់ផែសាមី។

បុរសក្មេងមានទឹកមុខអំនួតដោយសារថាគ្រប់យ៉ាងនៃគម្រោងការខ្លួនហាក់កំពុងវិវត្តន៍ទៅដោយរលូន ចំណែករាមនរិន្ទបុរសខ្លាំងដែលអ្នករួមជំនាន់នានាតែងតែញញើតក៏កំពុងស្ថិតនៅក្នុងគន្លងខ្លួនចាត់ចែងឲ្យដែរ។

បុរសពុកចង្កានិយាយតិចៗដោយទឹកមុខលិបលះ

ថៅកែគុណ! ការងារជិតបានសម្រេចហើយ! ពេលស្រីស្អាតបានទៅលោក លោកត្រូវងាកមកគោរព សន្យាពីដំបូងរបស់ពួកយើង!

សិទ្ធិគុណ ហារមាត់សើចបញ្ចេញភាពរីករាយ និងទំនុកចិត្តគេនិយាយដោយមិនសម្លឹងមុខគូសន្ទនាតែបែរជាសម្លឹងទូរសព្ទដៃដោយសាររូបថតធីតាបង្ហាញម៉ូតកំពុងរេរាំលើអេក្រង់នោះជានិច្ចចាប់ពីថ្ងៃដែលនាងដើរពត់ពេនលើឆាកអាស៊ីហ្គាឌិន។

បុរសក្មេងពោល៖

-ត្រឹមតែសាលារៀនប៉ុន្មានខ្នង និងប្រាក់ទ្រទ្រង់មន្ទីរពេទ្យរបស់ពួកលោក វាអត់បញ្ហាទេសម្រាប់ខ្ញុំ! លោកមិនចាំបាច់និយាយម្ដងហើយម្ដងទៀតទេអូណ៎រ! ត្រូវចាំថា ឲ្យតែរាមនរិន្ទព្រមយកឥន្ទប្បដិមាក្លែងក្លាយនោះហើយ ចេញទៅភ្នំពេញវិញពេលណា កុលសម្ព័ន្ធលឿងរបស់ពួកលោកមិនចាំបាច់ឆ្លងទៅរៀនសាលារបស់កុលសម្ព័ន្ធផ្សេងទេ! ហើយក៏មិនចាំបាច់ចេញទៅព្យាបាលជំងឺរហូតដល់សាមីដែរ!

ជនពុកចង្កាបង្ហាញភាពស្រស់ស្រាយលើផ្ទៃមុខ។ សិទ្ធិគុណដឹងថាទោះបីក្រុមនេះជាក្រុមប្រដាប់អាវុធហើយជាអម្បូរជនជាតិដើមចាស់ជាងគេនៅតំបន់នេះ ប៉ុន្តែពួកគេនៅតែគ្មានប្រាជ្ញាគ្រប់គ្រាន់ក្នុងការអភិវឌ្ឍន៍ការរស់នៅរបស់ពលរដ្ឋក្នុងមូលដ្ឋានគេទេ។ សេចក្ដីត្រូវការសព្វបែបយ៉ាងនៅតែគំរាមកំហែងការរស់នៅរបស់ពួកគេរហូតធ្វើឲ្យកុលសម្ព័ន្ធខ្លះហ៊ានបង្កជាក្រុមជាពួក លាក់កំបាំងពីរដ្ឋាភិបាលក្រុងហ្សាកាតាដើម្បីប្រតិបត្តិល្មើសផ្សេងៗជាប្រយោជន៍ដល់ក្រុមខ្លួនជារឿយៗ។ ដូច្នេះហើយនៅក្នុងគម្រោងការដែលបានព្រមព្រៀងជាមួយពាណិជ្ជករKen បុរសទាំងពីរបានសម្រេចចិត្តក្នុងការប្រើប្រាស់ក្រុមកុលសម្ព័ន្ធភ្នំទាំងនេះឲ្យបង្វែរទិសដៅរាមនរិន្ទដោយយកឥន្ទប្បដិមាក្លែងក្លាយជានុយ។

មធ្យោបាយព្រួញមួយបាញ់សត្វពីរ គឺធ្វើឲ្យនាយKenមានពេលចេញទៅកោះស្មៅលឿងមុនដើម្បីស្វែងរកលោករាទូ ឯរាមនរិន្ទនៅទីនេះបន្តដើម្បីទិញយកវត្ថុក្លែងក្លាយ ចំណែកស្រីស្រស់ត្រូវបានទៅលើអភិជនឈាមរាវដែលកំពុងអន្ទះសាចង់ក្រេបលំអងផ្កា។

ដោយស្រមៃថាផែនការខ្លួន និងឈានដល់ទទួលបានលទ្ធផលឆាប់ៗមិនខាននោះ អភិជនកូនកាត់សួរមួយៗទៅកាន់ជនពុកចង្កា៖

-អូណ៎រ! លោកគិតថារាមនរិន្ទចូលអន្ទាក់យើងស្រួលៗអញ្ចឹងអត់?

បុរសពុកចង្កាតបវិញដោយញញឹម៖

-តាមធម្មតាគឺមិនងាយទេ! តែចេះថៅកែគុណវៃឆ្លាត បានប្រើឥន្ទប្បដិមាជាអន្ទាក់! បើថៅកែរាមចង់បានរបស់នោះខ្លាំងពេក គេច្បាស់ជាភ្លេចប្រុងប្រយ័ត្នហើយ! អញ្ចឹងបានជាខ្ញុំណាត់ពួកគេឲ្យទៅមើលបដិមានៅលើភ្នំ គេព្រមភ្លាមអត់មានប្រកែកទេ!

សិទ្ធិគុណញញឹមស្រស់ តែគេនៅតែបន្តសួរតបវិញ៖

-ចុះលោកគិតថាពេលនិយាយពីលក្ខខណ្ឌគេនឹងព្រមជាមួយលោកដែរ?

បុរសហិណ្ឌូសើចរលាក់៖

-ក្រែងគេខំលេចវាលចូលព្រៃដើម្បីតែរបស់ហ្នឹងមែនទេ?

សិទ្ធិគុណងក់ក្បាលផ្ងក់ៗ៖

-យើងចាំមើលសិនទៅ! តែបើគេចង់កិកកុក! ខ្ញុំនៅសល់មួយក្បាច់ទៀតកំដរគេ! លោកអូណ័រត្រូវត្រៀមទាហានឲ្យហើយទៅ! បើបង្អែមមិនចង់ឲ្យគេស្គាល់ថ្នាំខ្លាំងវិញ!

សូរមាន់រងាវឮល្វើយៗ... ជាសញ្ញាថាព្រឹកព្រហាមនៃថ្ងៃថ្មី បានបង្ហាញរូបរាងជាបណ្តើរៗហើយ ។

ស្រស់ស្រីឌីម៉ាចេញពីបន្ទប់ អើតសម្លឹងទៅជាន់ក្រោមបង្អស់។ នាងឃើញរាម នរិន្ទឡើងរថយន្តហ្សីបយោធាមួយ ដោយមានអង្គរក្ស ខ្ពស់ស្រាវអមដំណើរ និងមានតែកុងឡានជាមនុស្សចម្លែកមុខមិនធ្លាប់ឃើញពីមុនមក។ ចំណែកបុរសពុកចង្កាឈ្មោះអូណ័រដែលនាងបានឃើញកាលពីនៅកំពង់ផែសាមីឡើងជិះលើរថយន្តមួយផ្សេងទៀត ដោយមានកងទាហានពីរនាក់តាមអមដំណើរផងដែរ។

នារីលះរលាំងដើរទៅបន្ទប់ទទួលភ្ញៀវ ដែលក្រុមកងការពារខ្លះរបស់រាមនរិន្ទនៅទីនោះនៅឡើយ។ពួកគេកំពុងហូបបាយ និងទស្សនាទូរទស្សន៍ដោយរីករាយ។ ធីតាយើងរួសរាន់ពោលសួរនាយBirdដែលកំពុងពមបាយមួយដុំធំទៅក្នុងមាត់៖

-បងBird! ហេតុអ្វីពួកបងនៅហ្នឹងទាំងអស់គ្នា?

នាយអង្គរក្សបង្កប់ដឹងហើយថានារីចង់និយាយថាហេតុអ្វីបណ្តោយឲ្យចៅហ្វាយទៅជាមួយជនពុកចង្កាតែពីរនាក់អង្គរក្សរឿន ប៉ុន្តែគេតបមកវិញបែបព្រងើយ៖

-មកពីអ្នកប្រុសមិនឲ្យទៅហ្នឹងហើយ!

នារីគ្រោប់ភ្នែករិះគិត។

"គេដូចជាមិនដែលស្គាល់បុរសឈ្មោះអូណ័រនោះពីមុនមកផង។ ហេតុអីក៏គេទុកចិត្តបុរសពុកចង្កានោះដល់ម្លឹង? កាលពីយប់គេថាគេត្រូវទៅមើលរបស់សំខាន់មួយនៅលើភ្នំជាមួយក្រុមកុលសម្ព័ន្ធ ចុះហេតុអ្វីគេយកតែអង្គរក្សរឿនទៅ?"

ហាក់យល់ចិត្តនាងនាយបន្លំខ្លួនធ្វើជានិយាយលេងបន្លំមែន៖

-កុំព្រួយអី! តាមមើលប្រហែលជាអ្នកប្រុសត្រូវទៅមើលរបស់សំខាន់ដែលមិនចង់ឲ្យពួកខ្ញុំឃើញ!

នាងយល់ហើយថានាយBirdចង់សំដៅដល់ឥន្ទប្បដិមា ប៉ុន្តែរបស់នោះក្រែងនៅជាមួយជនឈ្មោះរ៉ាទូនៅឯកោះស្មៅលឿង ម៉េចក៏មកនៅទីនេះទៅវិញ? ទោះបីយ៉ាងណានាងខំញញឹមគួរសមដាក់ក្រុមកងការពារហើយ បែរខ្លួនចាកចេញទៅក្រៅវិញ។

នាងគិតយ៉ាងណាក៏គិតមិនយល់ដែរថា រាមនរិន្ទដែលមកដល់កំពង់ផែសាមីភ្លាមត្រូវជនហិណ្ឌូមកស្ទាក់ផ្លូវរាក់ទាក់នោះកាលពីម្សិលមិញបានទៅជួបពួកគេនៅឯកុលសម្ព័ន្ធធំហើយទទួលបានដំណឹងពីឥន្ទប្បដិមា។

ដំបូងគេក៏នឹកចម្លែកចិត្ត ប៉ុន្តែដោយសារក្រុមនោះបានរៀបល្បិចទុកជាមុនដោយមាននាយKenនិងសិទ្ធិគុណនៅពីក្រោយ ដូច្នេះដំណើរការណ៍របស់គេមិនអាចថ្លោះធ្លោយបានឡើយ។ មុនពេលគេអាចធ្វើឲ្យរាមនរិន្ទព្រមមកតាមដល់ភូមិភូរីខាន់ និងស្នាក់នៅបន្តទីនេះ ទាល់តែគេអាចធ្វើឲ្យនាយជឿថា ឥន្ទប្បដិមាប្រាកដជាត្រូវបានប្លន់ពីលោករ៉ាទូនៅតាមផ្លូវវិលពីចាយ៉ាពូរ៉ា ហើយដោយសារនាយKenបានដឹងប្រវត្តិច្រើនទាក់ទងជាមួយវត្ថុនោះ គេបានប្រាប់ទៅលោកអូណាវ៍ឲ្យសូត្រទៅឲ្យរាមនរិន្ទស្តាប់រហូតដល់រាមនរិន្ទជឿថា បុរសហិណ្ឌូដែលដឹងប្រវត្តិវត្ថុបុរាណខ្មែរជ្រៅដល់ម្លឹងមិនសមថាគ្មានវត្ថុនោះក្នុងដៃទេ។

ចំណែកវត្ថុដែលមេកុលសម្ព័ន្ធឈ្មោះរ៉ាទូមានក្នុងដៃកាលនៅសណ្ឋាគារWinter Jayapura តើជារបស់ពិត ឬក្លែងក្លាយនៅមិនទាន់មានអ្នកណាហ៊ានអះអាងទេ ដូច្នេះហើយការចូលស៊ើបដល់ឫសគល់ គឺជាការងារអាទិភាពនៅទីនេះ។ ថ្វីត្បិតគេគិតដែរថា ការចំណាយពេលនៅភូមិភូរីខាន់គឺដូចជាទុកឱកាសឲ្យក្រុមពាណិជ្ជករKenអាចទៅដល់កោះស្មៅលឿងមុន ប៉ុន្តែចុះបើរបស់នៅកោះសាមីជារបស់ពិត ពាណិជ្ជករដែកថែបដែលខំទៅតាមរ៉ាទូដល់កោះស្មៅលឿងមិនត្រូវខាតជើងទទេ?

ចំណែកឌីម៉ាវិញ ទន្ទឹមនឹងសេចក្តីសុខទាំងប៉ុន្មានដែលនាងទទួលបានពីរាមនរិន្ទក្នុងរយៈពេលដែលនៅក្បែរគេ ធ្វើឲ្យលេចឡើងនូវសេចក្តីភិតភ័យបារម្ភពីសុខទុក្ខគេព្រមៗគ្នាដែរ។

ពេលអវត្តមានគេ នាងចាប់មានពីភាល់។ ទីនេះជាតំបន់ដែលគេទើបតែមកដល់ជាលើកដំបូង និងជាតំបន់ចុងកាត់មាត់ញកឆ្ងាយហួសគេ មិនមែនជាជនសាមញ្ញដែលគួរដើរហើរសេរីនោះទេ។ តើអង្គរក្សរឿនតែម្នាក់អាចការពារគេបានកម្រិតណាទៅ?

ធីតាចាប់ផ្ដើមអផ្សុកលែងឃ្លានអាហារ និងចេះទន្ទឹងផ្លូវគេ។ ក្ដីនឹករលឹកស្រាប់តែធ្វើឲ្យនាងយល់ថា ប៉ុន្មានថ្ងៃសោះ នាងហាក់មានគេពេញក្នុងបេះដូង ជំនួសឲ្យស្រមោលអពមង្គលជាមួយពាណិជ្ជករ Kenទៅហើយ។

"ឯងជាស្រីសាវ៉ា ដួរចិត្តរហ័សណាស់មែនទេកេតឌីម៉ា" នាងសួរខ្លួនឯង។ នាងមិនបានដឹងទេថា តាមពិតនាងមានគេតាំងពីថ្ងៃដំបូងដែលនាងបានបោះបង់ និងទុកចោលភាពជាស្រីក្រមុំនៅកន្លែងគេ។ ព្រោះតែគេបែកពីនាងយូរ និងមិនបាននឹកនាដល់នាងទៀត បានជាបេះដូងអស់សង្ឃឹមនោះ ចាប់មានរូបពាណិជ្ជករដែកថៃបដែលចូលមករាយអន្ទាក់ស្នេហ៍។ នៅពេលជួបគេសាជាថ្មីនៅកោះបាលី នាងតែងយល់ថាគេជាមនុស្សអាក្រក់ ប៉ុន្តែនៅជិតគេម្ដងជាពីរដង នាងបានកត់ទុកនូវអំពើល្អទាំងឡាយរបស់គេក្នុងបេះដូងដោយមិនដឹងខ្លួនទៅហើយ។ បើមិនដូច្នោះទេហេតុអ្វីក៏គេបំពាននាងនៅចាយ៉ាពូរ៉ាដោយការប្រចណ្ឌ នាងបែរជាមិនខឹងនឹងគេហើយបន្តដំណើរមកកាន់កោះស្មៅលឿងជាមួយគេទៀត?

"ឯងស្រលាញ់គេច្បាស់ណាស់កេតឌីម៉ា! ចុះបើថ្ងៃណាមួយ គេលែងត្រូវការឯងទៀតនោះ តើឯងត្រូវកាត់ចិត្តរបៀបណាវិញស្រីល្ងង់?"

តរុណីនិងនាយគង់ព្រមទាំងកងកាពារពីរនាក់ទៀតបានចេញដំណើរទៅកូនផ្សារក្រមួនមួយក្បែរនោះ ជាការកម្សាន្តផង រកមើលសម្ភារៈត្រូវប្រើប្រាស់ផង។ នារីដើរថ្មើរជើងកាត់តាមជើងភ្នំដែលមានផ្ទះអ្នកស្រុករកេតរកូត និងចម្ការកាហ្វេតូចៗ។ ទាំងស្រងេះស្រងោចក្នុងចិត្ត នៅពេលដែលគេលែងនៅក្បែរ នាងស្រាប់តែគិតម្នាក់ឯងថា បើបានរាមនរិន្ទមកដើរទន្ទឹមគ្នាលើតំបន់ធម្មជាតិស្រស់ត្រកាលកម្របានមកដល់នេះ ហើយគេឈប់រវល់នឹងរឿងតន្ទប្បដិមាដ៏ស្មុគស្មាញនោះ តើពិភពលោកនឹងប្រែទៅជាល្អយ៉ាងណា ?

មួយដង្ហើមក៏គិតពីគេ ធ្មេចភ្នែកក៏ស្រមៃឃើញគេបើកភ្នែកក៏ទន្ទឹងផ្លូវគេ នាងដឹងថាសម្ពាយស្នេហាលើខ្នងចាប់ផ្ដើមធ្ងន់ហើយចង់ដកចិត្តវិញក៏មិនមែនស្រួលដែរ។

ល្ងាចណាស់ហើយ តរុណីត្រឡប់មកផ្ទះសំណាក់វិញ។ ឌីម៉ាដើរសំដៅមករកបន្ទប់សម្រាកដោយមុខស្ងួត។ ភ្លាមនោះនាងប្រែទៅជាងឿងឆ្ងល់មួយរំពេច កាលបើឃើញអ្នកបម្រើឥណ្ឌូណេស៊ី ជាច្រើននាក់ដើរខ្វាត់ខ្វែងគ្នា ចុះឡើងក្នុងអាគារៈប្រញាប់ប្រញាល់ ហាក់បីដូចជាកំពុងរៀបចំពិធីសំខាន់អ្វីមួយអញ្ចឹង ។...

នាងឃើញពួកគេលើកភេសជ្ជៈ និងអាហារសំដៅបន្ទប់ប្រជុំដែលស្ថិតនៅសាលធំមួយខាងស្ដាំដៃ។

ឬមួយរាមនរិន្ទត្រឡប់មកវិញហើយ? បើមិនអញ្ចឹង តើគេកំពុងធ្វើបដិសណ្ឋារកិច្ចទទួលអ្នកណា បើនៅជាន់នេះ ជាកន្លែងផ្តាច់មុខសម្រាប់បុរសខ្មៅក្នុងបេះដូងនាងនោះ?

ទោះមិនហ៊ានចូលទៅកាន់បន្ទប់ប្រជុំដោយគ្មានការអនុញ្ញាត តែឌីម៉ាបានឆ្លៀតស្ទាក់សួរនារីឥណ្ឌូណេស៊ីមួយរូបដែលកំពុងលើកស្រាបារាំងនៅនឹងដៃជាភាសាអង់គ្លេស... ពេលនោះហើយដែលនាងដឹងថារាមនរិន្ទ កំពុងជួបចុះហត្ថលេខាលើការទិញដូរមួយជាមួយមេកុលសម្ព័ន្ធល្បឿងដែលនាងដឹងថាប្រាកដជាទាក់ទងនិងឥន្ទប្បដិមា។...

ឌីម៉ាគិតថាបើគេរវល់យ៉ាងនេះទៅហើយចង់ជួបគេគឺគ្មានប្រយោជន៍ទេព្រោះកិច្ចការចំពោះគេគឺសំខាន់ជាងរឿងស្រីៗឆ្ងាយណាស់។ នាងដើរបង្ហួសមកកាន់បន្ទប់យឺតៗ ទាំងហត់នឿយ និងឯកា។មិនទាន់បានមួយដង្ហើមស្រួលបួលផង តែរំពេចនោះសម្រិបជើងជាច្រើនដែលលាន់មកពីក្រោយខ្នងរួមជាមួយនឹងសំណើចខឹកៗរបស់មនុស្សប្រុសពីរនាក់ ដែលតរុណីនៅចំណាំបានថាគឺជាសំឡេងរាមនរិន្ទ ហើយសំឡេងមួយទៀតនោះ ប្រាកដជាសំណើចរបស់ជនជាតិឥណ្ឌូណេស៊ីមេកុលសម្ព័ន្ធនោះហើយបើតាមស្មាន ...។

ក្នុងគ្រាដែលប្រថុចញ៉ុចដែលឌីម៉ាដឹងថាត្រូវគេចខ្លួនកុំឲ្យពួកគេឃើញនោះ នាងប្រទះឃើញបន្ទប់ធ្វើការរបស់នរិន្ទ នៅក្បែរបង្កើយក៏ប្រញាប់ស្ទុះចូលលាក់ខ្លួន ។...

ចូលដល់បន្ទប់ធ្វើការរបស់គេ នាងឃើញមានតុ និងកៅអីនៅរត្រៀបត្រាហាក់ដូចកាលពីយប់គេបានចូលមកជួបប្រជុំជាមួយកូនចៅគេពីពេលណាក៏មិនដឹង ពិសេសក្រោយពេលនាងគេងលក់។ នាងទើបតែចាប់អារម្មណ៍ថា ការងារដែលគេកំពុងធ្វើមិនមែនជារឿងលេងសើចទេ។ ម្ល៉ោះហើយពេលនេះទៀត នាងឈានជើងចូលមកដល់ទីនេះដោយចៃដន្យ នាងមិនទុកចិត្តខ្លាចនរិន្ទ នាំភ្ញៀវចូលមកឃើញ នាងក៏បង្ហួសចូលដល់បន្ទប់ទឹកតែម្តង...។

ដូចអ្វីដែលឌីម៉ាគិតមែន... នាងមិនទាន់បិទទ្វារបន្ទប់ទឹកបានមួយដង្ហើមត្រឹមត្រូវផង... ស្នូរសម្រិបជើងពួកគេ បានឈានចូលមកដល់បន្ទប់ធ្វើការស្រេចទៅហើយ ។..

ភាគទី៣៥

តាមរយៈវាំងននហៀរគ្រប់ទ្វារ... ឌីម៉ាសសៀរខ្លួនអែបនៅទីនោះ... ហើយលួចសម្លឹងទៅបន្ទប់ធ្វើការនរិន្ទតាមរយៈប្រលោះកញ្ចក់ដែលរចនាជាម៉ូតលំអលើទ្វារ ។...

បុរសសង្ហាដែលនាងនឹកទាំងយប់ទាំងថ្ងៃកំពុងនាំបុរសមាឌក្រអាញខ្មៅដែលនាងបានឃើញគេចេញពីចំណោមទាហាននៅឯកំពង់ផែមកអង្គុយជុំវិញលើតុមួយកណ្តាលបន្ទប់ ។

ឪម៉ាដឹងថាដែលគេប្រជុំដល់យប់អាធ្រាត្រ និងចាកចេញពីដំណេកតាំងពីមេឃមិនទាន់ភ្លឺតាមពិតប្រហែលជាគេបានតម្រុយធំជុំវិញឥន្ទប្បដិមាក្នុងក្តីស្រមៃរបស់គេមែនហើយ...។

មាណវីលួចសម្លឹងផ្ទៃមុខបុរសសង្ហារម្ចាស់ចិត្ត ដែលពេលណាក៏ញញឹមស្រស់បង្ហាញសម្រស់ជាបុរសភេទពេញលក្ខណៈតែមានអំណាច។ នាងឃើញគេកំពុងលើកដៃចង្អុលទៅកុំព្យូទ័រលើតុដោយពោលពន្យល់បុរសម្ចាស់កោះជាភាសាអង់គ្លេស ៖

-ធនាគារGLមានសាខាធំនៅទីនេះ ប៉ុន្តែគេអាចទម្លាក់លុយមកតាមរយៈធនាគារមួយនេះនៅ Jaya Puraចុងក្រោយសាខាមួយនេះនឹងបញ្ជូនមកដល់ស្រុកSarmi។ លោកអូណ័រយល់យ៉ាងណាដែរ?...

ឪម៉ាងាកទៅរកបុរសសម្បុរខ្មៅ... នាងឃើញគេនោះញញឹមងក់ក្បាលផ្ងក់ៗ... ហាក់ដូចជាពេញចិត្តចំពោះអ្វីដែលរាមនរិន្ទបង្ហាញ... ។បបូរមាត់គេបន្លឺនូវពាក្យខ្លីតែច្រើនដង ៖

- ល្អណាស់... ល្អណាស់ ...!...

តាមពិតពួកគេរស់នៅតំបន់ព្រៃភ្នំ ការបញ្ជូនប្រាក់ និងការប្រើប្រាស់ប្រព័ន្ធធនាគារជារឿងថ្មីសុទ្ធសាធសម្រាប់ពួកគេ។ ធីតាយើងយល់ថាប្រហែលទឹកប្រាក់ដែលគេទារពីរាមនរិន្ទមានចំនួនច្រើនដែលគេមិនអាចមានលុយសុទ្ធឲ្យបាន ដូច្នេះហើយបានជាគេចាំបាច់ត្រូវនាំគ្នាមកស្វែងយល់ដល់ទីនេះ។ ប៉ុន្តែដែលនាងរីករាយនោះគឺថាប្រហែលជារាមនរិន្ទបានជួបវត្ថុសំណព្វក្នុងចិត្តនាយហើយបានជាឈានដល់ថ្នាក់ព្រមព្រៀងបែបនេះ។

ងាកទៅរាមនរិន្ទ នាងឃើញគេបញ្ចេញភាពស្រស់ស្រាយលើផ្ទៃមុខហាក់ដូចជាគិតថាកណ្តាប់ដៃខ្លួនកំពុងក្តាប់ជាប់នូវជោគជ័យមួយរយភាគរយទៅហើយ... នាងក៏កាន់តែមានអារម្មណ៍ចូលរួមត្រេកអរជាមួយគេ... ដោយលួចញញឹមស្រស់ម្នាក់ឯងទាំងមិនដឹងខ្លួន...។

ខណៈនោះរាមនរិន្ទ បន្លឺសួរទៅកាន់បុរសពុកចង្កា ៖

- អញ្ចឹងពេលណាទើបយើងអាចធ្វើកិច្ចសន្យាបាន ?...

បុរសម្ចាស់កោះងក់ក្បាលឆ្លើយភ្លាម ៖

- ឆាប់ៗនេះចុះ! កាន់តែឆាប់កាន់តែល្អ! យល់ថាអ៊ីចឹងទេថៅកែរាម ?

រាមនរិន្ទ ញាក់ចិញ្ចើម ៖

- O.K. ! អញ្ចឹងរៀបចំឥឡូវតែម្តងទៅ...!

ម្ចាស់កោះសម្បុរខ្មៅងក់ក្បាលយ៉ាងញាប់ ដោយញញឹមញញែម...គេលើកកែវស្រានៅដៃក្រេបបន្តិចរួចទើបត្រហែម យកសំឡេងដោយលួចមើលមុខរាមនរិន្ទផង។

មួយខណៈទើបពោលទៅ កាន់កំលោះអភិជន ៖

- ថៅកែរាម! ខ្ញុំឮគេសរសើរថា អ្នកគ្រូបង្ហាញម៉ូតដែលនៅជាមួយថៅកែស្អាតណាស់! ខ្ញុំចង់ស្គាល់អ្នកបង្ហាញម៉ូតខ្មែរម្នាក់នោះបានទេ ?...

ឌីម៉ាធ្លាក់ថ្លើមក្តុក។ ដៃជើងនាងចាប់ផ្តើមស្ពឹក ហើយបេះដូងលោតញាប់ដោយការភ្ញាក់ផ្អើល។ នាងងាកសម្លឹងរាមនរិន្ទយ៉ាងរហ័ស។ នៅទីនោះនាងប្រទះឃើញនរិន្ទ ដៀងភ្នែកសម្លឹងបុរសមេកុលសម្ព័ន្ធដោយទឹកមុខឥតផ្លាស់ប្តូរ គ្មានសញ្ញាថាគេខឹងសម្បារ ឬត្រេកអរឡើយ។ ក្នុងមួយខណៈដែលបេះដូងស្រស់ស្រីកំពុងលោតញាប់ខុសចង្វាក់ សំឡេងបុរសជនជាតិឥណ្ឌូណេស៊ីលាន់ឡើងបន្តទៀត ៖

-ឮថាស្រីនោះឈ្មោះឌីម៉ា អីដូចជាកេតឌីម៉ាអញ្ចឹងហើយ? ខ្ញុំចង់ជួបនាងមែនទែន? ថៅកែរាម ជួយខ្ញុំផង! O.K. ទេ? បើ... បាន...

បុរសខ្មៅពុកចង្ការូបនោះមិនដឹងជានឹកឃើញយ៉ាងម៉េចទេបានបញ្ឈប់កណ្តាលទីមិនបញ្ចប់ប្រយោគរបស់ខ្លួន តែនៅឯណោះឌីម៉ាកំពុងញាប់ញ័រអស់រាងកាយដោយក្តីរន្ធត់។ នាងសម្លឹងទៅរាមនរិន្ទមិនហ៊ានដកភ្នែក... សំឡេងខ្សឹបៗមួយលាន់ឡើងដោយសម្ងាត់ក្នុងចិត្តមាណវីកម្សត់...៖

- កុំយល់ព្រមនឹងគេអី !...

តែភ្លាមនោះ នាងឃើញរាមនរិន្ទងើបមុខសម្លឹងបុរសម្ចាស់កោះហើយបបូរមាត់គេដែលកាលពីយប់មិញពោលពាក្យផ្អែមល្ហែមពោរពេញដោយស្នាមញញឹមដាក់នាងនោះ ពេលនេះគេវាចាដោយទឹកមុខស្មើៈ

- បើខ្ញុំប្រគល់នាងឲ្យលោក... កិច្ចសន្យារបស់យើងនឹងរួចស្រេចមែនទេ ! ?...

ស្រីកម្សត់ទទួលអារម្មណ៍ដូចត្រូវគេចាប់បោះទម្លាក់ជ្រោះ... កាយវិការនរិន្ទហាក់ដូចជាយល់ព្រមប្រគល់នាងទៅឲ្យបុរសពុកចង្កាពិតណាស់។ ទឹកភ្នែកពីរតំណក់រមៀលធ្លាក់មកដក់លើផែនថ្ពាល់ដែលសស្លាំងដោយភាពសោកសៅនិងរន្ធត់។ នាងទទួលថាបេសកកម្មឥន្ទប្បដិមារបស់នរិន្ទសំខាន់ជាងរូបនាងឆ្ងាយណាស់ គេឆ្លងការលំបាកលំបិនសព្វអន្លើក៏ដោយសារតែវត្ថុនោះ ពេលនេះគេស្ម័គ្រចិត្តប្រគល់នាងទៅឲ្យជនបរទេសក៏គ្មានអ្វីចម្លែកដែរ តែទោះជានាងដឹងអញ្ចឹងក៏ដោយ ក៏នាងនៅតែទទួលអារម្មណ៍ឈឺចាប់ស្ទើរស្លាប់ទាំងរស់ ព្រោះគេសាហាវហួសពីការគិតរបស់នាងទៅទៀត ។

សំឡេងជនបរទេសម្ចាស់កុលសម្ព័ន្ធពោលតបទៅរកបុរសខ្មែរ ៖

- យប់នេះឲ្យអ្នកគ្រូបង្ហាញម៉ូតយកកិច្ចសន្យាទៅលើភ្នំ... មានគេចាំទទួលនាងហើយ! ចំណែកកិច្ចសន្យានោះនឹងរួចរាល់នៅពេលនោះដែរ!...

ទប់ខ្លួនមិនចង់នឹងនៅពេលដឹងថាខ្លួននឹងត្រូវក្លាយជាថ្នូរសម្រាប់ហត្ថលេខារបស់បុរសប្រមុខកុលសម្ព័ន្ធ។ កេតឌីម៉ាយំរហាមប៉ុន្តែក៏នៅតែប្រឹងសម្លឹងទៅបន្ទប់ធ្វើការរបស់រាមនរិន្ទស្ទើរមិនហ៊ានដកដង្ហើម នាងរង់ចាំមើលក្រែងគេប្រែចិត្តវិញ តែឥតសង្ឃឹមទេព្រោះពេលនេះ រាមនរិន្ទ និងបុរសហិណ្ឌូបាននាំគ្នាចាកចេញពីបន្ទប់ទៅហើយ ...។...

មាណវីទម្លាក់ខ្លួនអង្គុយផ្ទាល់ទៅនឹងឥដ្ឋ។ នាងដឹងថាលទ្ធផលនៃមិនការដែលមិនប្រមាណខ្លួនលទ្ធផលនៃភាពជាមនុស្សដៃខ្លីដែលឈោងស្រវាឱបភ្នំ គឺបានមកវិញត្រឹមតែភាពជូរចត់យ៉ាងដូច្នេះ។

ស្រីបង្ហាញម៉ូដ ខាំបបូរមាត់ស្ទើរដាច់ នាងនិយាយប្រាប់ខ្លួនឯងស្ងាត់ៗក្នុងចិត្តថា បើទុកណាជារាមនរិន្ទមិនស្រឡាញ់នាង ក៏មិនសមដាច់ចិត្តធ្វើមកលើនាងដល់ថ្នាក់នេះឡើយ គេភ្លេចអស់ហើយសម្ដីផ្អែមល្ហែមទាំងប៉ុន្មាននោះ ព្រោះគេជាអភិជន ជាអ្នកធ្វើការធំ គេឲ្យតម្លៃផលប្រយោជន៍ គេធំជាងការឈឺចាប់របស់អ្នកដទៃ។

កូនកាំបិតចិត្តផ្លែឈើ ដែលស្ថិតនៅលើថាសផ្លេចាំងព្រាកៗក្រោមរស្មីអំពូលអគ្គិសនីដែលលំអផ្ទៃបន្ទប់...។ ផ្លូវទ័លច្រកមួយលេចចេញមកក្នុងគំនិតនារី នាងស្ទុះក្រោកយ៉ាងរហ័ស ស្រវាកាំបិតមកក្ដាប់យ៉ាងណែនក្នុងដៃ ជាមួយដំណក់ទឹកភ្នែកដែលប្រជែងគ្នាស្រក់មកសស្រាក់...។...

នាងគិតស្រេចហើយថា ស៊ូស្លាប់ក៏មិនព្រមប្រឡាក់ប្រឡូសជាមួយអ្នកណាទៀតដែរ ជីវិតជាទាសីស្នេហ៍របស់នាងនឹងបញ្ចប់ត្រឹមនេះ។ ប៉ុន្តែទន្ទឹមនឹងលើកកូនកាំបិតសស្វាចមកមើលនាងនឹកឃើញភ្លាមដល់ប្អូនប្រុសតូចមិនដឹងក្តីនៅភ្នំពេញនៅឡើយ ព្រោះតែគេនោះហើយទើបនាងត្រូវធ្លាក់ក្នុងកណ្តាប់ដៃរាមនរិន្ទ នាងលក់កិត្តិយសព្រោះតែគេត្រូវវះកាត់ដើម្បីសង្គ្រោះជីវិត ពេលនេះគេជាសះពីជំងឺ គេផុតពីសេចក្តីមរណៈហើយ បើនាងទៅចោលគេ តើគេពឹងលើអ្វី ?។

តរុណីទម្លាក់ដៃចុះទាំងតានតឹងក្នុងចិត្ត។ ព្រោះដឹងថានាងមិនអាចគេចយករួចខ្លួនតាមរយៈការសម្លាប់ខ្លួនឲ្យផុតទុក្ខ ហើយបណ្តោយឲ្យប្អូនតូចមិនដឹងក្តីនៅរងកម្មម្នាក់ឯងបាន អញ្ចឹងហើយ មធ្យោបាយចុងក្រោយដែលនាងសម្រេចចិត្តជ្រើសរើសនោះ គឺរកផ្លូវត្រលប់ទៅភ្នំពេញវិញជាបន្ទាន់។

នាងទុកកូនកាំបិតជាប់នឹងខ្លួន ហើយត្រលប់ទៅបន្ទប់រើយកប្រាក់កាសរបស់ខ្លួនព្រមទាំងលិខិតឆ្លងដែនដោយប្រញាប់ប្រញាល់ដើម្បីចាកចេញពីផ្ទះសំណាក់។

មកដល់ផ្សារ នាងត្រូវបានគេប្រាប់ថារថយន្តឈ្នួលដែលដឹកអ្នកដំណើរទៅកំពង់ផែនោះអស់ជើងដោយសារតែល្ងាចពេកទៅហើយ។ រយៈពេលមួយម៉ោងដែលរថយន្តឈ្នួលជូនមនុស្សទៅដាក់កប៉ាល់ នាងអាចដើរដោយជើងកាត់តាមផ្លូវលំក៏អាចទៅដល់កំពង់បានដូចគ្នា ដែលនៅទីនោះ ឌីម៉ាអាចឆ្លងទឹកត្រឡប់ទៅកាន់ទីក្រុងចាយ៉ាពូរ៉ា ដើម្បីឡើងយន្តហោះត្រឡប់ទៅភ្នំពេញវិញ ...។

ដើម្បីទាន់ជើងកប៉ាល់ឌីម៉ាគ្មានជម្រើសទេ នាងត្រូវបង្ខំចិត្តធ្វើដំណើរដោយជើងតាមផ្លូវលំដែលអមសងខាងដោយព្រៃក្រាស់ឃ្មឹក។

ពលរដ្ឋឥណ្ឌូណេស៊ីជាច្រើនក៏ធ្វើដំណើរតាមនោះដែរ ដែលជាអំណោយផលល្អមិនសូវឲ្យតរុណីយើងភ័យខ្លាចពីបញ្ហាសុវត្ថិភាព ប៉ុន្តែដើរបានកន្លះម៉ោងផ្លូវបំបែកបានបង្ហាញខ្លួនហ្វូងមនុស្សក៏បានបំបែកគ្នាតាមទិសដៅរៀងៗខ្លួន។

ស្រីកម្សត់ត្រូវនៅទីទើរចំពោះផ្លូវតូចៗជាច្រើនដែលធ្វើឲ្យនាងមិនប្រាកដក្នុងចិត្តថាផ្លូវណាមួយដែលអាចឲ្យនាងទៅដល់កំពង់ផែនោះឡើយ។..

នាងបានសាកសួរក្រុមអ្នកដំណើរតែម្តងនេះឌីម៉ាត្រូវខកចិត្តយ៉ាងធ្ងន់ព្រោះពលរដ្ឋទាំងនោះគ្មានសមត្ថភាពប្រើភាសាអង់គ្លេស ដូចជនជាតិឥណ្ឌូណេស៊ីនៅឯផ្សារ និងផ្ទះសំណាក់ឡើយ។

ថ្ងៃលិចហើយ ចង់មិនចង់នាងត្រូវប្រថុយធ្វើដំណើរតាមផ្លូវលំមួយខាងឆ្វេងដៃ តាមការធ្វើកាយវិការប្រាប់របស់ស្ត្រីមូស្លីមម្នាក់ ដែលបានលក់ពិលមួយឲ្យនាង ។

មេឃងងឹតជាបណ្តើរៗ ពេលវេលាកន្លះម៉ោងក៏បានហួសផុតទៅហើយ ឌីម៉ាដឹងថាខ្លួននៅវិលវល់ក្នុងព្រៃដ៏ក្រាស់គួរឲ្យបារម្ភ។ មនុស្សម្នាបែកទៅណាអស់ក៏មិនដឹង ក្រៅពីសូរចចកលូល្វើយៗគ្មានសញ្ញាណាមួយបង្ហាញថានាងរកឃើញសមុទ្រ រកឃើញកំពង់ផែដូចការគិតទុកទេ...។...

នាងបង្ហាញម៉ូតដែលខ្សត់ខ្សោយកម្លាំងតាំងពីព្រឹក ចាប់ផ្តើមលើកជាយសំពត់រត់កាត់ព្រៃស្ងាត់ដែលក្លាយទៅជាស្រអាប់សឹងមើលផ្លូវលែងឃើញព្រោះគ្មានពន្លឺព្រះអាទិត្យ។

ពិលបានទិញពីស្ត្រីមូស្លីមជួយឌីម៉ាបានតិចតួចណាស់ក្នុងការបន្តដំណើរទៅមុខព្រោះមេឃងងឹតស្លុបទៅហើយ ...។...

ធាតុអាកាសចាប់ផ្តើមត្រជាក់ ឆ្កែចចកក៏ប្រជែងគ្នាលូរំពងព្រៃ ធ្វើឲ្យតរុណីរូបល្អតក់ស្លុតស្ទើរបាត់វិញ្ញាណ។ នាងរាវរកកូនកាំបិតដែលលាក់ទុកពីក្រោមអាវធំ ក្នុងពេលដែលនាងទើបនឹងភ្ញាក់ខ្លួនថាយប់នេះ ប្រសិនបើរកផ្លូវចេញពីព្រៃមិនឃើញទេ នាងនឹងក្លាយទៅជាចំណីចចកប្រាកដណាស់ ។

ដោយភាពតក់ស្លុត ឌីម៉ារត់បណ្តើរស្រែករកជំនួយបណ្តើរ ...៖

- មានមនុស្សទេ ?...ជួយខ្ញុំផង ?...

ក្រៅពីឮតែសំឡេងខ្លួនឯងខ្ទ័រមកវិញ ក៏មានតែសន្ធឹកខ្យល់បក់មករំជួយដើមស្រល់ព្រៃគួរឲ្យព្រឺព្រួចប៉ុណ្ណោះ។ នារីរត់ទាក់ជើងនឹងដង្គត់ឈើដួលច្រងាប់ច្រងិលហើយរបូតពិលពីដៃបែកខ្ទាយងងឹតស្លុប។

នាងក្រោកអូសជើងដែលឈឺដោយការទង្គិចនោះកណ្តាលភាពងងឹតសូន្យសុងសឹងឱនមើលជើងខ្លួនឯងមិនឃើញ។ ទម្រាំតែភ្នែកអាចស៊ាំនឹងភាពងងឹតបាន នាងបន្តរត់កាត់ភាពងងឹតនៃស្បៃរាត្រីទាំងយំសស្រាក់រកជំនួយ...

- មានអ្នកណានៅទីនេះទេ ...?... ជួយខ្ញុំផង ...!...

ម្តងណេះចប់ហើយ សូម្បីតែពិលបំភ្លឺផ្លូវក៏គ្មានទៀតដែរ។ នាងរត់ឃើតជាងមុនព្រោះតែការមុតបន្លាផងផ្លូវងងឹតមិនយល់ទិសតំបន់ផង។ នាងស្រែករហូតអស់កម្លាំង និងអស់សង្ឃឹមរលីងក្នុងខ្លួន។

ស្រស់ស្រីងាកក្រោយដោយគិតថានឹងបកក្រោយវិញតែនាងមើលលែងយល់ថាទីណាជាទីណាទៅហើយ។ កេតឪម៉ាឈរឱបដៃទាំងញ័រចំប្រប់សម្លឹងជុំវិញខ្លួនហើយងើយសម្លឹងមេឃរង់ចាំពន្លឺព្រះច័ន្ទជាជំនួយមាត់ពោលខ្សាវៗបានត្រឹមពីម៉ាត់ចុងក្រោយថា ៖

- ជួយផង !...

សំឡេងក្រអួនមួយលាន់មកល្វើយៗតាមកម្លាំងខ្យល់បក់ ៖

-ឪម៉ា!?

ដូចមនុស្សស្រេកទឹកស្ទើរស្លាប់ ដើរប្រទះទន្លេធំល្វឹងល្វើយ ស្គាល់ហើយថាជាសំឡេងអ្នកណា  តរុណីប្រមូលកម្លាំងស្រែកតបទាំងយំសស្រាក់៖

-លោកប្រុសរាម !... លោកប្រុសរាម !... ជួយផង !... ជួយផង លោកប្រុសរាម ...!...

ពិតជារាមនរិន្ទមែន គេប្រហែលជាបានឮសម្រែកនាងហើយ បានជាសំឡេងគេឮកាន់តែជិតឡើង

-ឪម៉ាៗ

នាងបង្ហាញម៉ូដទន្ទ្រាំជើងស្រែកដោយអំណរ ៖

- លោកប្រុសរាម! ខ្ញុំនៅទីនេះ! ជួយផង! ខ្ញុំនៅទីនេះ!...

សម្រិបជើងមនុស្សលាន់ឮមកស្រឹបៗពីចម្ងាយ សេចក្ដីសង្ឃឹមលេចចេញមកច្បាស់ឡើងៗក្នុងចិត្តតរុណីឪម៉ាងាកទៅរកទិសនៃស្នូរជើងទាំងអរពើតក្នុងចិត្ត។ កណ្ដាលភាពងងឹតនៃស្បែរាត្រី នាងបានឃើញលេចចេញនូវ រូបរាងមាំទាំរបស់មនុស្សម្នាក់ ដែលមានកាន់ពិលមួយនៅនឹងដៃផង សំឡេងគេ ដែលហៅឈ្មោះនាងមិនដាច់នោះ បានធ្វើឲ្យនាងភ្លេចអស់រលីងនូវរឿងអកុសលទាំងប៉ុន្មាន ដែលនាងបានជួបកាលពីល្ងាចក្នុងផ្ទះសំណាក់ នាងស្ទុះរឹងទៅរកគេ ដោយលាដៃឱបគេជាប់ ហាក់ខ្លាចវង្វេងបាត់។

រង្វង់ដៃបុរសមាឌធំក្រសោបរាងកាយតូចច្រឡឹងវិញយ៉ាងណែនហាក់ចង់គ្របឲ្យបាត់នូវសំណោកខ្សឹកខ្សួលរបស់នាងដែលកំពុងផ្ទប់មុខយំសស្រាក់ជាប់នឹងទ្រូងខ្លួន។...

ក្លិនខ្លួនដែលធ្លាប់នៅនែបនិត្យមិនងាយបំភ្លេចបានរួមជាមួយរង្វង់ដៃដ៏មាំទាំនៃកំលោះអភិជនបានធ្វើឲ្យភាពកក់ក្ដៅរត់ចូលមកក្នុងចិត្តមាណវី មួយភាគធំហើយក៏ពិតមែនតែភាពញ័ររន្ធត់ ដែលឪម៉ា

ទើបតែប្រទះជាលើកទីមួយក្នុងជីវិតនេះពិតជាមិនរលាយបាត់ងាយៗឡើយនាងនិយាយអណ្ដឺតអណ្ដកទាំងញ័រមាត់ទទ្រើក ៖

- ...ឆ្កែចចកៗ!

សូរសៀងស្រាលៗ ដែលនាងធ្លាប់បានឮជាញឹកញយ លាន់មកក្បែរសោតាសាជាថ្មី ៖

- ឈប់ខ្លាចទៅ!

ទ្រនិចនាឡិកាក៏រំលងទៅអស់ជាច្រើននាទីដែលតរុណីសំងំយំសសិតក្នុងលង្វែកទ្រូងបុរសម្ចាស់ចិត្តរាមនរិន្ទចាប់ផ្ដើមសួរដោយងឿងឆ្ងល់ ៖

-នៅសុខៗចូលព្រៃធ្វើអីអូនះ?

ស្វាងចេញពីក្ដីតក់ស្លុត ហេតុការណ៍កាលពីក្នុងផ្ទះសំណាក់ដែលនាងលបស្ដាប់រាមនរិន្ទ និងបុរសជាតិឥណ្ឌូណេស៊ីនិយាយគ្នានោះ លេចធ្លោមកក្នុងអារម្មណ៍នាងសាជាថ្មី នាងងើបមុខសម្លឹងគេកណ្ដាលភាពងងឹតនៃស្បៃរាត្រីរួចដកខ្លួនចេញពីរង្វង់ដៃគេយ៉ាងរហ័ស។

"តាមពិតគេមកតាមយើង ដើម្បីយកយើងទៅដូរជាមួយហត្ថលេខាម្ចាស់កុលសម្ព័ន្ធទេតើ"

គិតអញ្ចឹងហើយ ទើបនាងស្រែកទ្រហោយំរត់ចេញពីគេតម្រង់ទៅមុខលែងខ្លាចគ្រោះថ្នាក់។អ្នកប្រុសលំបាកណាស់ទម្រាំនឹងលុកលុយក្នុងព្រៃរកកេតឌីម៉ាឃើញ គេមានរឿងអីបណ្ដោយឲ្យនាងរត់បានងាយៗនោះ គេលូកដៃចាប់កដៃតរុណីជាប់។

ឌីម៉ាណាឈឺចាប់ក្នុងចិត្ត ណាវេទនារាងកាយដោយការរត់ដួល និងមុតបន្លា នាងយំសស្រាក់ដូចបាត់វិញ្ញាណ៖

-លែងខ្ញុំ! ខ្ញុំអត់ត្រឡប់ទៅវិញជាមួយលោកទេ មនុស្សអាក្រក់ មនុស្សចិត្តសាហាវ ហ៊ឹកៗ!

កូនប្រុសអ្នកនយោបាយរំជួលចិត្តចំពោះមុខកាយវិការ ដែលឌីម៉ាមិនធ្លាប់ហ៊ានធ្វើមកលើគេពីមុនមកនេះ។ គេដឹងថានាងកំពុងស្ថិតក្នុងស្ថានភាពមិនអាចគ្រប់គ្រងអារម្មណ៍បាន ទើបពោលសួរវិញ ៖

-និយាយអីហ្នឹងឌីម៉ា? បើមិនទៅវិញ ចង់ទៅណ៎ា ?...

មាណវីយំសស្រាក់ពេលត្រូវគេចាប់កដៃជាប់។ ស្នូរជើងមនុស្សរត់មកព្រូៗដោយមានពិលកាន់មកគ្រប់ដៃផង សំឡេងកូនចៅរាមនរិន្ទដែលនាងធ្លាប់ចំណាំច្បាស់លាន់រំពងព្រៃ ៖

-អ្នកប្រុស? អ្នកប្រុស ?

ធីតាងាកសម្លឹងទៅក្រុមអង្គរក្ស ដែលរត់មកដល់យ៉ាងច្រើនសន្ធឹក ឪម៉ាយល់ថាកាលដែលគេនាំគ្នាមកលុកលុយព្រៃទាំងយប់ ព្រោះចង់ចាប់នាងយកទៅសែនបុរសពុកចង្កានោះប្រាកដណាស់ទោះនាងមិនដឹងថាអ្នកដែលនាងត្រូវទៅជួបជានាយអភិជនខ្មែរវ័យក្មេងសិទ្ធិគុណក៏ដោយ។ នាងលូកដៃដកកូនកាំបិតពីចង្កេះ ចង្អុលទៅរករាមនរិន្ទទាំងគ្រវីក្បាលយំសស្រាក់ ៖

- ខ្ញុំមិនទៅទេ! ខ្ញុំសុខចិត្តស្លាប់នៅទីនេះ! ខ្ញុំមិនឲ្យលោកចាប់ខ្ញុំទៅឲ្យមេកុលសម្ព័ន្ធនោះទេ !...

ឪម៉ាកញ្ច្រោលកន្ត្រាក់ដៃពីរាមនរិន្ទ តែគេស្រវាឱបនាងហាក់ខ្លាចនាងគេចទៅក្នុងព្រៃបាត់ក្នុងភាពតក្កមារហ័សដូចផ្លេកបន្ទោរ នាងចាក់គេមួយកាំបិតចំស្មាខាងឆ្វេងខ្វាតឈាមមកលើដៃនាង។

ឪម៉ាដកដៃលែងកាំបិតចោលឲ្យធ្លាក់ទៅលើដីទាំងតក់ស្លុតស្ទើរទន់ជង្គង់ដួល រាមនរិន្ទលែងដៃពីនាង ដោយទ្រេតទ្រោតព្រោះមុខរបួស។

សំឡេងអង្គរក្សរឿនលាន់មកខ្ទ័រព្រៃដោយក្តីរន្ធត់ ៖

-អ្នកប្រុស!?

តរុណីនៅទ្រឹងព្រោះតែស្មានមិនដល់ថាតែក្នុងមួយវិនាទីសោះនាងបានចាក់រាមនរិន្ទឲ្យរបួសស្រេចទៅហើយ នាយគង់កងការពាររបស់រាមនរិន្ទ ស្រែកដោយក្រេវក្រោធ ៖

-កេតឪម៉ា ម៉េចក៏ចាក់អ្នកប្រុស?

ឪម៉ា ដែលត្រូវភាពរន្ធត់គ្របសង្កត់ពេញរាងកាយទៅហើយ។ នាងមានពេលឯណារវល់នឹងសំដីពួកកងការពារនោះ មានតែរាមនរិន្ទឯណោះទេដែលដឹងច្បាស់ថាកូនចៅខ្លួនកំពុងខឹងនាងពេញបន្ទុកបានលើកកាំភ្លើងតម្រង់មកឪម៉ាជាស្រេចទៅហើយ។

គេស្រែកកាត់ទាំងឈឺចាប់នឹងមុខរបួសស្ទើរដាច់ដង្ហើម៖

-គង់! កុំ!

សំឡេងរាមនរិន្ទយឺតបន្តិចព្រោះកូនចៅគេបានកេះកែរួចទៅហើយ។ គេគ្មានផ្លូវឯណាជ្រើសរើសក្រៅពីក្រឡាស់ខ្លួនមកពាំងពីមុខស្រីសំណព្វចិត្ត ទទួលគ្រាប់សំណនោះជំនួសនាងឡើយ។

ស្នូរផ្ទុះផ្ទួងរំពងព្រៃ ផ្អើលអស់សត្វស្លាបធំតូច រាងកាយរាមនរិន្ទដួលស្រ៊ុបមកលុតជង្គង់ផ្ទាល់នឹងដីចំពោះកែវភ្នែកតក់ស្លុត របស់តរុណីយើង។